**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី (លើកទី១០)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវ៉ែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង

លោក ម៉ាតូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាចាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក យ៉េត ចរិយា

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ បេិត

*(Mr. Alexander Bates)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទួអាដ ហ្វត *(Mr. Stuart FORD))*

លោក ប៉ាក់ ច័ន្ទលីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនជាប់ចោទ កាំង ហ្គេក អ៊ាវ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UNAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក យុង ផានិត

លោគ គឹម ម៉េងឃី

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វែ៉នណឺ *(Mr. Alain Werner)*

លោក ខារីម ខាន *(Mr. Karim KHAN)*

លោក ហ្វីលីព កាណុន *(Mr. Philippe CANONNE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សី** ៖ ជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ ឌុច

សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........ ទំព័រ ៣៣

សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត ផ្តើមពី ........ ទំព័រ ៤៥

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ៥២

សួរដោយចៅក្រម យ៉ា សុខន ផ្តើមពី ........ ទំព័រ ៦៤

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អាឡិចសាន់ឌឺ ប៊ែត | អង់គ្លេស |
| លោក ហ្វីលីព កាណុន | បារាំង |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ខារីម ខាន | អង់គ្លេស |
| លោក គឹម ម៉េងឃី | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែរ៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធាអង្គជំនុំជម្រះ) | ខ្មែរ |
| ចៅក្រម យ៉ាសុខន | ខ្មែរ |
| លោក តាន់សេណារ៉ុង | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:០៩:៤៥]

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោលតទៅទៀត ដំណើរការប្រព្រឹត្តិទៅនៃកិច្ចពិភាក្សាដេញដោលអង្គហេតុ ម-១៣ បានឈានដល់ដំណាក់កាលនៃការស្តាប់ចម្លើយសាក្សីចប់សព្វគ្រប់ហើយកាលពីម្សិលមិញ ។ ហើយជាបន្តនេះ អង្គជំនុំជម្រះសួរទៅភាគីថា តើអស់លោក លោកស្រី នៅមានសំណួរអ្វីត្រូវសួរដល់ជនជាប់ចោទ ឬក៏មានបំណងលើកនូវឯកសារសំអាង ដើម្បីលើកយកមកពិភាក្សាដេញដោលដែរឬទេ? បើសិនជាមាន សូមអញ្ជើញដោយធ្វើតាមលំដាប់ពីសហព្រះរាជអាជ្ញា មេធាវីការពារតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីមុន ។ បើមានសូមអញ្ជើញ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

អរគុណលោកប្រធាន។ តាមការយល់របស់ភាគី គឺយើងគួរតែអញ្ជើញឲ្យធ្វើសេចក្តីសន្និដ្ឋាននៅព្រឹកនេះ ទាក់ទងទៅនឹងការប្រើប្រាស់ឯកសារ ឈឿន សុទ្ធី ។ ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះធ្វើការចេញសេចក្តីសម្រេចទាក់ទងទៅនឹងឯកសាររបស់ ឈឿន សុទ្ធី ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសួរបញ្ហាពាក់ព័ន្ធជាមួយនឹងរឿងទីមួយ ថាតើកិច្ចការទីមួយនេះមានអ្វីត្រូវសួរដល់ជនជាប់ចោទ ឬក៏ឯកសារផ្សេងដែរឬទេ? ឬឯកសារនោះ គឺសហព្រះរាជអាជ្ញាបានលើកឡើងពីម្សិលមិញហើយ ហើយអង្គជំនុំជម្រះបានសម្រេចជាបណ្តោះអាសន្នហើយ ។ ហើយទុកឱកាសព្រឹកនេះ គឺម្សិលមិញយើងបានសម្រេចច្បាស់លាស់ណាស់ថា ព្រឹកនេះយើងនឹងស្តាប់នូវមតិយោបល់ភាគីពាក់ព័ន្ធនឹងឯកសារនេះ មុននឹងឈានដល់ការសម្រេចចុងក្រោយ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ឯកសារដែលសហព្រះរាជអាជ្ញាចង់ធ្វើការតទល់ជាមួយនឹងជនជាប់ចោទនោះ គឺរបាយការណ៍របស់ ឈឿន សុទ្ធី ដែលខ្ញុំរំពឹងទុកថា លោកប្រធាននឹងធ្វើការពិភាក្សាទៅលើការប្រើប្រាស់ឯកសារនេះមុនពេលដែលខ្ញុំធ្វើការចោទសំណួរ លើកសំណួរផ្សេងៗទៅលើបញ្ហាហ្នឹង ។ ប្រហែលជាលោកចៅក្រមឡាវែន៍ គាត់ចង់បន្ថែមទៅលើចំណុចហ្នឹង ឬក៏យ៉ាងម៉េច?

ខ្ញុំសូមអភ័យទោសគឺ ឈឿន សុទ្ធី ឯកសាររបស់ ឈឿន សុទ្ធី គឺទាក់ទងទៅនឹងបញ្ហោម-១៣ ។

[០៩:១៣:២៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ភាគីនឹងផ្តល់ឱកាសឲ្យផ្តល់យោបល់ ហើយនិងធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធទៅនឹងឯកសារដែលបានលើកឡើងអម្បាញ់មិញនេះ គឺអង្គជំនុំជម្រះពន្យារក្នុងការសម្រេច ។ ប៉ុន្តែ ជាបឋមលោកប្រធានចង់បង្ហាញឲ្យលោកថា តើលោកមានសំណួរចង់សួរទៅជនជាប់ចោទដែរឬទេ? ឬក៏លោកចង់បញ្ជាក់ថា ឯកសារណាមួយ ដែលលោកនឹងយកមកធ្វើជាមូលដ្ឋាន ហើយបញ្ហោរបាយការណ៍ ឈឿន សុទ្ធី នឹងយកមកពិភាក្សានៅពេលក្រោយ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

អរគុណលោកចៅក្រម។ គឺឯកសារដែលសហព្រះរាជអាជ្ញា ដែលចង់លើកឡើងនៅក្នុងសវនាការ គឺឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ឯកសារ ហាម អ៊ិន និង អ៊ិន វ៉ន ហើយនិង ឈឿន សុទ្ធី ។ ដូច្នេះ ឯកសារទាំងបីនេះ គឺជាឯកសារដែលសហព្រះរាជអាជ្ញាចង់ធ្វើការដាក់ជូនអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

ភាគីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានអ្វីត្រូវសួរដល់ជនជាប់ចោទបន្ថែមទៀតទេ?

[០៩:១៥:00]

**លោក ការីម ខាន៖**

អរុណសួរស្តីលោកប្រធាន និងលោកស្រីចៅក្រមជាទីគោរព! គឺខ្ញុំអត់មានសំណួរអីផ្សេងទៀតដើម្បីចោទសួរទៅកាន់ជនជាប់ចោទនោះទេ ។ សូមអរគុណ ។

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

សូមគោរពលោកប្រធាន និងអង្គសវនាការ គឺក្រុមខ្ញុំដូចគ្នាដែរ គឺក្រុមខ្ញុំអត់មានសំណួរណាមួយចង់តាំងសួរទៅកាន់ជនជាប់ចោទនោះទេ ។ សូមអរគុណ ។

**លោក គឹម ម៉េងឃី៖**

សូមគោរពលោកប្រធាននិងអង្គសវនាការ! ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ក៏មិនមានសំណួរអ្វីសួរទៅជនជាប់ចោទដែរ ហើយក៏មិនមានឯកសារអ្វីដាក់ដែរ ហើយសំណូមពរឲ្យបន្តដល់ការសួរទាក់ទងនឹងមន្ទីរស-២១ ។

**លោក ហុង គឹមសួន៖**

ខ្ញុំបាទសូមគោរពលោកប្រធាន និងលោកស្រីចៅក្រមជំនុំជម្រះជាទីគោរព! ខ្ញុំបាទ ជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤ មិនមានសំណួរសួរទៅជនជាប់ចោទទេ ហើយក៏សូមគាំទ្រនូវការលើកឡើងរបស់សហព្រះរាជអាជ្ញាអម្បាញ់មិញនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

លោកហ្វ្រង់ស្វ័រ រូ មានអ្វីពាក់ព័ន្ធទៅនឹងកូនក្តីរបស់លោកទេ ចុងក្រោយនេះ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

អរគុណលោកប្រធាន ជាបឋមគឺទាក់ទងទៅនឹងរបាយការណ៍របស់លោក ឈឿន សុទ្ធី ដែលខាងមេធាវីការពារក្តីទទួលឯកសារជាភាសាបារាំងនៅក្នុង-- យើងបានទទួលឯកសារភាសាក្នុងថ្ងៃ៣ ខែមេសា ឆ្នាំ២០០៩ ។ ខាងមេធាវីការពារក្តីចង់បញ្ជាក់ថា គឺលោក ឌុច គាត់យល់ស្របទាក់ទងទៅនឹងការពន្យល់បណ្តោះអាសន្នទាក់ទងទៅនឹងបញ្ហាឯកសារនេះ ដែលការពន្យល់នោះនឹងផ្តល់ជាពន្លឺចំពោះនីតិវិធីរបស់យើង ។ នេះជាអ្វីដែល ឌុច បានធ្វើឡើងនៅចំពោះមុខចៅក្រមស៊ើបអង្កេត នៅពេលដែលឯកសារនោះលើកឡើងនៅពេលនោះ ។ មេធាវីការពារក្តីលើកឡើងថា សហព្រះរាជអាជ្ញាគឺមិនបានដាក់ឯកសារនេះនៅចំពោះមុខចៅក្រមស៊ើបអង្កេត ។

[០៩:១៨:០១]

ចំពោះការសម្ភាសន៍ ដែលធ្វើឡើងដោយ *ឌីស៊ីខេម (DC-Cam)* គឺមជ្ឈមណ្ឌលឯកសារកម្ពុជាដែលសហព្រះរាជអាជ្ញាចង់ដាក់ជូនអង្គសវនាការ មេធាវីការពារក្តីសូមទទូចថា ឯកសារទាំងពីរនេះមិនគួរជាផ្នែកមួយនៃដំណើរការក្តីនៃ ឬក៏ផ្នែកមួយនៃសំណុំរឿងនោះទេ ។ ឯកសាររបស់ *ឌីស៊ីខេម* គឺមិនអាចជាផ្នែកនៃសំណុំរឿងនោះទេ។ ខ្ញុំសូមលើកឡើងថា ជាថ្មីម្តងទៀត គឺឯកសារទាំងពីរនេះ គឺប្រមូលបានក្នុង លក្ខខណ្ឌមួយដែលមិនមានលក្ខណៈសមហេតុផល ។ ហើយប្រហែលជាឯកសារនេះជាផលប្រយោជន៍ សម្រាប់អង្គការក្រៅរដ្ឋាភិបាលប៉ុណ្ណោះ ហើយវាមិនមែនជាផលប្រយោជន៍

សម្រាប់ជនជាប់ចោទនោះទេ ។

ខ្ញុំសូមផ្តល់ឧទាហរណ៍មួយចំពោះបញ្ហានេះ ។ ផ្នែកទៅលើឯកសារសម្ភាសមួយក្នុងចំណោមពីរនោះ អង្គការក្រៅរដ្ឋាភិបាលគឺ *ឌីស៊ីខេម* គាត់បានរៀបចំរបាយការណ៍ដែលត្រូវបានបោះពុម្ពទូទាំងប្រទេស ហើយវាមាននៅក្នុងរបាយការណ៍នោះ ។ ហើយនៅក្នុងឯកសារនោះ គឺមិនមានការផ្ទៀងផ្ទាត់ ហើយមិនមានការជំទាស់ណាមួយ ហើយអង្គការមួយនោះ គាត់បានជម្រាបទៅសាធារណជនថា គឺមានចំនួនស្លាប់នៅម-១៣ចំនួន៣ម៉ឺននាក់ ហើយមានរបាយការណ៍នេះដែលបានដាក់នៅចំពោះមុខចៅក្រម ។ ដូច្នេះខ្ញុំសូមបញ្ជាក់ថា វាទាក់ទៅនឹងបញ្ហានៃការស្វែងរកការពិត ហើយចំនួន៣ម៉ឺននាក់ទោសដែលស្លាប់នោះ គឺជាការសម្ភាសន៍ ។ ដូច្នេះហើយ សហព្រះរាជអាជ្ញាចង់បញ្ចូលសំណុំរឿង ឬក៏ឯកសារនេះចូលទៅក្នុងសំណុំរឿង ។ នៅក្នុងការពិភាក្សាដេញដោលក្នុងសវនាការទាក់ទងនឹងសាក្សីមួយចំនួន តើយើងអាចបន្តឲ្យមានការបញ្ចូលនូវព័ត៌មានដែលនិយាយថា មានចំនួនស្លាប់ដល់ទៅ៣ម៉ឺននាក់ដែរឬទេ?

នៅថ្ងៃនេះ នៅពេលនេះយើងនឹងធ្វើការស្វែងរកយុត្តិធម៌ យើងមិនមែនជាការធ្វើការឃោសនាណាមួយទេទៅលើបញ្ហានេះ ។ តាងនាមឲ្យមេធាវីការពារក្តី ខ្ញុំស្នើសុំអង្គសវនាការឲ្យដកឯកសារទាំងពីរនេះចេញ ដោយសារឯកសារនេះមិនមានលក្ខណៈវិជ្ជាជីវៈ ។

ចំណុចចុងក្រោយ លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! នៅក្នុងថ្ងៃទី៣នៃអាទិត្យនៃសវនាការក្នុងអាទិត្យនេះ មេធាវីការពារក្តីមានបំណងសូមធ្វើការទាញចំណាប់អារម្មណ៍អង្គសវនាការចំពោះបញ្ហាបកប្រែ ដែលជាបញ្ហាធ្ងន់ធ្ងរ ហើយយើងបានជួនប្រទះនៅទីនេះ ។ នៅអ្វីដែលខ្ញុំប្រមូលបាន យើងបាត់នូវអ្វីដែលបានលើកឡើង៥០ភាគរយជាភាសាខ្មែរ ។

[០៩:២២:០៦]

នេះជាតុលាការដែលផ្អែកទៅលើច្បាប់ គឺនេះជាចំណុចមួយដែលយើងមិនអាចទទួលយកបានទេ នៅពេលដែលយើងធ្វើទៅតាមវិធីដែលយើងកំពុងតែធ្វើនៅបច្ចុប្បន្ននេះ ។ មានន័យថា គឺប្រជាជនកម្ពុជាហ្នឹង គឺថាបាត់បង់នូវព័ត៌មាន៥០ភាគរយពីអ្វីដែលសាក្សីបាននិយាយ ហើយនិងអ្វីដែលជនជាប់ចោទបានលើកឡើង ។ ហើយនៅពេលដែលខ្ញុំលើកឡើងក្នុងការផ្តល់ព័ត៌មានជូនទៅលោកចៅក្រម គឺថាលោក លោកស្រីចៅក្រមហ្នឹង គឺថាបាត់បង់អស់៥០ភាគរយផងដែរ ។ ហើយខ្ញុំក៏មិនដឹងថា តើមានការបាត់បង់ប៉ុន្មានភាគរយទៀតទេនូវអ្វីដែលខ្ញុំបាននិយាយនោះ ។

ខ្ញុំសូមស្នើជាផ្លូវការដល់លោកចៅក្រម ដោយនៅក្រោមអំណាចដែលលោកចៅក្រម លោកស្រីចៅក្រមមាននោះ គឺថាសូមបញ្ជា ឬក៏បង្គាប់ឱ្យខាងរដ្ឋបាលខាងផ្នែកតុលាការនេះ ចាត់ការជាបន្ទាន់ចាត់វិធានការចាំបាច់ជាបន្ទាន់ ។ ដូច្នេះ គឺថាយើងនឹងមានការបកប្រែមួយដែលត្រឹមត្រូវស្មោះត្រង់ ។ ដូច្នេះហើយគឺថា យើងអាចនឹងមានបុគ្គលិកដែលមានជំនាញ ដើម្បីធ្វើការពិនិត្យឡើងវិញនូវប្រតិចារឹកជារៀងរាល់ថ្ងៃ ហើយដើម្បីធ្វើការសម្រេចថា តើមានកំហុសនៃការបកប្រែដែរឬទេ?

នៅចុងបញ្ចប់នៃដំណើរការនីតិវិធីនេះ សាលសវនាការនឹងចេញសេចក្តីសម្រេចចិត្តដោយអាស្រ័យទៅលើអ្វីដែលបាននិយាយនៅក្នុងបន្ទប់សាលសវនាការនេះ ។ ខ្ញុំមិនចង់ធ្វើការស្រមៃថា តើអ្វីនឹងកើតមានឡើងទេ ប្រសិនបើសេចក្តីសម្រេចចិត្តរបស់លោក លោកស្រីចៅក្រមនុ៎ង គឺមិនបានបញ្ចូលនូវសេចក្តីថ្លែងការណ៍ដែលបានធ្វើឡើង ឬក៏ធ្ងន់ធ្ងរជាងនេះទៅទៀតនោះ គឺអ្វីដែលបាននិយាយនោះគឺជាព័ត៌មានមួយដែលមិនត្រឹមត្រូវតាមរយៈការបកប្រែ ។

ខ្ញុំសូមផ្តល់ជាឧទាហរណ៍មួយដល់លោក លោកស្រីចៅក្រម កាលពីព្រឹកម្សិលមិញ នៅពេលដែលលោកសាក្សី គាត់និយាយអំពីរណ្តៅបី ខ្ញុំឮការបកប្រែនិយាយថា គឺឃើញគុកបី ។ អ៊ីចឹងតើយើងត្រូវធ្វើយ៉ាងម៉េចទៅនៅក្នុងករណីនេះ? អ៊ីចឹងខ្ញុំសូមនិយាយថា គឺថាប្រទេសនេះមានអ្នកដែលមានជំនាញគ្រប់គ្រាន់ហើយ ដើម្បីធានាថា យើងមានការបកប្រែបានត្រឹមត្រូវ ។ ខ្ញុំសូមនិយាយថា គឺថាវាមិនមែនមិនធម្មតាទេ បន្ទាប់ពីដំណើរការនីតិវធីជាច្រើនសប្តាហ៍មកហើយ ហើយយើងនៅតែមិនមានការបកប្រែផ្ទាល់ពីខ្មែរមកបារាំង ហើយនិងពីបារាំងមកខ្មែរនោះ ។

[០៩:២៥:៤៨]

ខ្ញុំនិយាយថា នៅពេលដែលយើងប្រើប្រព័ន្ធបកប្រែបន្តគ្នានោះ គឺថាយើងនឹងមានហានិភ័យនៃបាត់បង់ ឬក៏ការមិនយល់គ្នា ។

លោកប្រធាន! ខ្ញុំសូមឱ្យលោកប្រធានប្រើអំណាចដែលលោកប្រធានមាន ដើម្បីស្នើឱ្យខាងផ្នែករដ្ឋបាលចាត់វិធានការសមស្រប ហើយសម្រាប់អស់លោកដែលជាអ្នកបកប្រែដែលធ្វើកិច្ចការដ៏លំបាកនេះ ។ ខ្ញុំសូមនិយាយថា គឺថាយើងត្រូវព្យាយាមទាំងអស់គ្នា ដើម្បីនិយាយឱ្យបានយឺតៗ ដូចដែលលោកលោកស្រីបានបង្គាប់ប្រាប់យើងជាច្រើនដងមកហើយ គឺថាឱ្យយើងសួរសំណួរខ្លីៗ ប៉ុន្តែចំណុចនេះមិនទាន់គ្រប់គ្រាន់ទៅឡើយទេ ។ គឺថា ធនធាននៃការបកប្រែតុលាការនេះគឺមិនបានគ្រប់គ្រាន់នៅឡើយទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា ហើយមានបំណងនិយាយពីបញ្ហាអីទៅ? ពាក់ព័ន្ធនឹងការបកប្រែ ឬក៏កិច្ចការអី?

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

លោកប្រធាន គឺថាខ្ញុំសូមទទួលនូវការណែនាំរបស់ពីលោកដើម្បីធ្វើការឆ្លើយតបទៅនឹងអ្វីដែលលោក រូ បានស្នើឡើង ។ គឺថាយើងមានបញ្ហាចំនួនពីរ គឺទីមួយបញ្ហាទាក់ទងនឹងការបកប្រែ ទីពីរទាក់ទងនឹងឯកសារដែលត្រូវបញ្ចូលទៅក្នុងសំណុំរឿង ។ ហើយខាងសហព្រះរាជអាជ្ញាគឺចង់ធ្វើការដាក់សំណើ ឬក៏ឆ្លើយតបទៅលើបញ្ហាទាំងពីរនេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញៗ ហើយការកត់សម្គាល់ទីមួយ គឺសូមឲ្យលោកសហព្រះរាជអាជ្ញាបញ្ជាក់អំពីឯកសារដែលសហព្រះរាជអាជ្ញាបានលើកឡើងកាលពីម្សិលមិញ ហើយអង្គជំនុំជម្រះបានសម្រេចជាបណ្ដោះអាសន្ននោះ ថាតើលោកអាចបង្ហាញអំពីហេតុផលទាំងឡាយនៃភាពពាក់ព័ន្ធនៃឯកសារនេះទៅនឹងអង្គហេតុដែលកំពុងតែធ្វើសវនាការហ្នឹងយ៉ាងម៉េច? ហើយសូមអញ្ជើញ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមានសំណើមួយពីខាងលោក ខាន ដែលជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ ដែលខ្ញុំយល់ថា គាត់មានភារកិច្ចផ្សេងទៀតនៅព្រឹកនេះ ហើយគាត់ចង់សុំនិយាយឲ្យបានមុនទាក់ទងទៅនឹងបញ្ហានេះ ហើយខាងសហព្រះរាជអាជ្ញាអត់មានបញ្ហាជំទាស់ទេក្នុងការដែលឲ្យគាត់និយាយមុននោះ ។

[០៩:២៩:៣២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ។

**លោក ការីម ខាន៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំថ្លែងអំណរគុណចំពោះសណ្ដានចិត្តរបស់លោកស្រី។ អ៊ីចឹងតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ ខ្ញុំសូមគាំទ្រដោយសស្រាក់សស្រាំនូវកំណត់សម្គាល់ដែលបានលើកឡើងដោយខាងមេធាវីការពារក្ដី ។ ពីព្រោះនេះជាចំណុចសំខាន់បំផុត ទាក់ទងទៅ

នឹងដំណើរការ ហើយនិងភាពស្របច្បាប់របស់តុលាការនេះ ពីព្រោះបញ្ហាបកប្រែ គឺមិនមែនជាសំណួរ ឬក៏ដែលថា អាចពឹងបាននោះ ។

ប៉ុន្តែ វាជាចំណុចគ្រោះថ្នាក់បំផុត បើសិនជាមានប៉ះពាល់ដល់នីតិវិធីនៃដំណើរការនេះ ។ ប្រសិនបើភាគណាមួយ គឺថាដើម្បីបង្កើតនូវចំណុចមួយ ដើម្បីឲ្យលោក លោកស្រីចៅក្រមធ្វើការពិនិត្យឲ្យបានសព្វគ្រប់ទៅលើការពិភាក្សាគ្នាទឡ្ហីករណ៍ផ្នែកច្បាប់នានាដែលបានលើកឡើង ។ ដូចអ្វីដែលលោក រូ បានលើកឡើងនោះគឺថាខ្ញុំយល់ថាជាការត្រឹមត្រូវណាស់ ហើយចាំបាច់បំផុត វាជាការសំខាន់ណាស់ទាក់ទងទៅនឹងនីតិវិធីនេះ ដើម្បីឲ្យខាងលោកចៅក្រមធ្វើការបង្គាប់ឲ្យអ្នកជំនាញឯករាជ្យណាមួយពិភាក្សាឡើងវិញ ឬក៏ពិនិត្យមើលឡើងវិញនូវសំណាកនៃការបកប្រែចាប់តាំងពីដំណើរសវនាការបឋមមកនោះ ។

[០៩:៣១:១៦]

ហើយបញ្ហាបកប្រែ នៅពេលដែលយើងមានស្ថិតិ ឬក៏ពិនិត្យមើលទៅលើការបកប្រែនេះ ដូចថាយើងអាចពឹងបាន ឬក៏មិនបាននោះ ហើយដែលធ្វើការវាយតម្លៃបានត្រឹមត្រូវបាននោះ ថាតើមានបញ្ហានៃការបកប្រែឬក៏អត់? ហើយបើសិនជាមាននោះ តើបញ្ហានោះវាមានទំហំប៉ុន្មាន? ហើយតើយើងអាចធ្វើអ្វីដើម្បីដោះស្រាយបញ្ហានោះបាន? ហើយបើសិនជាវា-- ចំណុចនេះជាចំណុចសំខាន់ណាស់នៅពេលនេះ ដើម្បីឲ្យយើងធ្វើការពិភាក្សាដោះស្រាយនៅពេលនេះ ហើយកុំទុកវាឲ្យរហូតដល់យឺតពេលនៅពេលក្រោយនោះ ។

លោកចៅក្រម ការលើកឡើងទីពីររបស់ខ្ញុំ គឺទាក់ទងទៅនឹងឯកសារតើទទួលយកបាន ឬក៏មិនបាននោះ? បើតាមការយល់ដឹងរបស់ខ្ញុំ ទាក់ទងទៅនឹងឯកសារ ២២៤១ ដល់ ២២៤៧ ដែលជាឯកសារជាភាសាខ្មែរនោះ ។ ភាសាខ្មែរគឺមាន ០០១៧២២០២ គឺជាឯកសាររបស់ ឈឿន សុទ្ធី ។ ខ្ញុំយល់ថាខាងមេធាវីក្តីហ្នឹងក៏អត់មានជំទាស់ទៅលើឯកសារនេះទេ ។

ដូច្នេះ ខ្ញុំមិនចង់ធ្វើការ គ្រាន់តែចង្អុលបង្ហាញទៅលើឯកសារនេះទេ ។ ការលើកឡើងរបស់ខ្ញុំគឺពឹងទៅលើគោលការណ៍មួយ បើសិនជាខ្ញុំយល់ដឹងច្បាស់នោះ ដូចអ្វីដែលខាងមេធាវីការពារក្តីបានលើកឡើងកាលពីម្សិលមិញ គឺថា ការលើកឡើងនូវទឡ្ហីករណ៍ដែលថា ឯកសារណាក៏ដោយ ដែលមាននៅក្នុងសំណុំរឿង ដែលមិនបានបង្ហាញដោយខាងសហចៅក្រមស៊ើបអង្កេតឲ្យដល់សាក្សីបានមើលនោះ គឺថា គួរតែចាត់ទុកថា ឯកសារនោះមិនអាចទទួលយកបាន ។

[០៩:៣៣:០៥]

អ៊ីចឹងបើសិនជាខ្ញុំបានយល់ដឹងទឡ្ហីករណ៍ដែលខាងមេធាវីការពារក្តីលើកឡើងនោះ អ៊ីចឹងនេះគឺជាការលើកឡើងមួយដែលមិនគួរទទួលយកបានទេ ។ ហើយខ្ញុំសូមស្នើឲ្យលោកចៅក្រមធ្វើការបដិសេធនូវសំណើរបស់មេធាវីការពារក្តីនេះ ដែលទាក់ទងនឹងថា វិធានថាតើយើងអាចទទួលឯកសារបាន ឬក៏មិនបាននោះ គឺមានលើកឡើងនៅក្នុងវិធាន៨៧ ។ ហើយវិធាន៨៧ ហ្នឹង គឺមានចែងច្បាស់ណាស់ថាតើចំណុចចាប់ផ្តើមជាទូទៅ គឺថាភស្តុតាងទាំងអស់គឺអាចទទួលយកបាន ។ នេះគឺជាប្រព័ន្ធស៊ីវិលឡ ដែលដែលប្រើនៅក្នុងប្រព័ន្ធប្រទេសកម្ពុជា ហើយអាចទទួលបានដោយជាលក្ខណបទដ្ឋានអន្តរជាតិ ។

អ៊ីចឹងអស់លោក លោកស្រី ជាចៅក្រមវិជ្ជាជីវៈ ហើយដែលអាចនលទ្ធភាពគ្រប់គ្រាន់ ដើម្បីធ្វើការវាយតម្លៃទៅលើភស្តុតាង ហើយនិងសម្រេចថាតើភស្តុតាងអ្វីដែលមានដាក់នៅចំពោះមុខលោកលោកស្រីចៅក្រមហ្នឹង ថាតើទទួលយកឯកសារណាខ្លះបាន?

អ៊ីចឹងគឺថា ត្រូវបានកម្រិតអប្បបរិមាណាមួយ ថាតើយើងអាចទទួលបានឯកសារត្រឹមកម្រិតណា? ប៉ុន្តែជាការច្បាស់លាស់ណាស់ទាក់ទងទៅនឹង *ខេសឡ* នោះ ទាក់ទងទៅនឹងសំណុំរឿង*អលរីច* នៅក្នុងមុខតុលាការយូហ្គោស្លាវី ខាងរដ្ឋអាជ្ញា *អាលរីច* ហ្នឹង ទាក់ទងទៅនឹងសំណុំរឿង IT០៣-០៨៣ សាលក្រមរបស់តុលាការដែលបានចេញថ្ងៃ៣០ ខែ៦ ឆ្នាំ២០០០ នៅក្នុងកថាខណ្ឌ ២៩ លោកចៅក្រមបានលើកបញ្ជាក់យ៉ាងច្បាស់ថា គឺថាមិនមែនចាំបាច់សម្រាប់ឯកសារមួយ ដើម្បីធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់ពីសាក្សី ដើម្បីទទួលយកបាននោះ ។

អ៊ីចឹងនៅពេលដែលវត្ថុតាងដែលបង្ហាញ ដែលមិនត្រូវបានបង្ហាញជូនដល់សាក្សីដែលមានតម្លៃមិនសមរម្យ ឬក៏មិនសមស្របនោះទេ គឺថាមិនអាចទទួលយកបានទេ ។ អ៊ីចឹងដូចថាលោកចៅក្រមបានយល់ដឹងហើយ នៅក្នុងដំណើរការនៃការទទួលយកឯកសារបាន ឬក៏មិនបាននោះ ។

ទីពីរ គឺក្នុងការកំណត់ថាតើ យើងទទួលយកបាននូវឯកសារនោះ ឬក៏មិនបាន ដោយអាស្រ័យទៅលើតម្លៃរបស់វា ។ អ៊ីចឹងជាទូទៅគឺថា ការទទួលយកបាន ឬក៏មិនបានហ្នឹង គឺថាយើងពិនិត្យមើលទៅលើទម្រង់នៃឯកសារ ថាតើវាមានបោះត្រានៅពីលើ ឬក៏បញ្ជាក់ពីភាពត្រឹមត្រូវរបស់គេ ឬក៏មានចុះថ្ងៃខែ ហើយនិង គឺទៅលើអត្ថន័យនៃឯកសារនោះ ។

[០៩:៣៥:៤៦]

អ៊ីចឹងចំណុចដែលខ្ញុំលើកឡើងវាគឺទាក់ទងទៅនឹងសំណុំរឿង-- ឯកសាររបស់ ឈឿន សុទ្ធី

ដែលខាងមេធាវីការពារក្តីក៏បានលើកឡើងដែរនោះ ។ អ៊ីចឹងគឺថា ឯកសារនេះគឺថាវាមានពាក់ព័ន្ធទៅនឹងអង្គហេតុទាំងនេះ ។ អ៊ីចឹងក្នុងករណី យើងមានស្ថាប័នណាមួយដែលឯករាជ្យ ហើយដែលអាចជឿទុកចិត្តបាន ឬក៏លោក លោកស្រីចៅក្រមបានឮពីភស្តុតាងនេះរួចទៅហើយនោះ គឺថាអាចបង្ហាញឱ្យបានច្បាស់លាស់បន្ថែមទៀតអំពីអត្ថន័យដែលមាននៅក្នុងរបាយការណ៍នេះ ដែលខាងសហព្រះរាជអាជ្ញាបានស្នើ ដើម្បីដាក់បញ្ចូលនោះ ។

អ៊ីចឹងទាក់ទងទៅនឹងបទកិច្ចសម្ភាសន៍ នៅពេលដែលបទសម្ភាសន៍មាននោះ ហើយសាក្សីមានវត្តមាននៅចំពោះមុខលោក លោកស្រីចៅក្រម គឺថាចំណុចចាប់ផ្តើមទីមួយ គឺថាតើយើងទទួលយក ឬក៏មិនទទួលយក? ហើយពេលហ្នឹងមេធាវីការពារក្តី បានឱ្យពិនិត្យទៅលើវិធាន៨៧ ហ្នឹង គឺថាគាត់អាចធ្វើការសួរ ថាតើឯកសារនោះ នឹងអាច ដូចថាមានសុពលភាព ឬក៏អត់ទេ?

អ៊ីចឹងនៅក្នុងករណីនេះ ថាតើបទសម្ភាសន៍ហ្នឹងត្រូវបានបង្ហាញជូនដល់សាក្សីឬទេ ថាគាត់ទទួលថា នេះជាគឺជាកិច្ចសម្ភាសន៍របស់គាត់ដែរឬទេ?

អ៊ីចឹង អ្វីដែលជាសេចក្តីបារម្ភរបស់ខ្ញុំគឺថា ការលើកឡើងដូចដែលខាងមេធាវីការពារក្តីបានលើកឡើង ហើយសំណុំរឿងដែលមាននៅក្នុងសំណុំរឿងនោះគឺថាមិនបានបង្ហាញ ដោយសហចៅក្រមស៊ើបអង្កេតឱ្យសាក្សីបានមើលទេ ឬក៏ក្នុងករណីនេះបើសិនជាគ្រាន់តែមិនបានបង្ហាញនោះ ត្រូវតែមិនយកមកដាក់បញ្ចូល ឬក៏មិនអាចមកបង្ហាញបាននៅក្នុងតុលាការឬក៏យ៉ាងម៉េចនោះ?

អ៊ីចឹងតាមខ្ញុំយល់ គឺខ្ញុំថានេះមិនមែនជាបន្ទុករបស់សហចៅក្រមស៊ើបអង្កេតទេ ដើម្បីធ្វើការបង្ហាញដល់សាក្សីនូវគ្រប់រាល់ឯកសារទាំងអស់នោះទេ ឬក៏គ្រប់រាល់ឯកសារដែលមាននៅក្នុងសំណុំរឿងនោះ ដើម្បីឱ្យឯកសារនោះទទួលយកបាននៅក្នុងសាលសវនាការ ។

អ៊ីចឹងគឺថា អ្វីដែលគាត់លើកឡើងថា ម្ចាស់ឯកសារនុ៎ងគឺថាមិនមែនជាអ្នកដែលថាមានលទ្ធភាពក្នុងការបញ្ជាក់ថា ឯកសារនោះជាឯកសារដើម ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ។

តំណាងអយ្យការ នៅតែទទូចសុំ ដើម្បីឱ្យអង្គជំនុំជម្រះលើកយករបាយការណ៍របស់ឈ្មោះ

ឈឿន សុទ្ធី មកពីចារណាឡើងវិញដដែល ដែលនៅក្នុងនោះមូលហេតុអ្វីបានជាតំណាងអយ្យការសុំឲ្យលើកយករបាយការណ៍នោះមកពិចារណាឡើងវិញ? ដែលក្នុងរបាយការណ៍ទាំងនោះ ពិតមែនតែជារបាយការណ៍ដែលការិយាល័យសហចៅក្រមស៊ើបអង្កេតពុំបានរកអត្តសញ្ញាណនូវជននោះឃើញវិញក៏ដោយ ក៏របាយការណ៍នោះវាមានការស៊ីសង្វាក់គ្នារវាងចម្លើយរបស់សាក្សី ដែលបានអញ្ជើញមកយកចម្លើយនៅពេលថ្មីៗនេះ ហើយនិងចម្លើយរបស់ជនត្រូវចោទដែលបានឆ្លើយនៅក្នុងអង្គសវនាការនេះដែរ។

[០៩:៣៩:២៤]

នៅក្នុងនោះដែរ របាយការណ៍នោះក៏បានបញ្ជាក់ថា នៅក្នុងអំឡុងពេលនោះវាមានមន្ទីរសន្តិសុខពីរ ដែលមួយនៅក្នុងគុក គេហៅថាមន្ទីរសន្តិសុខគុកស្ពាត ដែលជា ម-១៣ “ខ” វាស៊ីសង្វាក់ជាមួយនឹងចម្លើយរបស់សាក្សី និងជនត្រូវចោទ ហើយនិង ម-១៣ “ក” ដែលស្ថិតនៅអមលាំង ដែលគេហៅថា ម-១៣ “ក” នោះ ។ ហើយក្នុងនោះដែរក៏មានមនុស្សជាច្រើន ដែលពាក់ព័ន្ធនៅក្នុងរបាយការណ៍របស់ ឈឿន សុទ្ធី ដែលយើងត្រូវការសុំឲ្យជនត្រូវចោទហ្នឹងធ្វើការបញ្ជាក់ ហើយនិងឆ្លើយតបឡើងវិញ មានឈ្មោះ ថា ធើ ហើយក្នុងនោះដែរក៏មានអ្នកទោសលួចរត់ ហើយមានជាន់មីនជាដើម ។

លើសពីនោះទៀតដែរ ក៏នៅក្នុងរបាយការណ៍របស់ ឈឿន សុទ្ធី នោះ ក៏មានបញ្ជាក់ពីក្រោយព្រឹត្តិការណ៍នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដែលមានមនុស្សជាច្រើន នៅក្នុងនោះមាន តាធើ, វ៉ាន់ដែលជាក្មួយរបស់ តាធើ ហ្នឹង ហើយប៉ុន មាន អឿន មានហួត មានឈុំ ហើយដែលអាចសុំការឆ្លើយបញ្ជាក់ពីជនជាប់ចោទហ្នឹងដែរ ។

ក្នុងនោះដែរ របាយការណ៍របស់ ឈឿន សុទ្ធី នោះ ក៏មានបញ្ជាក់ថា គុក ទាំងពីរហ្នឹងមានមួយនៅនឹងភូមិបារី ខាងលិចវត្តត្រង់ ហើយនិងទីពីរ នៅជិតវត្តឈ្លូសសោមផងដែរ ។ ក្នុងនោះដែរក៏មាន-- របាយការណ៍នោះក៏មានបញ្ជាក់ពីហេតុផលមួយចំនួនដែលបានចាប់ឈ្មោះ ហឿន ដែលជាទាហានរបស់កងទ័ពជាតិនៅពេលនោះ ។ ហើយរបាយការណ៍នោះក៏វាមានការបញ្ជាក់ពីឈ្មោះរបស់គុកប្រធានគុក ម-១៣ “ខ” ឈ្មោះ តាស៊ុំ ។

[០៩:៤១:១៦]

លើសពីនោះទៀតដែរ នៅក្នុងរបាយការណ៍របស់ ឈឿន សុទ្ធី ហ្នឹង ក៏មានបញ្ជាក់អំពីមន្ទីរសន្តិសុខនៅអមលាំង ដែលមានឈ្មោះ ឌុច ដែលជាជនជាប់ចោទ ហើយនិងឈ្មោះ ចាន់ ដែលជាអនុប្រធានរបស់គាត់ ថាជាមនុស្សសាហាវព្រៃផ្សៃផងដែរ ។

បន្ថែមពីលើនោះទៅទៀត នៅក្នុងរបាយការណ៍របស់ ឈឿន សុទ្ធី ហ្នឹង ក៏មានបានបញ្ជាក់ថា ទីតាំងរបស់គុកស្តុត គុកនៅម-១៣ "ខ" ហ្នឹង ឈ្មោះមន្ទីរឃុំឃាំងនៅឃុំស្តុកស្រោត ដែលមាននៅមាត់ត្រពាំងខាងជើងភូមិស្តុកស្រោត ខាងក្រោម ហើយមានបញ្ជាក់ពីស្ថិតនៅលើអ្វី ហើយមានគុកនោះមានដំបូល ហើយមានទំហំប៉ុនណា ដែលខ្ញុំពេលនេះមិនលម្អិតជូនអង្គជំនុំជម្រះទេ ។ ហើយទុកជូនអង្គជំនុំជម្រះដើម្បីពិចារណាឡើងវិញ ទទួលយកឯកសារហ្នឹងជាផ្លូវច្បាប់ ។

ហើយមានបញ្ជាក់ថា ឈ្មោះ ស៊ុំ ហ្នឹង មានរាងរៅភិនភាគរបស់គាត់ហ្នឹងដូចម្តេចដែរ ។ ហើយមានការហូបចុក របបហូបចុកនៅក្នុងគុកទាំងពីរហ្នឹង ហើយក្នុងហ្នឹងដែរក៏មានបញ្ជាក់ពីឈ្មោះ ឈឿន សុទ្ធី ហ្នឹង ដែលគាត់បានជាប់ថាគាត់ហ្នឹងជាភ្នាក់របស់-- ជាភ្នាក់ងារយកការណ៍ ហើយដែលគាត់បានជាប់រហូតពីគុកនៅស្តុតស្រោត ដែលជាម-១៣"ខ" រហូតដល់គាត់បានចូលមកក្នុងគុក អមលាំង គុក ម-១៣"ក" ហ្នឹង ថែមទៀត ។

ហើយបញ្ជាក់ពីចំនួនមនុស្ស អ្នកដែលជាកងការពារនៅទីនោះ ហើយចំនួនអ្នកទោសនៅទីនោះ ។ ហើយនៅក្នុងគុក ម-១៣"ក" ក៏មានបានបញ្ជាក់ នៅក្នុងនោះក៏បានបញ្ជាក់ ដែលនៅក្នុងអង្គសវនាការនេះមិនទាន់បានសួរថា តើនៅក្នុងរណ្តៅ នៅក្នុងម-១៣"ក" នោះ មានរណ្តៅនោះ វាស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយរបស់សាក្សី និងចម្លើយរបស់ជនជាប់ចោទហ្នឹងផងដែរថា តើគុកនោះមានរាងដូចម្តេច? ហើយរបាយការណ៍នេះបញ្ជាក់ថា រណ្តៅនោះមានទំហំពីរម៉ែត្រ ទទឹងជម្រៅពីរម៉ែត្រ ហើយមានរាងជាស្អី ហើយមានបណ្តោយដប់ម៉ែត្រ ហើយមានរាងជាដូចអក្សរ "ក" អត់មានសក់ទៀត ។

ហើយកន្លងមកគឺថាអត់មានពិភាក្សាដេញដោល និងសួរពីភិនភាគនៃគុកដែលមានបីហ្នឹងទេ ថាតើមានរាងរៅដូចម្តេច? គ្រាន់តែយើងបានបញ្ជាក់ថាវានៅជិតគ្នា ។ ហើយរបាយការណ៍នោះគេមានគេសរសេរជា-- គេគូសជាអក្សរកហ្នឹងទៀត ។ ជាអក្សរកដើម្បីបង្ហាញហ្នឹងទៀត ។

ដូច្នេះវាអាចជាប្រយោជន៍មួយ ដើម្បីឲ្យជនជាប់ចោទហ្នឹងបញ្ជាក់ឲ្យបានច្បាស់លាស់ថែមទៀតនូវព័ត៌មានសំខាន់ៗទាំងនេះ ។

[០៩:៤៥:១៩]

ហើយចំពោះឯកសារនានាដែលពាក់ព័ន្ធនៅក្នុង ដែលដូចលោកមេធាវីរបស់ក្រុមការពារក្តីរបស់ជនត្រូវចោទបានលើកហ្នឹង ខ្ញុំនឹងទុកភារៈហ្នឹងជូនដល់ដៃគូរបស់ខ្ញុំ ដើម្បីធ្វើការឆ្លើយតបទៅជាមួយនឹងការលើកឡើងរបស់លោកមេធាវី រូ ។

អាស្រ័យហេតុនេះ តំណាងសហព្រះរាជអាជ្ញាជាតិនៅតែទទូចសុំឲ្យអង្គជំនុំជម្រះហ្នឹងធ្វើការពិចារណាឡើងវិញ ដើម្បីទទួលយកឯកសាររបស់ឈ្មោះ ឈឿន សុទ្ធី ហ្នឹង ទុកជាបានការតាមផ្លូវច្បាប់ ពីព្រោះជាព័ត៌មានមួយបន្ថុកនូវការផ្ទៀងផ្ទាត់គ្នា និងស៊ីសង្វាក់គ្នាយ៉ាងខ្លាំងរវាងសាក្សីនានា និងចម្លើយរបស់ជនជាប់ចោទ ហើយនិងការជជែកគ្នាពីប្រវត្តិរបស់គុកម-១៣ និងបង្ហាញពីប្រវត្តិនានាបន្ថែមទៀតរបស់ជនជាប់ចោទផងដែរ ។

ខ្ញុំសូមអរគុណ ខ្ញុំទុកភារៈនេះជូនលោកដៃគូរបស់ខ្ញុំបាទ ។

[០៩:៤៥:២៦]

**លោក អាឡិចសាន់ឌឺ ប៊េត៖**

អរគុណ លោកប្រធាន ។ ជាបឋម ខ្ញុំសូមលើកឡើងថា ការលើកឡើងរបស់មេធាវីការពារក្តីថារបាយការណ៍របស់ ឈឿន សុទ្ធី គឺមិនបានដាក់នៅចំពោះមុខជនជាប់ត្រូវចោទនៅពេលនោះ ជាពិសេសនៅក្នុងដំណាក់កាល់ស៊ើបអង្កេត ។ ដូច្នេះ របាយការណ៍នេះមិនគួរជាផ្នែកមួយនៃសំណុំរឿងទេ វាជារបាយការណ៍មិនពាក់ព័ន្ធហើយមិនផ្អែកទៅតាមមូលដ្ឋានវិធានផ្ទៃក្នុង ។ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺមានរបាយការណ៍នេះ ហើយវាមានរបាយការណ៍នេះនៅក្នុងដីកាដំណោះស្រាយ ហើយវាបានបញ្ចូលទៅក្នុងសំណុំរឿង ។ ហើយយើងបានពិភាក្សារបាយការណ៍នេះ នៅក្នុងដំណាក់កាលសាលសវនាការបឋមនៅចំពោះមុខភាគី ។ ហើយភាគី គឺមានសិទ្ធិក្នុងការយោងទៅរកឯកសារទាំងឡាយដែលមានដាក់ជូននៅក្នុងសវនាការនេះ ។

**លោក ហ្សង់ស្ទ័រ រូ៖**

លោកប្រធាន! ខ្ញុំសូមអភ័យទោស ចំពោះការលើកឡើងនៅពេលនេះ ។ គឺខ្ញុំនិយាយផ្ទុយពីហ្នឹងជាការពិតទៅ ខ្ញុំមិនបាននិយាយដូចអ៊ីចឹងទេ ។ ខ្ញុំបាននិយាយថា មេធាវីមិនឃើញមានបញ្ហាអ្វីទេ ក្នុងចំណោមឯកសារទាំងឡាយដែលមាននៅក្នុងសវនាការនេះ ។ ហើយខ្ញុំបាននិយាយថា ខ្ញុំមានការសោកស្តាយដែលលោកមិនបានធ្វើការងារទាំងនោះនៅចំពោះមុខចៅក្រមស៊ើបអង្កេត ហើយខ្ញុំមិនដឹងថាមានការបកប្រែយ៉ាងម៉េចនោះទេ ។

ហើយខ្ញុំគិតថា យើងមិនគួរធ្វើការជជែកគ្នាច្រើនទៅលើឯកសារនេះទេ ។ ហើយខាងមេធាវីការពារក្តីយល់ស្របក្នុងការបញ្ចូលឯកសាររបស់ ឈឿន សុទ្ធី នេះ ដោយយើងគិតថាដាក់ឯកសារដើមដើម្បីយកមកធ្វើការពិភាក្សា ។ ហើយប្រសិនបើមានការបកប្រែខុសនោះ ខ្ញុំសុំអភ័យទោស ។ ហើយនៅ

ពេលនេះ គឺយើងនិយាយអំពីបញ្ហាភាសាបកប្រែបារាំង និងភាសាអង់គ្លេស ។

[០៩:៤៨:00]

**លោក អាឡិចសាន់ឌឺ ប៊េត៖**

ប្រហែលជាខ្ញុំយល់ខុស សុំគោរពលោកប្រធាន ។ គឺមេធាវីការពារក្តីលើកឡើងថា ខាងមេធាវីការពារក្តីមានការសោកស្តាយដែលថា ខាងសហព្រះរាជអាជ្ញាមិនបានដាក់នៅចំពោះមុខសហព្រះរាជអាជ្ញា ។ គឺខ្ញុំសូមឲ្យខាងមេធាវីការពារក្តី ធ្វើការបំភ្លឺទៅលើការបដិសេធទៅលើឯកសារហ្នឹង ។

ខ្ញុំឃើញនៅក្នុងករណីនេះ វាមានបញ្ហាចំនួនពីរទាក់ទងទៅនឹងឯកសារហ្នឹង ។ បញ្ហាដែលបានលើកឡើង ដោយអង្គសវនាការ នៅក្នុងដីកាកំណត់កាលបរិច្ឆេទនៃសវនាការនៅខែមីនា គឺវាពាក់ព័ន្ធថាតើជនជាប់ចោទនឹងធ្វើការតតាំងទៅនឹងសេចក្តីថ្លែងការណ៍ទាំងឡាយដែលមិនទាន់បានធ្វើការដេញដោលឬយ៉ាង? ហើយបញ្ហាទីពីរ គឺវាទាក់ទងទៅនឹង ថាតើឯកសារជាច្រើននៅក្នុងរឿងក្តីនេះ គឺឯកសារដែលប្រមូលឡើងដោយអ្នកស៊ើបអង្កេត ។ ហើយថាតើយើងគួរពិភាក្សាទៅលើឯកសារនោះដែរឬទេ? វាជាការបង្គាប់របស់អង្គសវនាការ ហើយគឺឯកសារ *ឌីស៊ីខេម* ហើយគឺយើងឃើញថាមានបញ្ហាពីរនៅទីនេះ ។

មុនពេលដែលខ្ញុំ ធ្វើការពិភាក្សាទៅលើគោលការណ៍ផ្សេងៗទាំងអស់នេះ គឺខ្ញុំសូមអានឡើងវិញនៅក្នុងកថាខណ្ឌ៩.២ នៃសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង គឺឯកសារ E2600290321 គឺឯកសារនេះ គឺមិនបានតវ៉ា ដែលមានការលើកឡើងបញ្ជាក់នៅក្នុងឯកសារដែលថានឹងលើកឡើងនៅក្នុងកថាខណ្ឌទី៩.២ ហើយជនជាប់ចោទមិនបានធ្វើការតតាំងទៅនឹងឯកសារទាំងឡាយ ដែលមិនបានធ្វើការដេញដោល ។

ដូច្នេះ យើងសហព្រះរាជអាជ្ញា មិនមានការជំទាស់ទៅលើបញ្ហានេះទេ ។ ហើយវាងាយស្រួលក្នុងការយល់ទៅលើបញ្ហាន៎ុង ។ ហើយវាជាភស្តុតាងដែលភស្តុតាងកើតចេញពីសាក្សី ដែលគាត់នៅរស់នៅឡើយ ។ ហើយខ្ញុំនឹងបន្តអានទៅលើកថាខណ្ឌ៩.២ ។ ការលើកឡើងក្រៅពីឯកសារហ្នឹង គឺសាក្សីគាត់ស្លាប់ឬក៏គាត់មិនបានស្លាប់ដោយសារមូលហេតុណាមួយ គឺភាគីគាត់យល់ស្របទៅលើបញ្ហាហ្នឹង។

គឺចំពោះសហព្រះរាជអាជ្ញា-- អង្គជំនុំជម្រះសាលាដំបូងលើកឡើងថា លែងតែមានការលើកឡើងពីភាគីផ្សេងៗ គឺជនជាប់ចោទនិងមិនធ្វើការតតាំងចំពោះចម្លើយផ្សេងៗ ដែលយើងមិនបានស្តាប់នៅឡើយ ។ ហើយចំពោះបញ្ហានេះ នៅក្នុងដីកាកំណត់ថ្ងៃសវនាការនោះ គឺវាផ្ទុយពីវិធានផ្ទៃក្នុង ហើយ

ផ្ទុយទៅនឹងវិធីសាស្ត្រចំពោះការអនុវត្តភស្តុតាងនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ។

វិធាន៨១ គឺជាចំណុចផ្តើមអ្វីដែលយើងបានពិភាក្សានៅព្រឹកនេះ ។ លើកលែងតែមានបញ្ញត្តិចែងនៅក្នុងវិធានផ្ទៃក្នុង គឺភស្តុតាងគ្រប់ទាំងអស់ត្រូវទទួលយក។ នេះជាចំណុចនៃវិធានដែលយើងត្រូវពិនិត្យជាដំបូង។ ហើយចំណុចយោងនៅក្នុងវិធានផ្ទៃក្នុងចំពោះការដកចេញនូវភស្តុតាងនោះ គឺនៅក្នុងវិធានទី៨៣.២ ហើយគឺថាភស្តុតាងនោះ ហើយគឺវាមិនជាប់ពាក់ព័ន្ធការស្នើសុំជាន់គ្នាមិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុនៃការស្នើសុំពិនិត្យភស្តុតាង ឬក៏ច្បាប់មិនអនុញ្ញាត ។ ហើយនៅក្នុងវិធានមួយទៀតនោះ គឺវាមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះដែរ គឺវិធាន២១.៣ និង ២ គឺវាទាក់ទងទៅនឹងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ អ.វ.ត.ក ។ ហើយគឺឯកសារដែលថាមានការគំរាមគំហែងផ្សេងៗ មិនត្រូវទទួលយកមកធ្វើពិចារណានោះទេ ។

[០៩:៥៣:១៤]

ដូច្នេះ យើងមិនឃើញមានអញ្ញត្រកម្មណាមួយទាក់ទងទៅនឹងវិធានទូទៅ នៅក្នុងវិធាន៨៧.១ នោះទេ ទាក់ទងទៅនឹងការទទួលយកភស្តុតាង ។ ហើយមិនមានអញ្ញត្រកម្មណាមួយដែលពាក់ព័ន្ធនឹងច្បាប់ត្រូវមកអនុវត្តនៅក្នុងតុលាការនេះទេ ។ គឺសហព្រះរាជអាជ្ញាមានការព្រួយបារម្ភ និងចាប់អារម្មណ៍ថា សាលាដំបូងគឺគួរតែធ្វើការចេញសេចក្តីសម្រេចដោយផ្អែកទៅលើសេចក្តីបង្គាប់នៅក្នុងខែមីនា ។

ហើយយើងឃើញមានលក្ខខណ្ឌទាក់ទងទៅនឹងចម្លើយផ្សេងៗ ដែលទាក់ទងទៅនឹងសាក្សីដែលគាត់ស្តាប់ ឬក៏មិនទាន់បានស្តាប់ ហើយក្រៅពីនោះគឺភាគីអាចយកយល់ស្របទៅលើបញ្ហាហ្នឹង ។ ហើយខ្ញុំសូមទៅដល់ចំណុចទូទៅ គោលការណ៍ទូទៅ យើងគ្មានការបែងចែកនៅក្នុងវិធានផ្ទៃក្នុងរបស់យើងនោះទេ ទាក់ទងទៅនឹងចម្លើយរបស់សាក្សី និងប្រភេទនៃភស្តុតាងផ្សេងៗទៀត ។

ឯកសារទាំងអស់ ជាកម្មវត្ថុនៃវិធានចំពោះបញ្ហានៃការទទួលយកបាននៃភស្តុតាង ។ ហើយនិយាយតាមផ្លូវច្បាប់ យើងមិនឃើញមានភាពខុសគ្នា ចំពោះឯកសារផ្សេងៗដែលធ្វើឡើងនៅក្រៅរង្វង់នៃតុលាការនេះទេ ។ ហើយយើងមានឯកសាររាប់រយរាប់ពាន់ ដែលថាតុលាការនឹងយកមកធ្វើការដេញដោលនិងពិចារណានៅក្នុងសវនាការ ។ យើងឃើញមានដ្យាក្រាមរបស់យោធា របស់បក្ស របាយការណ៍របស់ប្រធានអង្គភាព ដែលបញ្ជូនអ្នកទោសទៅ ស-២១ កំណត់ហេតុផ្សេងៗរបស់អ្នកសួរចម្លើយ ។ ប្រសិនបើអង្គសាលាដំបូងនឹងលើកឡើងថា ឯកសារទាំងអស់នេះមិនអាចយកមកដេញដោល និងប្រើប្រាប់នោះទេ ដោយសារតែយើងមិនអាចរកអ្នកដែលគាត់រៀបចំឯកសារទាំងអស់នោះ ឬក៏មិនមានការ

យល់ស្របពីខាងមេធាវីការពារក្តី ។

ខ្ញុំសង្ឃឹមថា តុលាការនឹងយល់ឃើញអំពីភាពប៉ះពាល់និងផលប៉ះពាល់ ចំពោះការពិភាក្សាទាំងឡាយដែលកំពុងតែបន្ត ហើយវាជាបញ្ហាមួយដែលសំខាន់ណាស់ ។ ហើយមិនមានមូលដ្ឋានណាមួយនៅក្នុងវិធានផ្ទៃក្នុង ដែលថាគ្រប់ករណីដែរថា នៅពេលដែលអ្នករៀបចំឯកសារស្លាប់ ឬក៏មិនមានវត្តមានអីផ្សេងៗនោះ គឺមិនអាចទទួលយកបាន ។

យើងមានមូលហេតុត្រឹមត្រូវចំពោះបញ្ហាហ្នឹង ។ យើងនឹងដាក់អំណាចចំពោះការគ្រប់គ្រងនៃឯកសារ ហើយវាជាឯកសារដែលស្ថិតនៅក្នុងរបស់អង្គសាលាដំបូង ហើយមេធាវីការពារក្តីគឺគាត់ត្រឹមតែនិយាយថា គាត់មិនអាចយល់ស្របបានទេចំពោះឯកសារដែលបានរកឃើញទាំងអស់នោះ ។ ហើយវាអាចរារាំងសាលាដំបូងក្នុងការពិចារណាទៅលើឯកសារទាំងអស់នោះ។ នេះមិនមែនជាគោលបំណងដែលអង្គសាលាដំបូងនឹងធ្វើការដោះស្រាយទៅលើបញ្ហាភស្តុតាងទាំងអស់នោះទេ ។

[០៩:៥៦:៤៣]

សហព្រះរាជអាជ្ញា ទទូចអង្គសាលាដំបូងមិនអាចយកវិធានរបស់ច្បាប់ខំមិនឡ ចំពោះភស្តុតាងនោះទេ ប៉ុន្តែយើងឃើញថាមានលក្ខណៈដូចគ្នា ។ ជាមេធាវី ឬសហព្រះរាជអាជ្ញាមកពីប្រព័ន្ធខំមិនឡ កថាខណ្ឌ៩.២ គឺខ្ញុំយល់ទៅលើកថាខណ្ឌ៩.២ ។ គឺឯកសារដែលទទួលរកយកបានចំពោះបញ្ហាសាក្សីស្លាប់ឬក៏បញ្ហាភស្តុតាងដែលឮតាមគេនោះគឺវាស្រដៀងគ្នានឹងប្រព័ន្ធច្បាប់ខំមិនឡ ហើយយើងឃើញវាមានលក្ខណៈស្រដៀងគ្នាចំពោះបញ្ហាទាំងអស់នេះ ។ ប៉ុន្តែ មិនមានវិធានណាមួយរារាំង ចំពោះភស្តុតាងដែលជាពាក្យចចាមអារ៉ាមនោះទេ ។ ហើយចំណុចសំខាន់នោះ យើងមិនឃើញមានវិធាននៅក្នុងច្បាប់ជាតិ ឬក៏មិនឃើញមានវិធានណាមួយចែងនៅក្នុងផ្ទៃក្នុងទាក់ទងទៅនឹងបញ្ហានេះទេ ។

ហើយខ្ញុំសូមធ្វើការកែប្រែចំណុចមួយចំនួនដែលលោក ខាន បានលើកឡើង ។ គាត់បានលើកឡើងអំពីលក្ខខណ្ឌពីរក្នុងការទទួលយកភស្តុតាងនិងពិចារណាទៅលើភស្តុតាង នៅចំពោះមុខតុលាការមួយនេះ ។ គាត់បានលើកឡើងថា ជាដំបូងគឺបញ្ហានៃការទទួលយកភស្តុតាង ទីពីរគឺបញ្ហាទម្ងន់នៃភស្តុតាង ។ ចំពោះការលើកឡើងរបស់គាត់លក្ខខណ្ឌទាំងពីរនេះមិនមានទេ ហើយនៅពេលដែលយើងមានឯកសារនៅក្នុងសំណុំរឿងមិនមានការជំទាស់ណាមួយពីមេធាវីការពារក្តី គឺការជំទាស់ក្នុងការដកចេញពីសំណុំរឿងនោះ ដូច្នេះឯកសារទាំងអស់នោះគឺនឹងយកមកពីពិចារណា ។ ហើយបញ្ហានៅទីនេះ គឺទាក់ទងទៅនឹងទម្ងន់នៃភស្តុតាង នៅពេលដែលយើងមានឯកសារហើយ គឺឯកសារនោះគឺយើងមាន

នៅក្នុងដៃ បានន័យថាវាចូលនៅក្នុងសំណុំរឿងរួចហើយ ។

[០៩:៥៨:៥៥]

ខ្ញុំសូមលើកឡើងដោយសង្ខេបទាក់ទងទៅនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ជាពិសេសទាក់ទងចម្លើយរបស់មជ្ឈមណ្ឌលនេះ ។ ហើយប្រសិនបើសិនជាលើកឡើង ដូចជាមេធាវីការពារក្តីបានលើកឡើងនោះ ឯកសារចម្លើយរបស់ *ឌីស៊ីខេម* ទាំងអស់មិនអាចទទួលយកបានឡើយ ។ ដោយសារតែឯកសារទាំងអស់នោះធ្វើឡើង មិនធ្វើតាមទម្រង់នៃនីតិវិធី ដោយមិនធ្វើតាមលក្ខណៈចៅក្រមស៊ើបអង្កេត ដោយមិនមានការពិនិត្យទៅលើការសួរផ្សេងៗ ឬក៏មិនបានពិចារណាទៅលើការគុណភាពនៃការចម្លើយអីផ្សេងៗចំពោះឯកសារនោះ ។ មេធាវីការពារក្តីបានលើកឡើងថា ឯកសារទាំងអស់នេះមិនមែនជាឯកសារច្បាប់ ដូច្នេះហើយវាជាឯកសារដែលយើងមិនអាចយកមកប្រើប្រាប់បានទេ ។ ដូច្នេះ ខ្ញុំសង្ឃឹមថាលោក រូ គឺគាត់នឹងមិនលើកឡើងថាឯកសាររបស់ *ឌីស៊ីខេម* នោះ គួរតែដកចេញពី សំណុំរឿងនោះទេ ។ បានន័យថា យើងមិនអាចយកមកពិចារណា ហើយគាត់គួរតែនិយាយថា ឯកសារទាំងអស់នោះមិនមានទម្ងន់ ពីព្រោះវិធាន៧១នៃវិធានផ្ទៃក្នុងចែងអំពីបញ្ហាកំហុសនីតិវិធី ជាពិសេសនៅក្នុងបញ្ហាមោឃភាពនៃឯកសារ ដែលមាននៅក្នុងសំណុំរឿង ។ ហើយចំពោះមោឃភាពគួរតែធ្វើឡើងនៅក្នុងដំណាក់កាលស៊ើបអង្កេត ។ វិធាន៧៦ គឺមិនមានការសន្និដ្ឋានណាមួយពីខាងមេធាវីការពារក្តី ចំពោះបញ្ហានេះទេ ហើយមិនមានលើកឡើងចំពោះបញ្ហានៃឯកសាររបស់*ឌីស៊ីខេម* នោះទេ ។ ឯកសារ៧៦.៧ គឺជាដំណោះស្រាយកែតម្រូវកំហុសនៃការមិនគោរពវិធាន និងបញ្ញត្តិក្នុងការស៊ើបសួរ។ ដូច្នេះ ចម្លើយរបស់ *ឌីស៊ីខេម* គឺមាននៅក្នុងសំណុំរឿង គឺមេធាវីការពារក្តី ដូចដែលភាគីដទៃទៀតដែរ គឺគាត់គួរនិយាយថា ឯកសារទាំងអស់នោះមានទម្ងន់ ឬក៏មានទម្ងន់តិចតួច ដោយសារវាមិនមាន បញ្ហាធ្វើតាមនីតិវិធីច្បាប់ ដោយមិនមានអ្នកស៊ើបអង្កេត ឬក៏ដោយសារបញ្ហានៃការបកប្រែ។ ហើយមេធាវីការពារក្តីគឺគាត់មិនបានលើកទៅលើបញ្ហាទាំងអស់នោះទេ ។ ទោះបីជាអ្វីដែលលោក រូ បាន លើកឡើងក៏ដោយគឺថាគាត់មិនអាចធ្វើអ្វីខុសពីវិធានដែលមានចែងនៅក្នុងតុលាការយើងនេះទេ នៅពេលដែលឯកសារបានបង្ហាញនូវចំពោះសវនាការនេះហើយ គឺថាមិនអាចដកចេញបាននោះទេ ។

អ៊ីចឹងខ្ញុំសង្ឃឹមលោក រូ គឺគាត់មិនមាន-- ខ្ញុំថាខ្ញុំមិនយល់ច្រឡំពីអ្វីដែលលោក រូ បាននិយាយនោះទេ ។ លោកប្រធានឯកសារមួយចំនួនរបស់ *ឌីស៊ីខេម* អាចមានប្រយោជន៍សម្រាប់តុលាការនេះគឺលោកចៅក្រមអាចសម្គាល់បានទៅលើចំណុចអស់ទាំងនេះ ពីព្រោះអីនៅក្នុងឯកសារខ្លះហ្នឹង គឺមាន

ជាសំណួរនាំមុខ ហើយប្រហែលជាលោក លោកស្រីកត់សម្គាល់ឃើញផងដែលថា សំណួរខ្លះហ្នឹង គឺថាវាអត់ដូចមានពាក់ព័ន្ធទេ ។ ប៉ុន្តែ ឯកសារនេះមួយ គឺត្រូវធ្វើការវិនិច្ឆ័យពិចារណាទៅលើទម្ងន់ ឬក៏អត្ថន័យនៃឯកសារនីមួយៗនោះ ហើយគឺថាមិនមានអ្វីផ្សេងទៀត ដែលមិនមានចែងនៅក្នុងវិធាននេះ ដែលនិយាយថា ប្រភេទឯកសារមួយចំនួនអាចត្រូវធ្វើការសាកល្បងផ្សេងៗទៀត ដើម្បីនឹងទទួលយកបាននោះ ។ ទោះបីជាកំណត់ហេតុសួរចម្លើយដែលខាងសហចៅក្រមស៊ើបសួរបានធ្វើឡើងនោះ ក៏វាមានភាពផ្សេងៗគ្នាដែរ ទាក់ទងទៅភាពច្បាស់លាស់នៃកិច្ចសម្ភាសអស់ទាំងនោះ ។ អ៊ីចឹងខ្ញុំចង់លើកឡើងដែលថា ការលើកឡើងរបស់មេធាវីការពារក្តី ដែលថាត្រូវឲ្យទម្ងន់ទៅលើឯកសារណាមួយហ្នឹង ដើម្បីឲ្យលោក លោកស្រីចៅក្រមធ្វើការពិចារណានោះ គឺមិនមែនជាការទទួលយករកបានទេនៅក្នុងវិធានរបស់យើងនេះ ។

[១០:០៣:២៦]

បញ្ហានេះ គឺវាសាមញ្ញបំផុត ។ ឯកសារគឺអាចទទួលយកបាន ពីព្រោះមិនមានអ្វីមិនឲ្យឯកសារនោះមិនទទួលយកបានទេ ។ មិនមានតម្រូវការណាផ្សេងទៀត ទាក់ទងនៅក្នុងវិធានរបស់យើង ដែលថា ភាគីទាំងអស់ត្រូវព្រមព្រៀងគ្នានោះ ។ នេះ គឺថាទាក់ទងទាំងការសង្កេតការពិនិត្យមើលទាំងពីរទៅនឹងចម្លើយ ឬក៏សេចក្តីសម្ភាសសាក្សីពីមុនមកនោះ ។ ដើម្បីរកឃើញនូវចំណុចបែបនោះ នេះគឺជាចំណុចគ្រោះថ្នាក់មួយបំផុតសម្រាប់តុលាការនេះនៅក្នុងការកាត់ទោសនៅក្នុងសំណុំរឿង ដែលមាននៅចំពោះមុខលោកចៅក្រមនេះ ។ មានន័យថា បើសិនជាយើងធ្វើតាមនោះ គឺថាយើងត្រូវបង្កើននូវវិធានផ្សេងទៀត ដើម្បីទទួលយកនូវភស្តុតាង ហើយដើម្បីបង្កើនវិធាននោះ គឺថានេះមិនមែនជាសិទ្ធិអំណាចរបស់តុលាការ របស់អង្គសវនាការនេះទេ ។

អ៊ីចឹងបើសិនជា លោក លោកស្រីចៅក្រមបដិសេធអាស្រ័យទៅលើអង្គហេតុយ៉ាងសាមញ្ញបែបនេះ គឺថាជាចំណុចមួយគ្រោះថ្នាក់បំផុត ដូចជាសហសេវិករបស់ខ្ញុំ បានលើកឡើងពីភាពពាក់ព័ន្ធ និងអត្ថប្រយោជន៍នៃឯកសាររបស់ ឈឿន សុទ្ធី នោះ ។ ហើយខ្ញុំសង្ឃឹមថា ខ្ញុំក៏បានបង្កើតនូវគោលជំហររបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងឯកសារនានា ឬក៏កិច្ចសម្ភាសរបស់ *ឌីស៊ីខេម* ហើយបើសិនជាយើងត្រូវធ្វើការពិភាក្សាឯកសារលម្អិតនីមួយៗរបស់ *ឌីស៊ីខេម* ហើយត្រូវគិតទម្ងន់របស់ឯកសារនោះ គឺថាខាងសហព្រះរាជអាជ្ញាសប្បាយចិត្តនឹងធ្វើការពិភាក្សាទៅលើបញ្ហានេះ ដោយពិនិត្យលើឯកសារនីមួយៗ ។ បើសិននេះជាវិធីដែលលោក លោកស្រីចៅក្រមចង់ធ្វើនោះ ។

ខ្ញុំសូមទោសដែល ខ្ញុំស៊ីពេលច្រើនបន្តិចព្រឹកនេះ នៅពេលដែលខ្ញុំឡើងនិយាយ ពីព្រោះបញ្ហានេះជាបញ្ហាសំខាន់បំផុត ។ សូមអរគុណ ។

[១០:០៥:២០]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តមេធាវីក្រុម២ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម២ មានអ្វីចង់បញ្ចេញមតិយោបល់លោកបញ្ហានេះទេ? បើមានសូមអញ្ជើញ ។

**កញ្ញា ស៊ីលឃី ស្ទួតហ្វ៊ីនស្ពី៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំសូមលើកឡើងនូវបញ្ហាមួយចំនួនដូចខាងក្រោមនេះ ទាក់ទងទៅនឹងបញ្ហាដែលបានលើកឡើងនៅព្រឹកនេះ ។

ជាដំបូង ពួកយើងខ្ញុំបានសម្គាល់ឃើញថានៅទីនេះ ហើយនឹងអ្វីដែលយើងបានឃើញកាលពីម្សិលមិញនៅក្នុងការពិភាក្សាគ្នា ថាតើយើងអាចពិនិត្យលើកឯកសារដែលមាន ឯកសារមួយដែលមាននៅក្នុងសំណុំរឿងរួចហើយ ហើយទាក់ទងទៅនឹងច្បាប់ ខំមិនឡូ ហើយនឹងច្បាប់ស៊ីលវិលឡូ ។ ដើម្បីធ្វើជាការបញ្ជាក់នោះ គឺថាយើងនៅក្នុងដំណើរការនីតិវិធីស៊ីវិលឡូនៅពេលនេះ ។ ដូច្នេះ ហើយអ៊ីចឹងនេះជាចំណុចសំខាន់បំផុតដែលខាងអង្គសវនាការត្រូវធ្វើសេចក្ដីសម្រេចដោយអនុលោមទៅតាមស៊ីវិលឡូទូទៅ នីតិវិធីរបស់ស៊ីវិលឡូ ហើយដោយមិនធ្វើពិចារណាករណី តាមករណីនីមួយៗ ឬក៏ធ្វើការសាកល្បងទៅលើ គ្រប់ឯកសារនីមួយៗនោះ ដើម្បីពិនិត្យមើលថាតើគួរទទួល ឬក៏មិនទទួលយកនូវឯកសារនោះ ។

អ៊ីចឹងជាដំបូង ខ្ញុំសូមលើកឡើងថា នៅសេចក្ដីថ្លែងការណ៍ ឬក៏កិច្ចសម្ភាសរបស់ខាង-- សេចក្ដីថ្លែងការណ៍ដែលបានលើកឡើងរបស់ខាងសហព្រះរាជអាជ្ញា ខ្ញុំសូមប្រាប់ថាគាំទ្រ ។ ហើយខ្ញុំមិនចង់និយាយឡើងវិញនូវទឡ្ហីករណ៍អស់ទាំងនេះទេ ដោយថាយើងបានឯកសារទាំងស្រុងរួចមកហើយនោះរួមបញ្ចូលទាំងការលើកឡើងនូវភាពមិនស៊ីចង្វាក់គ្នានៃសេចក្ដីសម្រេចចិត្តនៅក្នុងឯកសារ E២៦ នៅក្នុងកថាខណ្ឌ ហើយនិងកថាខណ្ឌ ៩.២ ទាក់ទងទៅនឹងវិធាន រួមបញ្ចូលទាំងសេចក្ដីថ្លែងការណ៍ផងដែរ ឬក៏ការលើកឡើងរបស់លោក ខាន ទាក់ទងទៅនឹងដំណាក់កាលពីរ ដែលយើងត្រូវលើកឡើង នោះហើយខ្ញុំក៏មិនឯកភាពទៅនឹងនូវអ្វីដែលគាត់លើកឡើងនោះដែរ ។

ខ្ញុំចង់បន្ថែមថា ខ្ញុំចង់បន្ថែមនូវចំណុចមួយទៀតទាក់ទងទៅនឹងវិធាន៨៧ ដែលអាចនឹងណែនាំ

ដល់ដំណើរការនីតិវិធីនៅចំពោះយើងនេះ ហើយដែលយើងវាស៊ីគ្នាជាមួយនឹងក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា ស្ថិតនៅត្រង់វិធាន៨៧.២ ដែលខ្ញុំអាចនឹងអានឲ្យលោក លោកស្រីចៅក្រមស្តាប់៖

សេចក្តីសម្រេចចិត្តអង្គជំនុំជម្រះសាលដំបូងត្រូវផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខ។ នេះជាចំណុចទី១ ហើយចំណុចទី២ គឺភស្តុតាងនោះ ត្រូវបានដាក់នៅចំពោះអង្គជំនុំជម្រះសាលាដំបូងហើយ ហើយបន្ទាប់មកទៀត គឺថាភស្តុតាងនោះត្រូវឆ្លងកាត់ការដេញដោល។ នេះជាវិធានដែលមានចែង ដែលធ្វើការបញ្ជាក់យ៉ាងច្បាស់ថាសេចក្តីសម្រេចចុងក្រោយត្រូវអាស្រ័យទៅលើធាតុផ្សំអស់ទាំងនេះ ។ អ៊ីចឹងបើសិនជាយើងពិនិត្យមើលទៅលើចំណុចអស់ទាំងហ្នឹង ហើយនឹងធ្វើការសាកល្បងទៅលើចំណុចអស់ទាំងនេះ ទាក់ទងទៅនឹងសេចក្តី ឬក៏ចម្លើយ ឬក៏សេចក្តីសម្ភាសរបស់សាក្សី ដែលមានរួចហើយនៅក្នុងសំណុំរឿង ។ នេះមានន័យថា គឺឯកសារអស់ទាំងហ្នឹងអាចយកមកប្រើប្រាស់បាន ។ នេះគឺជាផ្នែកមួយនៃភស្តុតាង ពិតណាស់ ហើយគឺជាឯកសារដែលជាភស្តុតាង ។ ហើយបើសិនជាឯកសារហ្នឹងត្រូវគេយកមកបង្ហាញមុខនៅចំពោះមុខអង្គជំនុំជម្រះ ហើយអាស្រ័យ ហើយត្រូវតែយកមកពិនិត្យជាមុនសិននោះ អ៊ីចឹងសេចក្តីសម្រេចចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូង គឺអាចអាស្រ័យទៅលើ ទៅលើសេចក្តី ថ្លែងការណ៍អស់ទាំងហ្នឹង ដែលជាផ្នែកមួយរបស់សំណុំរឿង ហើយគឺជាឯកសារតែម្តង ។

អ៊ីចឹងគឺថា ឯកសារអស់ទាំងហ្នឹង គឺថាអាចលើកលែងបាន លើកលែងមិនយកមកពិចារណាបាន គឺទាក់ទងទៅនឹងចំណុច វិធាន៨៧.៣ ដែលខ្ញុំមិនចង់លើកឡើងមកទៀតទេ ព្រោះខាងសហព្រះរាជអាជ្ញា គាត់បានលើកឡើងរួចមកហើយ ។ ជាការពិតណាស់ ឯកសារបែបនេះ ដែលដូចជាឯកសារភាគច្រើន ដូចជាឯកសាររបស់ *ឌីស៊ីខេម* គឺថាសាក្សីអស់ទាំងហ្នឹងត្រូវបានគេសម្ភាស ហើយបន្ទាប់មកគឺថាមានរបាយការណ៍ដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ហើយប្រសិនបើសាក្សី បើសាក្សីដែលទាក់ទងទៅនឹងឯកសារអស់ទាំងហ្នឹង អ៊ីចឹងអាទិភាពនោះ គឺទីមួយ អាស្រ័យទៅលើសាក្សី ដែលជាចំណុចទីមួយ បើសិនជាសាក្សីហ្នឹងអាចមាន ។ បើសិនមិនអាចរកសាក្សីនោះបាន ឯកសារនោះគឺដូចជាឯកសារនានាដទៃទៀតដែរ ហើយអាចគួរតែយកមកពិចារណា ដោយអង្គជំនុំជម្រះសាលាដំបូង។ អ៊ីចឹងការពិចារណាទៅលើលក្ខណៈនៃភស្តុតាងអស់ទាំងហ្នឹង គឺត្រូវសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងខ្លួនឯងផ្ទាល់ ហើយខ្ញុំគិតថាបន្ទាប់មក គឺមានសំណួរនៅចុងក្រោយ ថាតើអំពីតួនាទីរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីពិចារណាទៅលើភស្តុតាងទាំងនោះ ហើយនិងដើម្បីពិនិត្យថ្លឹងថ្លែង ថាតើ--

ឧទាហរណ៍៖ ឯកសារនុ៎ង វាមានសេចក្តីសម្អាស ឬក៏សេចក្តីថ្លែងការណ៍ដែលគួរឲ្យជឿជាក់បាន ដែលមានភាពស៊ីចង្វាក់ ដែលវាស៊ីចង្វាក់នៅក្នុងឯកសារនុ៎ងហើយ ហើយវាស៊ីចង្វាក់គ្នាជាមួយឯកសារ នានាដទៃទៀត ហើយអ៊ីចឹងហ្នឹងគឺជាភារកិច្ចដែលអង្គជំនុំជម្រះសាលាដំបូងត្រូវមាន ដើម្បីធ្វើការពិចារណាសេចក្តីថ្លែងការណ៍របស់សាក្សី ដែលបានផ្តល់ផ្ទាល់មាត់នៅក្នុងសាលសវនាការ ។

[១០:១៣:៥៥]

ដូច្នេះហើយ អ៊ីចឹងនៅចុងបញ្ចប់ គឺអាស្រ័យទៅលើអង្គជំនុំជម្រះសាលាដំបូងដើម្បីពិចារណាថាតើវិធីណា ឬក៏ដើម្បីនឹងសម្រេចថាក្នុងការប្រើប្រាស់ឯកសារនោះ ។ ហើយបើសិនជាភស្តុតាងនុ៎ងត្រូវបានលើកលែងមិនឲ្យយកមកប្រើប្រាស់ក្រោមវិធាន៨៧.៣នោះ ទើបពេលហ្នឹងឯងអង្គជំនុំជម្រះសលាដំបូងមិនចាំបាច់យកមកពិចារណាទេ ។ នេះគឺវាស៊ីចង្វាក់ ហើយខ្ញុំសូមលើកឡើងមកវិញ គឺថាយើងនៅក្នុងតុលាការមួយដែលមានការលាយចូលគ្នានូវខេមមិនឡូ ហើយនិងមានមន្ត្រី ឬក៏ចៅក្រមមេធាវីមកពីស៊ីវិលឡូ ។

បើអ៊ីចឹង ខ្ញុំសូមស្នើទទូចឲ្យលោក លោកស្រីចៅក្រមធ្វើតាមវិធីសាស្ត្ររបស់ស៊ីវិលឡូ របស់ច្បាប់ស៊ីវិលឡូហ្នឹង ។ ហើយខ្ញុំសូមបន្ថែមទៀតថា ពីព្រោះគឺថា យើងមានការប្រឈមមុខនឹង បញ្ហាជាច្រើនទាក់ទងនឹងការបកប្រែ ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង គួរតែធ្វើការពិចារណានូវឯកសារដើមនៅក្នុងសាលសវនាការនេះ ។ ដូចដែលយើងបានឃើញនូវសេចក្តីថ្លែងការណ៍ ឧទាហរណ៍របស់ ហាម អ៊ីន ជាដើម ។ ពីព្រោះអី គឺថាមានការមិនស៊ីចង្វាក់គ្នាជាច្រើនរវាងច្បាស់ជា ភាសាបារាំង និងច្បាប់ជាភាសាអង់គ្លេស ។ ដូច្នេះ នៅក្នុងសាសសវនាការនេះ គឺខ្ញុំសូមស្នើឲ្យលោក លោកស្រីចៅក្រមហ្នឹងពិចារណាទៅលើឯកសារដើម ដែលជាភាគច្រើន គឺទាក់ទងទៅនឹងឯកសាររបស់ *ឌីស៊ីខេម* ។ ហើយដូចដែលខ្ញុំយល់ គឺថាតុលាការយើងនេះអាចធ្វើការពិចារណា បានហើយនឹងពិនិត្យមើលថាតើប្រតិចារឹកហ្នឹងត្រឹមត្រូវ ឬក៏មិនត្រឹម?

អ៊ីចឹងជាសរុបមក ទាក់ទងទៅនឹងចំណុចនេះ ខ្ញុំមិនទាន់ចង់លើកពីបញ្ហានៃការបកប្រែនៅ ឡើយទេ ។ ភស្តុតាងទាំងអស់ដែលមាននៅក្នុងសំណុំរឿងអាចប្រើប្រាស់បាន ។ ហើយវិធាននេះ ដែល ខ្ញុំបានលើកឡើងនេះគួរតែជាវិធានដែលលោក លោកស្រីចៅក្រមអាចយកមកពិចារណាបាន ហើយក៏វាស៊ីចង្វាក់គ្នាទៅនឹងច្បាប់របស់កម្ពុជាផងដែរ ។ ទាក់ទងទៅនឹងវិធាន ហើយនឹងនីតិវិធីដំណើរការនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីក្រុមបី បើមានសូមអញ្ជើញ ។

[១០:១៧:២៤]

**លោក ហ្វីលីព កាណុន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមចង់ធ្វើការកំណត់សម្គាល់ចំនួនពីរ ។ ទីមួយទាក់ទងទៅនឹងការបកប្រែ ។ ខ្ញុំគាំទ្រពេញលេញទៅលើសំណើរបស់លោក ហ្វ្រង់ស្វ័រ រូ គឺថាយើងជាមេធាវី នៅក្នុងសាលសវនាការនេះ គឺថាយើងចង់ធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីការពិត អ្វីទៅដែលជាការពិត? ហើយផ្នែកខ្លះនៃដំណើរការរបស់ការកាត់ទោសនេះនឹងត្រូវបានកំណត់ ឬក៏សម្រេចដោយអាស្រ័យទៅលើសេចក្តីថ្លែងការណ៍ ដែលគេបានធ្វើនៅក្នុងសាលសវនាការនេះ ។ ដូច្នេះ ជាការចាំបាច់ណាស់យើងត្រូវមានការយល់ដឹងពិតប្រាកដត្រឹមត្រូវ ហើយជាការសំខាន់ណាស់ដើម្បីពិនិត្យមើលអំពីភាពត្រឹមត្រូវនៃឯកសារអស់ទាំងនេះ ឬសេចក្តីថ្លែងការណ៍ទាំងនេះ ។ ហើយការសម្រេចចុងក្រោយបំផុតនេះគឺអាស្រ័យទៅលើអ្វីដែលបានធ្វើនេះ ។ អ៊ីចឹងមានន័យថា ដើម្បីធ្វើឲ្យវាមានភាពត្រឹមត្រូវនោះ គឺជាការចាំបាច់ដើម្បីឲ្យការបកប្រែហ្នឹង ក៏ជាការបកប្រែងត្រឹមត្រូវដោយសុចរិតផងដែរ ។ អ៊ីចឹងជាថ្មីម្តងទៀត ខ្ញុំគាំទ្រយ៉ាងពេញលេញទៅលើសំណើរបស់មេធាវីការពារក្តី ។

នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូ គេនិយាយថា នៅពេលដែលយើងសួរសាក្សី ឲ្យសាក្សីធ្វើការស្បថស្បែនោះ គឺថាគាត់ត្រូវតែសន្យាថានិយាយតែការពិត គឺតែការពិតតែមួយមុខគត់ ។ គឺការពិតទាំងស្រុង ។ អ៊ីចឹង ខ្ញុំបារម្ភថាការពិតខ្លះហ្នឹង គឺបានគេចវេសពីយើងនៅក្នុងនីតិវិធីនេះ ពីព្រោះមកពីយើងមិនបានយល់អ្វីដែលបាននិយាយ ។ នេះគឺជាការកត់សម្គាល់ឃើញទីមួយរបស់ខ្ញុំ ។ ការកត់សម្គាល់ទីពីររបស់ខ្ញុំ ទាក់ទងទៅនឹងការដាក់បង្ហាញឯកសារនៅចំពោះមុខសាលសវនាការ ។ ដំណើរការនីតិវិធី ឬក៏ការកាត់ក្តីនេះ គឺមានលក្ខណៈពិសេស ដោយមានការស៊ើបអង្កេត ដំណាក់កាលស៊ើបអង្កេត ហើយនិងការដាក់បញ្ចូលនូវឯកសារជាច្រើនដែលបានប្រមូល ។

[១០:២០:០៥]

ខ្ញុំចង់និយាយទាក់ទងទៅនឹងការយល់ដឹងធម្មតា ដោយមិននិយាយផ្អែកទៅលើផ្អែកច្បាប់ទេ ។ អ៊ីចឹងទៅតាមការយល់ធម្មតានោះ គោលបំណងនៃនីតិវិធីរបស់យើង គឺដើម្បីធ្វើការប្រៀបធៀប ដើម្បីធ្វើការដេញដោល ប្រឈមមុខនូវឯកសារទាំងអស់ នូវព័ត៌មានទាំងអស់ដែលមាននៅក្នុងសេចក្តីថ្លែង-

ការណ៍ដែលបានធ្វើនៅទីនេះ ឬក៏នូវសក្ខីកម្មដែលសាក្សីបានផ្តល់ឲ្យនៅទីនេះ ។ នេះគឺជាគោលបំណង នៃនីតិវិធីគឺធ្វើការដេញដោលនូវព័ត៌មានទាំងអស់ ។ អ៊ីចឹងហើយបាទ, លោកប្រធាន កាលពីម្សិលមិញ គឺខ្ញុំសូមស្នើដោយម៉ឺងម៉ាត់ថា សូមឲ្យអង្គសាលសវនាការបង្គាប់ប្រាប់ពួកយើងនូវ តើវិធីសាស្ត្រណា ដែលអង្គសវនាការនឹងសម្រេចយកនោះ ដើម្បីបានដឹងច្បាស់លាស់អំពីប្រភេទឯកសារ ។ តើឯកសារ អាចទទួលយកបានឬមិនបាន? អ៊ីចឹង ខ្ញុំសង្ឃឹមថា សេចក្តីសម្រេចចិត្តរបស់លោក លោកស្រីនឹងអាចធ្វើ ទៅបានទាក់ទងទៅនឹងប្រតិបត្តិការនៃដំណើរការនីតិវិធីនេះ ។

ឥឡូវនេះ ខ្ញុំសូមពិនិត្យទៅលើបញ្ហាច្បាប់ ។ ខ្ញុំចង់ឲ្យលោកពិនិត្យមើលវិធាន៨៧.២ និងវិធាន ៨៦.៧ ហើយខ្ញុំនឹងអានជូន៖ នៅដំណាក់កាលណាមួយនៃដំណាក់ស៊ើបអង្កេត ប្រសិនបើភាគីណាមួយ ចាត់ទុកថា ឯកសារណាមួយគឺថាមិនអាចយកមកប្រើប្រាស់បានទេនោះ គឺថាត្រូវផ្តល់នូវការលើកឡើង ដោយមានហេតុផលជាក់លាក់មកដល់ខាងសហចៅក្រមស៊ើបអង្កេត ស្នើឲ្យពួកគាត់ធ្វើការលើកឡើង បញ្ហានេះជាមួយនឹងអង្គបុរេជំនុំជម្រះដើម្បីពិចារណាទៅលើចំណុចនេះ ។ លើកលែងតែខ្ញុំច្រឡំ ខ្ញុំយល់ ថាដំណើរការនីតិវិធី គឺថាមិនដែលបានធ្វើទេ ។ បើអ៊ីចឹង ឥឡូវនេះ ខ្ញុំចង់ពិនិត្យមើលវិធាន៨៦.៧--

[១០:២២:៣៤]

ដីកាដំណោះស្រាយត្រូវតែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ ។ គ្មាន បញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះអាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ សាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ ។

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! ខ្ញុំសូមលើកឡើងថា នេះមិនមែនជាការ ពិភាក្សាដេញដោលជាក់លាក់ចំពោះបញ្ហានេះទេ បញ្ហានេះយើងបានយល់ច្បាស់លាស់ហើយ។ ដូច្នេះខ្ញុំ ស្នើសុំអង្គសវនាការឲ្យរំលឹកដល់ភាគីទាំងអស់ ។ វិធានដែលខ្ញុំទើបតែបានអានអម្បាញ់មិញនេះ គឺវាជា វិធានមួយដែលយើងអាចមើលជាសាធារណៈ ហើយយើងអាចអនុវត្តតាមវាដើម្បីភាពអនុវត្តទៅងាយ ស្រួលនៅក្នុងនីតិវិធីរបស់យើង។ ដូច្នេះយើងបន្តអនុវត្តតាមវិធានរបស់យើងបន្តទៀត ។ អរគុណលោក ប្រធាន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីតំណាងឲ្យដើមបណ្តឹងនៃក្រុមប្អូន ។ បើមានសូមអញ្ជើញ ។

[១០:២៣:៥៨]

**លោក ហុង គីមសួន៖**

ខ្ញុំបាទសូមអរគុណលោកប្រធាន និងគោរពអង្គសវនាការម្តងទៀត ។ ខ្ញុំបាទមេធាវី ហុង គីមសួន នៅក្រុមទីបួនសូមធ្វើការកត់សម្គាល់ដូចតទៅនេះ ។ អម្បាញ់មិញនេះ ខ្ញុំបាទបានលើកឡើងរួច ហើយថាខ្ញុំបាទគាំទ្រនូវការលើកឡើងរបស់សហព្រះរាជអាជ្ញា ។ អ៊ីចឹងនៅក្នុងនេះ ខ្ញុំបាទក៏មិនខុសពីលោក លោកស្រីមេធាវីលើកមុនៗដែរ ដែលគាត់បានលើកឡើងទាក់ទងជាមួយនឹងការបង្ហាញភស្តុតាងជាឯកសារដែលកំពុងតែដេញដោលគ្នានេះ ។ ដូច្នេះ ទាក់ទងនឹងឯកសារដែលមានសាក្សីឈ្មោះ ឈឿន សុទ្ធី ហៅ សារិន នេះ លោកមេធាវីការពារលោកមិនបានជំទាស់ទេ បើតាមខ្ញុំស្តាប់បាន តាមការបកប្រែ ។ ប៉ុន្តែ ទាក់ទងទៅនឹងឯកសារដែលចេញ ឬផ្សព្វផ្សាយដោយអង្គការ *ឌីស៊ីខេម* ឬមជ្ឈមណ្ឌលស្រាវជ្រាវឯកសារស្វែងរកការពិត ។ ដូច្នេះ ក្នុងនេះការលើកឡើងរបស់មេធាវីមុនៗដែលគាត់លើកអំពីវិធាន៨៧ ស្តីពីវិធាននៃភស្តុតាង ។

នៅត្រង់ចំណុចទីពីរ និងចំណុចទីបី ដូចកញ្ញា ស្ទូតហ្វឺនស្គី បានលើកឡើងអម្បាញ់មិញ ខ្ញុំបាទសូមគាំទ្រទាំងស្រុង ។ ព្រោះថាឯកសារទាំងអស់នេះ ខ្ញុំបាទពិនិត្យទៅឃើញមានភាពទាក់ទងគ្នា ដែលស្របគ្នានឹងចំណុចទីបី វិធាន៨៧.៣ ហើយអនុវិធាន៨៧.៣(ក) ដែលនិយាយថា "បើសិនមិនពាក់ព័ន្ធគ្នាទើបអង្គសវនាការ ឬលោកប្រធានដឹកនាំអង្គសវនាការ នឹងធ្វើការសម្រេចបដិសេធចោល" ។ ហើយទីពីរទៀត ទាក់ទងជាមួយនឹងភាពមិនអាចរកបានក្នុងរយៈពេលសមស្របណាមួយនោះ ។ ប៉ុន្តែ ក្នុងនេះក្នុងការអនុវត្តតាមស៊ីវិលឡនោះ គឺរាល់ឯកសារទាំងអស់ដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនោះ ហើយនៅក្នុងវិធាននេះបានប្រើពាក្យថា "ភស្តុតាងដែលមាននៅក្នុង សំណុំរឿងត្រូវបានចាត់ទុកថា បានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ។ គេបានចែង យ៉ាងច្បាស់យ៉ាងដូច្នេះ ។

ហើយបើសិនជាទាក់ទងទៅនឹងជាមួយច្បាប់ជាតិរបស់ព្រះរាជាណាចក្រកម្ពុជា នៅក្នុងនីតិវិធីក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជា ចេញនៅខែកក្កដា ឆ្នាំ២០០៦ ត្រង់មាត្រា១៥៥ បានចែងអំពីភាពត្រឹមត្រូវក្នុងការធ្វើឯកសារ ទោះបីថានេះជារឿងព្រហ្មទណ្ឌ ក៏ប៉ុន្តែ នៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងមាត្រា១២ និយាយអំពីការបើមានភាពមិនច្បាស់លាស់ ឬមានន័យមិនត្រឹមត្រូវនោះ គឺយកច្បាប់ជាតិជាធំ ។ នេះជាអត្ថន័យដែលខ្ញុំបាទលើកឡើង ។

[១០:២៧:១៩]

អ៊ីចឹងមាត្រា១៥៥ បានចែងភាពត្រឹមត្រូវក្នុងការធ្វើឯកសារ ។ ខ្ញុំបាទសូមអនុញ្ញាតអានបន្តិច គឺវាមិនវែងពេកទេ ។ ទីមួយ ភាគីដែលបានស្នើសុំឲ្យពិនិត្យភស្តុតាងជាឯកសារ ត្រូវបញ្ជាក់ថា ឯកសារនោះត្រូវបានធ្វើឡើងដោយត្រឹមត្រូវ ។ ចំណុចទីពីរ បើទទួលស្គាល់ថា ឯកសារត្រូវបានធ្វើឡើងដោយមន្ត្រីរាជការនៅក្នុងមុខនាទី ដោយផ្អែកលើទម្រង់ និងខ្លឹមសារនៃឯកសារ នោះត្រូវសន្មតថាជាសាធារណៈដែលបានធ្វើឡើងដោយត្រឹមត្រូវ ។ ចំណុចទីបី បើមានមន្ទិលសង្ស័យទៅលើភាពត្រឹមត្រូវ ក្នុងការធ្វើឯកសារសាធារណៈ នោះតុលាការអាចសួរដោយឆន្ទានុសិទ្ធិទៅក្រសួង ឬស្ថាប័នដែលពាក់ព័ន្ធបាន ។ អ៊ីចឹងខ្ញុំសូមអានបីចំណុចនេះ ហើយខ្ញុំបាទក៏សូមប្រៀបធៀប និងកត់សម្គាល់ថា ទោះបីអង្គការ *ឌីស៊ីខេម* ដែលលោកមេធាវីការពារលើកឡើងថា មិនទាន់សន្មតថាជាអ្នកមានសមត្ថភាព ឬអ្នកដែលត្រូវបានទទួលស្គាល់ដោយស្ថាប័នតុលាការក៏ដោយ ក៏ប៉ុន្តែ ឯកសារទាំងអស់នេះមិនមែនតែប៉ុននេះទេ មានច្រើនរាប់ម៉ឺនរាប់សែនរាប់លានទំព័រទៅទៀត ដែលបានមកពីអង្គការ *ឌីស៊ីខេម* ដាក់ចូលមកក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ ។

[១០:២៩:១៧]

អ៊ីចឹង ខ្ញុំបាទសូមត្រឡប់ថយក្រោយវិញ អង្គការ *DC-Cam* នេះត្រូវបានទទួលស្គាល់ជាផ្លូវការដោយរាជរដ្ឋាភិបាលកម្ពុជា អនុញ្ញាតជាផ្លូវការឲ្យស្វែងរក ស្រាវជ្រាវរករាល់ឯកសារឬភស្តុតាងទាំងឡាយដែលទាក់ទងគ្នាទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានគ្រប់គ្រងប្រទេសកម្ពុជា ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ មកទាល់ថ្ងៃ៦ មករា ឆ្នាំ១៩៧៩ និងមានលើសពីហ្នឹងទៅទៀត ។

ខ្ញុំបាទសូមជម្រាបលោកប្រធានទៀតថា អង្គការនេះក៏ជាដៃគូដ៏សំខាន់បំផុតសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់ស្វែងរកការពិត ។ អ៊ីចឹងអ្វីដែលជាឯកសារដាក់ជូនមកទោះឯកសារមុនឆ្នាំ៧៥ ក៏ដោយ ឯកសារនៅក្នុងចន្លោះ៧៥ ដល់ ៧៩ ក៏ដោយ ឬក៏ក្រោយទៀតក៏ដោយ មិនមែនតែមានអង្គការ *ឌីស៊ីខេម* មួយទេដែលដាក់បញ្ចូលមក ។ ហើយត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទទួលដាក់បញ្ចូលទៅក្នុងសំណុំរឿងរួចហើយ ។ អ៊ីចឹង សំខាន់បំផុតគឺឆន្ទានុសិទ្ធិរបស់លោកប្រធានដែលដឹកនាំសវនាការទទួលយកបាន ឬមិនបាន? ហើយស៊ីចង្វាក់គ្នា ឬមិនស៊ីចង្វាក់គ្នា? ដែលលោកព្រះរាជអាជ្ញាជាតិបានលើកឡើងអម្បាញ់មិញនេះ ។

អ៊ីចឹងចុងបញ្ចប់នេះ ខ្ញុំបាទសូមកត់សម្គល់ថា ការលើកឡើងរបស់កញ្ញាមេធាវី ស៊ីលយីស្ទួត

ហ្សីនស្គី ខ្ញុំបាទសូមគាំទ្រទាំងស្រុង ហើយខាង លោកសហព្រះរាជអាជ្ញា ក៏ខ្ញុំបាទសូមគាំទ្រដោយនេះ យោងទៅតាមបទប្បញ្ញត្តិ ដែលមានចែងនៅក្នុងវិធាន៨៧ នៃវិធានផ្ទៃក្នុងនិងមាត្រា១៥៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ។

សូមឲ្យលោកប្រធានសម្រេចទទួលយកឯកសារដែលកំពុងតែដាក់នេះមកពិចារណា និងដេញដោលតទៅទៀត ។ សូមអរគុណ ។

[១០:៣១:១១]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីការពារក្តីមានអ្វីចង់លើកឡើងថែមទៀតដែរឬទេ?

**លោក ហ្រ្វង់ស្វ័រ រូ៖**

អរគុណលោកប្រធាន ។ មេធាវី គឺមិនមែនដកខ្លួនចេញពីការធ្វើសេចក្តីសន្និដ្ឋាន ឬក៏ដកខ្លួនចេញពីនីតិវិធីដែលកំពុងដំណើរការនេះទេ ។ ខ្ញុំសូមរំឭកលោក លោកស្រី ចៅក្រម អំពីគោលការណ៍ដែលប្រកាសដោយសាស្រ្តាចារ្យច្បាប់ដែលលោក លោកស្រីចៅក្រម ធ្លាប់ឮការដកស្រង់សម្តីនេះរួចហើយ គឺថា សត្រូវ គឺថានីតិវិធីគឺ “ទម្រង់គឺជាបងប្អូនភ្លោះនៃសេរីភាព” សម្តីដកស្រង់ ។ អ្វីដែលខ្ញុំលើកឡើងនៅទីនេះ យើងនិយាយអំពីវិធាន៧៦ នៃវិធានផ្ទៃក្នុងរបស់យើង ដែលចែងអំពីមោឃភាពនីតិវិធី គឺពាក្យសុំចំពោះមោឃភាពនីតិវិធី ហើយគឺថាតើយើងធ្វើយ៉ាងម៉េចទៅរួចចំពោះបញ្ហានេះ? គឺវាអាស្រ័យទៅលើភាគីក្នុងការស្នើសុំ ថាតើមោឃភាពនៅមុនដីកាដំណោះស្រាយនោះ គឺវាធ្វើយ៉ាងម៉េចដោយសារវាយឺតពេលទៅហើយ? ដូច្នេះខ្ញុំសូមអរគុណចំពោះការរំឭកចំពោះវិធាននេះ ។ ហើយខ្ញុំសូមអរគុណ ហើយខ្ញុំអ្វីដែលខ្ញុំកំពុងតែនិយាយចំពោះបញ្ហានេះ ថាតើឲ្យបុគ្គលណាម្នាក់អាចដាក់ជូនកិច្ចសម្ភាសន៍របស់ *ឌីស៊ីខេម* ដើម្បីដាក់ជូនចូលទៅក្នុងសំណុំរឿងយ៉ាងម៉េច? ខ្ញុំសូមរំឭកថា ថាតើធាតុផ្សំច្បាប់ យ៉ាងម៉េចនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល?

យើងអាចប្រើប្រាស់វចនានុក្រម ហើយអាចប្រើប្រាស់នឹងពិនិត្យ មើលនិយមន័យនៃធាតុផ្សំទាំងឡាយដែលអនុវត្តនៅក្នុងនីតិវិធី ។ គឺធាតុផ្សំដែលវាពាក់ព័ន្ធនៅក្នុងការវិវត្តន៍នៃដំណើរការនីតិវិធីក្នុងការស្វែងរកការពិត ។ នៅក្នុងធាតុផ្សំទាំងអស់នោះយើងអាចមានដីកាសន្និដ្ឋានបញ្ជូនរឿង ឬក៏ជាការស្នើសុំ ឬក៏សេចក្តីសន្និដ្ឋានរបស់ភាគី ឬក៏នៅក្នុងករណីមួយចំនួនគឺសេចក្តីសន្និដ្ឋានរបស់ក្រសួងផ្សេងៗ គឺមាននៅក្នុងនោះធាតុផ្សំទាំងអស់ក៏មានរបាយការណ៍អ្នកជំនាញ ឬក៏សេចក្តីសម្ភាស ឬក៏ចម្លើយផ្សេងៗ

របស់សាក្សី ។

[១០:៣៤:៥០]

ដូច្នេះ ប្រសិនបើខ្ញុំអនុវត្តតាមវិធាន៧៦ គឺវាចែងអំពីការស្នើសុំឲ្យពិនិត្យទៅមើលលើមោឃភាពនៃកំណត់ហេតុជាលាយលក្ខណ៍អក្សរ ។ ដូច្នេះ គឺមេធាវីយល់អំពីការស្នើសុំមោឃភាពចំពោះកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់តុលាការ គឺមេធាវី គឺមានចិត្តក្នុងការស្នើសុំទៅលើមោឃភាពនៃនីតិវិធី ឬចំពោះឯកសារផ្សេងៗដែលប្រមូលឡើងដោយចៅក្រមស៊ើបអង្កេត ឬក៏តាមរយៈដីកាស្នើសុំឲ្យស៊ើបសួរ ។ ដូច្នេះហើយ យើងមិនឃើញថា មានករណីណាមួយដែលអាចយកវិធាននេះយកមកដោះស្រាយចំពោះករណីដែលខ្ញុំបានលើកឡើង ។ ឯកសារដែលយើងបានលើកឡើងនៅទីនេះ គឺមិនមែនជាកំណត់ហេតុលាយលក្ខណ៍អក្សរនៃការសួរយកចម្លើយ ឬការសម្ភាសនោះទេ ។ ទោះបីជាវាមានលក្ខណៈស្រដៀងទៅនឹងកំណត់ហេតុលាយលក្ខណ៍អក្សរក៏ដោយ ។ កំណត់ហេតុលាយលក្ខណ៍អក្សរ គឺជាឯកសារផ្លូវការ ហើយឯកសារទាំងអស់នេះត្រូវបានប្រមូលឡើងដោយបុគ្គលដែលបានស្បថ ។ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូបានន័យថា គឺបុគ្គលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ចៅក្រមស៊ើបអង្កេត ។

ដូច្នេះ អរគុណចំពោះលោកសហព្រះរាជអាជ្ញា ដែលចុងក្រោយនេះ គឺបានលើកឡើងទៅលើបញ្ហាចំពោះឯកសារទាំងអស់នេះ ។ ហើយវានាំឲ្យខ្ញុំគិតទៅដល់ការរិះគន់ផ្សេងៗដែលបានលើកឡើងហើយនិងភាពសំខាន់ៗ ។ យើងទាំងអស់គ្នា លោកសហព្រះរាជអាជ្ញាក្នុងរយៈពេលមួយឆ្នាំកន្លះ នៃដំណាក់កាលស៊ើបអង្កេត ហើយយើងមានការសួរចម្លើយច្រើនជាង៣៤ដង ហើយយើងមានលទ្ធភាពក្នុងការផ្តល់ជូនចៅក្រមស៊ើបអង្កេតចំពោះឯកសារផ្សេងដែលយើងទាំងអស់គ្នាមានបំណងដាក់ចូលទៅក្នុងសំណុំរឿងឯកសារ ។

[១០:៣៧:៣៥]

ដូច្នេះ ជនជាប់ចោទអាចត្រូវបានសួរចម្លើយនៅក្នុងបរិបទនៃដំណាក់កាលស៊ើបអង្កេត ។ ហើយខ្ញុំបានស្នើសុំលោក លោកស្រី ច្រើនដងហើយឲ្យគោរពទៅលើនីតិវិធីទាំងអស់នេះ ហើយខ្ញុំបានធ្វើការជូនដំណឹងច្រើនដឹងហើយឲ្យមានការប្រុងប្រយ័ត្នទៅលើបញ្ហានេះ ។ អ្វីដែលយើងមិនបានធ្វើនៅក្នុងដំណាក់កាលស៊ើបអង្កេតគឺយើងមិនអាចអនុវត្ត ឬក៏មិនអាចធ្វើឡើងបន្ទាប់ពីដំណាក់កាលនោះទេ ។ ជាការពិតណាស់បញ្ហានេះគឺបានលើកឡើងដល់ជនជាប់ចោទដែលគាត់បដិសេធមិនឆ្លើយតបនៅក្នុងការឆ្លើយជូនសហចៅក្រមស៊ើបអង្កេត ។ ហើយវាមានលក្ខណៈយឺតយ៉ាវចំពោះករណីទាំងអស់នេះ ។ អ្វី

ដែលយើងលើកឡើងនិងដោះស្រាយនៅទីនេះ គឺវិធានមួយណា? គឺវិធាន៧៦ នៃស្តីពីបញ្ហាមោឃភាពនីតិវិធី ឬក៏យ៉ាងម៉េច? វិធានផ្ទៃក្នុងរបស់យើងគឺមានបញ្ចូល និងចែងអំពីបញ្ហាមួយចំនួនទាក់ទងទៅនឹងបញ្ហាភស្តុតាងឯកសារ ដែលសហព្រះរាជអាជ្ញាគាត់ចង់បញ្ចូលឯកសារ ចំនួនឯកសារនៅក្នុងនីតិវិធីរបស់យើង ។ ហើយនៅក្នុងបញ្ហាមោឃភាពនេះយើងឃើញថា មានឯកសារជាច្រើនបានបញ្ចូលនៅក្នុងសំណុំរឿង ។ ហើយខ្ញុំមានបំណងនៅក្នុងតុលាការនេះ គឺយើងអាចរៀបចំបញ្ហាទាំងអស់នេះឲ្យបានមុនពេលវេលាកំណត់ដើម្បីចំណាយពេល ដើម្បីជៀសវាងការចំណាយពេលរបស់យើងដូចជារយៈពេលពីរម៉ោងដោះស្រាយទៅលើបញ្ហានេះ ។ យើងមានជនរងគ្រោះ និងសាធារណជនដែលកំពុងរង់ចាំចំពោះបញ្ហានៃការស្តាប់អង្គហេតុស-២១ ហើយនៅពេលនេះយើងចំណាយពេលដោះស្រាយទៅលើបញ្ហាទាំងអស់នេះ ។

វិធាន៨៧.៣ នៅពេលអង្គជំនុំជម្រះសាលាដំបូងធ្វើសេចក្តីសម្រេចផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿងវាមានលក្ខណៈចែងច្បាស់លាស់ថា ធាតុផ្សំទាំងអស់បានបញ្ចូល ហើយឯកសារនោះបានបញ្ចូលទៅក្នុងសំណុំរឿង ហើយខ្លឹមសាររបស់វាត្រូវសង្ខេប ។ ខ្លឹមសារសង្ខេបត្រូវយកមកអាននិងភស្តុតាងដែលមាននៅក្នុងសំណុំរឿងត្រូវចាត់ទុកថាបានលើកឡើងនៅមុខអង្គជំនុំជម្រះសាលាដំបូង បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ឬត្រូវបានអានក្នុងសវនាការ ។ ខ្ញុំមិននិយាយអំពីបញ្ហាមោឃភាពនៅទីនេះទេ ។ ខ្លឹមសារនៅក្នុងវិធាននេះចែងច្បាស់ថា អង្គជំនុំជម្រះអាចបដិសេធចំពោះពាក្យសុំពិនិត្យភស្តុតាង ។ វាចែងច្បាស់នៅទីនេះថា ការបដិសេធគឺវាទាក់ទងទៅនឹងភស្តុតាងមិនជាប់ពាក់ព័ន្ធ ។

ហើយចំណុចទីពីរ គឺភស្តុតាងមិនអាចរកបានក្នុងរយៈពេលណាមួយសមស្រប ។ ហើយទីបីគឺមិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅស្នើសុំពិនិត្យភស្តុតាង ។

[១០:៤១:២៥]

ដូច្នេះ ខ្ញុំសូមស្នើសុំដល់អង្គសាលាដំបូង ដែលជាអង្គសាលាដំបូងក្នុងការធ្វើសេចក្តីសម្រេច គឺយើងត្រូវបង្ហាញថា យើងមិនអាចទទួលយកបានចំពោះសេចក្តីប្រកាសទាំងពីរនោះ យើងអាចហៅវាថាជាកិច្ចសម្ភាសន៍ដែលធ្វើឡើងដោយ *ឌីស៊ីខេម* ដែលឯកសារទាំងអស់នេះមានបញ្ហាចោទជាច្រើន ហើយក៏ដូចជាបញ្ហានៃឯកសារផ្សេងៗដែលបង្កើតឡើងដោយអង្គការមួយនេះ ។ ដែលឯកសារទាំងអស់នោះមានចំណងជើងដូចជា ការស្វែងរកការពិតជាដើម ។

មូលហេតុដែលខ្ញុំលើកឡើងថា វាមិនអាចទទួលយកបានចំពោះធាតុផ្សំទាំងអស់និងឯកសារផ្សេងៗរបស់ *ឌីស៊ីខេម* នោះគឺ ឌុច មានបានរៀបរាប់ ។ លោកសហព្រះរាជអាជ្ញា គឺមេធាវីការពារក្តីទទួលស្គាល់អំពីឯកសារដើមជាការពិត ដែលលោក លោកស្រីមានបំណងក្នុងការដាក់បញ្ចូលជាឯកសារទាក់ទងទៅនឹងលោក ឈឿន សុទ្ធី ។ ដូចមេធាវីការពារក្តីបានទទួលស្គាល់ចំពោះឯកសារនេះមុនហ្នឹង គឺយើងគួរតែពិភាក្សាឯកសារដែលពាក់ពន្ធ័ទៅនឹងស-២១ ដែលជាឯកសារមូលដ្ឋាន ថាតើនៅទីនេះយើងពន្យល់ប្រាប់អង្គជំនុំជម្រះជូន យើងអាចបញ្ជាក់ជូនអង្គជំនុំជម្រះយ៉ាងម៉េច ចំពោះរបាយការណ៍លោក ឈឿន សុទ្ធី? ដែល ឌុច អាចពន្យល់ចំពោះបញ្ហាហ្នឹង ។ ហើយវាជាចំណុចមួយគួរឲ្យចាប់អារម្មណ៍ចំពោះនីតិវិធីរបស់យើង ។ ហើយលោក សៀ ផល នោះគឺជាអតីតអ្នកទោស ហើយនេះគឺជាបញ្ហាមួយគួរឲ្យចាប់អារម្មណ៍នៅក្នុងហ្នឹង ។

ដូច្នេះ ឯកសារនេះវាជាឯកសារមួយគួរឲ្យចាប់អារម្មណ៍ ។ ហើយលោក ឈឿន សុទ្ធី បានលើកឡើងអំពីបញ្ហា ម-១៣ ហើយមន្ទីរនោះត្រូវបានប្រើប្រាស់សម្រាប់ឃុំអ្នកដែលទទួលរងការដាក់ទណ្ឌកម្មមួយជីវិត ។ ហើយយើងមានឃើញមានអ្នកទោស២៥០ ទៅ ៣០០ ដែលជាប់នៅទីនោះ ។ ហើយនៅក្នុងរបាយការណ៍របស់ *ឌីស៊ីខេម* ឯកសាររបស់ *ឌីស៊ីខេម* គឺឯកសារលេខ ERN ជាភាសាបារាំង ០០២៩៥១៥១ គឺឯកសារមួយនេះគឺបានបង្ហាញអង្គហេតុដែលមិនគួរឲ្យជឿ ។ តាំងពីបង្កើតម-១៣ រហូតមកការផ្លាស់ប្តូទីតាំងមកស-២១ គឺមានអ្នកទោសរាប់ពាន់ អ្នកទោស៣ម៉ឺននាក់ត្រូវបានសម្លាប់។ ដូច្នេះ ហើយនៅទីនេះយើងគួរតែពិចារណាទៅលើបញ្ហានេះ ។ ហើយយើងសុំឲ្យមានឯកសារបង្ហាញនូវឯកសារពីរដែលចង់ស្នើសុំឡើងនេះដែលវាមានលក្ខណៈផ្ទុយគ្នាទាំងស្រុងតែម្តង ។

លោកប្រធាន លោក លោកស្រី ចៅក្រមជាទីគោរព! ជាសេចក្តីសន្និដ្ឋានបញ្ចប់ ខ្ញុំស្នើសុំឲ្យអង្គសាលាដំបូងបង្ហាញថា ឯកសារទាំងអស់នោះមិនមែនជាឯកសារដែលធ្វើឡើងតាមនីតិវិធីច្បាប់នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូ ។ ដូច្នេះ ខ្ញុំស្នើសុំអង្គសវនាការសាលាដំបូងឲ្យប្រកាសថា យើងមិនអាច ស្នើសុំឲ្យធ្វើមោឃភាពបានចំពោះឯកសារដែលមិនបានធ្វើឡើងត្រឹមត្រូវតាមនីតិវិធីដែលវាយើងត្រូវពិនិត្យទៅលើវិធាន៨៧.៣ គឺយើងមានលទ្ធភាពក្នុងការប្រកាសមោឃភាពចំពោះឯកសារទាំងអស់នោះ ។

[១០:៤៦:០៨]

ដូច្នេះ ហើយជាចំណុចទាំងឡាយ ដែលខ្ញុំសុំស្នើឲ្យធ្វើការប្រកាសចំពោះបញ្ហាមោឃភាព ។ ដូច្នេះ យើងខ្ញុំគិតថា យើងជួបប្រទះបញ្ហាទាំងឡាយ ដូចជាបញ្ហានៃខ្សែរូបភាពវីដេអូផងដែរ ដែលខ្សែ

រូបភាពវីដេអូនោះ គឺមេធាវីការពារក្តីកំពុងតែពិនិត្យពិចារណា ។ ហើយខ្សែវីដេអូនោះ វាជាខ្សែវីដេអូមួយធ្វើឲ្យយើងមានការភ្ញាក់ផ្អើលចំពោះភស្តុតាង ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកកន្លះម៉ោង ។

*[សវនាការសម្រាកពីម៉ោង ១០:៤៧នាទី ដល់ម៉ោង ១១:៣៤នាទី]*

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចពិភាក្សាដេញដោលតទៅទៀត ។ ហើយអម្បាញ់មិញនេះអង្គជម្រះមុននឹងសម្រាកបានឃើញ សហព្រះរាជអាជ្ញាបានលើកដៃមានបំណងនិយាយអំពីបញ្ហាអ្វីទៅ?

បើមានសូមអញ្ជើញ ហើយសូមនិយាយខ្លីបានហើយ ហើយជៀសវាងនិយាយច្រំដែល ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

អរគុណលោកប្រធាន ។ ខ្ញុំនឹងលើកឡើង ហើយខ្ញុំនឹងលើកចំណុចមួយចំនួនដែលលើកឡើងដោយលោក រូ ។ ខ្ញុំនឹងនិយាយក្នុងនាមសហព្រះរាជអាជ្ញា ហើយសេចក្តីលើកឡើង សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីមានលក្ខណៈមិនមានមូលដ្ឋាន ។ ហើយសហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គសវនាការយកចម្លើយរបស់ *ឌីស៊ីខេម*ដាក់មកពិភាក្សាដេញដោលនៅចំពោះមុខ ។ ហើយយើងខ្ញុំស្នើសុំឲ្យមានការយកឯកសារនេះមកពិភាក្សាដេញដោល ។ ហើយសហព្រះរាជអាជ្ញាមិនមានជំហរណាមួយដែលថាមានមនុស្ស៣ម៉ឺននាក់ បានស្លាប់នៅម-១៣នោះទេ ។ ប៉ុន្តែ ចំណុចនេះគឺវាមិនពាក់ព័ន្ធទៅនឹងបញ្ហាចោទលើឯកសារចំនួនពីររបស់ *ឌីស៊ីខេម* ។ សេចក្តីសម្រេចរបស់អង្គសវនាការត្រូវតែធ្វើឡើងផ្អែកទៅលើឯកសារនីមួយៗ និងឯកសារទាំងឡាយដែលបានដាក់ជូន ។ ហើយខ្ញុំសូមលើកឡើងទៅលើវិធាន៧៦ និងវិធាន៨៧ ហើយការបកស្រាយទៅលើវិធាន៧៦ គឺមានការបកស្រាយទៅលើបញ្ហាហ្នឹង ។ ហើយចំពោះវិធាន៧៦ គឺចែងអំពីបណ្តឹងសុំមោឃភាព ដោយការមិនគោរពវិធានបញ្ញត្តិ ។

នៅក្នុងករណីនេះ គឺនៅក្នុងកិច្ចនីតិវិធីត្រូវស្នើសុំមោឃភាព គឺបានន័យថា គឺស្នើសុំឲ្យសហព្រះរាជអាជ្ញាបានស្នើសុំឲ្យដាក់សំណុំរឿងនេះចូលទៅក្នុងដាក់ឯកសារនេះចូលទៅក្នុងសំណុំរឿង ។ ហើយនៅពេលដែលយើងដាក់ឯកសារទាំងពីរចូលទៅក្នុងសំណុំរឿង គឺកិច្ចរបស់ចៅក្រមស៊ើបអង្កេត គឺជាកិច្ចទាំងឡាយដែលត្រូវសុំមោឃភាព ដូច្នេះ វាចំណុចនេះ គឺវាមិនពាក់ព័ន្ធ ។ ហើយចំណុចនេះហើយ

គឺវានាំទៅដល់ការបកស្រាយទៅលើវិធាន៨៧ ។ ខ្ញុំហាក់ដូចជាមិនឮទឡ្ហីករណ៍របស់មេធាវីការពារក្តី អ្វីដែលគាត់បានលើកឡើង ។ ខ្ញុំឮគាត់លើកទៅលើលក្ខខណ្ឌពីរក្នុងចំណោមលក្ខខណ្ឌទាំងប្រាំ ដែលយើងពិចារណាថា ឯកសារនោះយកបាន ទទួលយកបាន ឬក៏មិនទទួលយកបាន ។ ចំណុចមួយ គឺគាត់លើកឡើងថា ឯកសារនោះមិនជាប់ពាក់ព័ន្ធ ហើយខ្ញុំមិនឮទឡ្ហីករណ៍ណាមួយដែលបញ្ជាក់ថា ឯកសាររបស់*ឌីស៊ីខេម*គឺមិនមានលក្ខណៈសមរម្យ ឬក៏មិនពាក់ព័ន្ធ គឺមិនមានទឡ្ហីករណ៍លើកឡើង ។ ហើយវាមិនមែនជាគោលនយោបាយត្រឹមត្រូវ ដែលថាដោយសារតែឯកសារមិនបានធ្វើឡើងដោយអនុវត្តតាមគោលការណ៍ច្បាប់នោះ ឯកសារនោះមិនអាចទទួលយកបាន ។ គោលការណ៍នេះ គឺមិនត្រឹមត្រូវក្នុងការលើកឡើងដូច្នេះនោះទេ ។ គឺឯកសារនោះ គឺបានបញ្ជាក់ និងវាស៊ីទៅនឹងចម្លើយផ្សេងៗ និងភស្តុតាងផ្សេងៗ ហើយឯកសារនោះ គឺវាស៊ីគ្នាទៅនឹងចម្លើយរបស់ជនជាប់ចោទ ដែលបានលើកឡើងនៅចំពោះមុខអង្គសវនាការ ។

[១១:៣៩:១១]

ចំណុចចុងក្រោយដែលខ្ញុំសូមលើកឡើង យើងមិនឃើញមានវិធានណាមួយដែលថា គ្រប់ឯកសារទាំងអស់ត្រូវតែតទល់ និងបង្ហាញមុខចំពោះមុខជនត្រូវចោទគ្រប់ពេលទាំងអស់នោះទេ ដើម្បីឲ្យអង្គសវនាការផ្អែកទៅលើឯកសារទាំងអស់នោះបាន ។ ខ្ញុំដឹងថា មេធាវីការពារក្តីមិនបានលើកយោងទៅលើវិធានទាំងអស់នោះទេ ដូច្នេះ ហើយចំណុចដែលខ្ញុំបានលើកឡើងនេះ គឺជាអ្វីដែលខ្ញុំសូមដាក់ជូនអង្គសវនាការ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រ៉ូ ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

សូមអរគុណ ។ ខ្ញុំនឹងមិននិយាយឡើងវិញនៅការពន្យល់ទាំងឡាយដែលខ្ញុំបានធ្វើរួចមកហើយនោះទេ។ ខ្ញុំនៅតែរក្សានូវអ្វីដែលខ្ញុំបានិយាយទាក់ទងទៅនឹងវិធាន៧៦ ដែលចំណងជើងរបស់វិធានហ្នឹងគឺទាក់ទងនឹងបណ្តឹងសុំមោឃភាព ដោយការមិនគោរពវិធានបញ្ញត្តិ នេះគឺទាក់ទងទៅនឹងកំណត់ត្រានៃជាលាយលក្ខណ៍អក្សររបស់ខាងតុលាការ ហើយអ្វីដែលខាងសហព្រះរាជអាជ្ញាបានលើកឡើងនោះគឺមិនមែនជាកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់តុលាការនេះទេ ។ ហើយខ្ញុំក៏មិនស្នើសុំឲ្យមានមោឃភាពនោះដែរ។ យ៉ាងណាមិញ វិធាន៨៧ ទាក់ទងទៅនឹងកថាខណ្ឌទី២ ដែលបានចែងថា សេចក្តី

សម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្អែកទៅលើភស្តុតាងដែលបានដាក់នៅចំពោះមុខនៅក្នុងដំណើរការនីតិវិធី ។ ហើយភស្តុតាងនោះត្រូវឆ្លងកាត់ការដេញដោល ដើម្បីឆ្លើយតបទៅនឹងអ្វីដែលខាងសហព្រះរាជអាជ្ញាបានលើកឡើងនោះ គឺថា ឯកសារអស់ទាំងហ្នឹងត្រូវតែឆ្លងកាត់ការដេញដោល គឺទាល់តែមានការបង្ហាញថា ឯកសារនោះអាចទទួលយកបាន ឬក៏មិនយកបានដូចមានចែងនៅក្នុងកថាខណ្ឌទី៣ ។ គឺថានៅពេលអង្គជំនុំជម្រះសាលាដំបូងធ្វើសេចក្តីសម្រេចផ្អែកលើភស្តុតាង ដែលមាននៅក្នុងសំណុំរឿង ។ ហើយបើសិនជាយល់ឃើញថា វាមិនជាប់ពាក់ព័ន្ធ ឬក៏ជាការស្នើសុំជាន់គ្នា មានន័យថា គឺមិនជាប់ពាក់ព័ន្ធគ្នា ឬជាការស្នើសុំជាន់គ្នា ហើយជាថ្មីម្តងទៀត គឺថាវាមិនសមស្របក្នុងការបង្ហាញភស្តុតាង ដែលឯកសារនោះចង់បង្ហាញនោះ ។

[១១:៤២:១៩]

អ៊ីចឹង ខ្ញុំចង់បញ្ជាក់អំពីចំណុចចុងក្រោយនោះ គឺថាភស្តុតាងនោះមិនអាចបង្ហាញអំពីអង្គហេតុ ឬក៏គោលដៅនៃការស្នើសុំពិនិត្យភស្តុតាងនោះ ។ អ៊ីចឹងនៅក្នុងសេចក្តីសម្អាសដែលបានធ្វើឡើងនៅក្នុងលក្ខខណ្ឌមួយដែលយើងអាចធ្វើការជជែកតវ៉ាគ្នាបាននោះដូច្នេះ មានន័យយើងថា គឺឯកសារហ្នឹងមិនអាចពឹងបាន អាស្រ័យលើបានទេ ។ ហើយនេះ ដែលត្រូវបានបង្ហាញឡើងដោយខាង *ឌីស៊ីខេម* ហើយរបាយការណ៍ ដែលបានបង្ហាញនេះ គឺគេវាមានរកឃើញនៅក្នុងស្ថាប័នរបស់ប្រទេសកម្ពុជាដទៃទៀត ដែលត្រូវបានបង្កើតឡើងដោយ*ឌីស៊ីខេម* ខ្លួនឯង មិនមែនជាស្ថាប័នជាផ្លូវការណាមួយនោះទេ ហើយឯកសារហ្នឹង គឺថាមិនមានឆ្លើយតបទៅនឹងទម្រង់ផ្នែកច្បាប់ណាមួយ ហើយដូច្នេះមិនអាចបង្ហាញនូវអ្វីដែលឯកសារនោះបង្ហាញនោះទេ ។

អ៊ីចឹង ខ្ញុំចង់និយាយថា ឯកសារអស់ទាំងហ្នឹង គឺមានលក្ខណៈភាពដដែលៗជាន់គ្នាទីមួយ ដូច្នេះហើយគឺថា ខ្ញុំសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងហ្នឹង ធ្វើការបង្ហាញថា គឺលោក លោកស្រីចៅក្រមបានដឹងហើយអំពីបញ្ហាជាក់លាក់អស់ទាំងហ្នឹង។ អ៊ីចឹងហើយ ខ្ញុំសូមរំឭកដល់លោកចៅក្រម លោកលោកស្រីចៅក្រមផងដែរ គឺថា យើងបានពិនិត្យមើលសាក្សី៣នាក់ ហើយទាក់ទងនឹងម-១៣ ហើយនិងបានពិភាក្សាពិនិត្យទៅលើជនជាប់ចោទផងដែរ ហើយអង្គហេតុនៅម-១៣ គឺមិនទាក់ទងទៅនឹងយុត្តាធិការរបស់ជំនុំជម្រះសាលាដំបូងនេះទេ របស់តុលាការនេះទេ ។ អ៊ីចឹងហើយ យើងគួរតែបន្តទៅមុខទៀត កុំនៅត្រឹមកម្រិតនេះទៀត ។ អ៊ីចឹង ដូច្នេះយើងគួរតែពិនិត្យមើលលើអង្គហេតុដែលជាការចោទប្រកាន់ទៅលើ ឌុច មានន័យថាគឺអ្វីដែលកើតឡើងបន្ទាប់ពីថ្ងៃ៧មុនថ្ងៃ៧ មករា ១៩៧៩នោះ ។ អ៊ីចឹង

ខ្ញុំសូមស្នើឲ្យអង្គសវនាការធ្វើការសម្រេចថា ឯកសារទាំងពីររបស់ *ឌីស៊ីខេម* នោះគឺវាមិនពាក់ព័ន្ធហើយ មិនអាចពឹងពាក់លើបានទេ ទៅលើអ្វីដែលគេបានលើកឡើងនៅក្នុងឯកសារនោះ គឺអាស្រ័យទៅលើអ្វីដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ ទាក់ទងទៅនឹងវិធាន៨៧.៣នោះ ហើយដូច្នេះខ្ញុំសុំស្នើអង្គសវនាការធ្វើការបង្ហាញថា មិនអាចទទួលយកបានភស្តុតាងនេះថាជាភស្តុតាងបានទេ ។

[១១:៤៥:00]

**ប្រធានអង្គជំនុំ៖**

បានស្តាប់សេចក្តីសន្និដ្ឋានរបស់ភាគី បានពិចារណា គឺអង្គជម្រះសាលាដំបូងសូមប្រកាសថា សំណើដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា ក៏ដូចជាភាគីដែលបានលើកឡើងអំពីបញ្ហាដែលមានបច្ចុប្បន្នភាពនៃសមត្ថភាពនៃការបកប្រែភាសា ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងទៀត មិនមែនតែឯកសារដែលបានលើកឡើងនៅពេលនេះទេ គឺមានឯកសារទៅមុខទៀត នឹងអាចមានពាក់ព័ន្ធស្ថានភាពដូចគ្នា ។ ហើយដោយលក្ខណៈនៃបញ្ហានេះវាមានលក្ខណៈស្មុគស្មាញផង ដោយផ្អែកលើវិធាន៧៦ និងវិធាន៨៧ ដែលភាគីបានសំអាង អង្គជម្រះសម្រេចថា ហ្នឹងលើកយកបញ្ហានេះទៅពិនិត្យពិភាក្សាសម្រេចនូវពេលក្រោយ ។

ហើយជាកិច្ចបន្តនេះសូមវេទិការហ្នឹងទៅលោក ហ្សង់ម៉ាក ដែលលោកមានបំណងពាក់ព័ន្ធទៅហ្នឹងឯកសារមួយចំនួនដែលមានការពិភាក្សាលើបញ្ហានេះដែរ គឺឯកសារធ្វើឡើងដោយ *យូអ៊ិនអេជស៊ីអ័រអា (UNHCRA)* ។ បើមានសូមអញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំនឹងព្យាយាមលើកសំណួរមួយចំនួនទាក់ទងទៅហ្នឹងកាលៈទេសៈ នៃកិច្ចសម្ភាសន៍រវាងជនជាប់ចោទ និងលោក ប៉េស៊្វ ជាអ្នកតំណាងឲ្យអង្គការសិទ្ធិមនុស្សជាន់ខ្ពស់ដែលបានធ្វើឡើង ។ ហើយឯកសារនោះ គឺមានលេខ០៩ កិច្ចសម្ភាសន៍នោះបានកើតឡើងកាលនៅពីខែ០៤ ឆ្នាំ៩៩ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

អ៊ីចឹង នៅក្នុងពេលនេះខ្ញុំនឹងមិនធ្វើការប្រឈមមុខទៅលើថា តើយើងទទួលយកបានឯកសារនោះ ឬក៏អត់ទេ? ប៉ុន្តែ ខ្ញុំចង់និយាយអំពីលក្ខខណ្ឌទូទៅដែលថា តើឯកសារនោះប្រមូលមកយ៉ាងម៉េច?

ដូច្នេះ គឺខាងមេធាវីការពារក្តីនឹងនិយាយពីបញ្ហានេះនៅពេលក្រោយ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បើអ៊ីចឹងខ្ញុំគ្រាន់តែចង់បញ្ជាក់ថា អ្វីដែលខ្ញុំនិយាយនោះត្រូវបានបកប្រែរួចស្រួលបួលសិន ។

អង្គសវនាការនឹងលើកសំណួរ ដើម្បីកំណត់នូវកាលៈទេសៈពិតប្រាកដដែលកិច្ចសម្ភាសន៍នោះបានធ្វើឡើង គឺមិនមានសំណួរទាក់ទងទៅនឹងខ្លឹមសារនៃបទសម្ភាសនោះទេ ។ ខ្ញុំសង្ឃឹមថា នេះបើជាចំណុចច្បាស់លាស់ហើយដែលខ្ញុំបានលើកឡើង ។

[១១:៤៨:៤១]

**ស៖** លោកត្រូវបានគេសម្ភាសន៍ នៅក្នុងអំឡុងកាលដំណាក់កាលស៊ើបអង្កេតទាក់ទង ទៅនឹងឯកសារនេះ ។ តើលោកមាននៅចាំទេកិច្ចសម្ភាសន៍នោះស៊ីអស់រយៈពេលប៉ុន្មានទៅ? ហើយធ្វើនៅឡើងឯណា? ហើយនឹងធ្វើឡើងនៅពេលណា?

**ឆ៖** លោកចៅក្រមជាទីគោរព! តាមខ្ញុំចាំ គឺខ្ញុំទៅដល់បាត់ដំបង នៅថ្ងៃ២៩ ខែមេសា ហើយកញ្ញា រអ៊ីហ្គូ នាំខ្ញុំទៅជួលបន្ទប់មួយនៅ-- កញ្ញា១ រីអ៊ីហ្គូ នាំខ្ញុំទៅជួលបន្ទប់ស្នាក់នៅក្នុងសណ្ឋាគារមនោរម្យខេត្តបាត់ដំបង ។ ល្ងាចថ្ងៃ២៩ហ្នឹង ខ្ញុំឃើញ គ្រីស្តូហ្វ ប៉េស៊្ហូ ចុះទៅដល់ជាមួយ ហេង ហាំខេង ជាអ្នកត្រូវបកទៅជាមួយដែរ ។ ការសន្ទនាគ្នាជាបទសម្ភាសបានចាប់ផ្តើមឡើង តាំងពីល្ងាចថ្ងៃទី២៩នុ៎ងម្ល៉េះ ។

ដូច្នេះ នៅក្នុងការសន្ទនាគ្នានេះមានមនុស្ស៥នាក់ ។ ទីមួយ គឺខ្ញុំបាទ កាំង ហ្គេកអ៊ាវ ទីពីរ លោក គ្រីស្តូហ្វ ប៉េស៊្ហូ ទីបី គឺកញ្ញា រុជអ៊ីយហ្គូ *ម៉ាត់ដេម័រស៊ែល* ប្តូយតូ *(ជនជាប់ចោទសើច)* ។ *(សុំទោស)* ទីបី គឺកញ្ញា រុជអ៊ីយហ្គូ ទីបួន គឺអ្នកបកប្រែឈ្មោះ ហេង ហាំខេង ឯទីប្រាំគឺ ពែរ ប៉ែកណាបុព្វជិកកាតូលិកម្នាក់ ដែលទៅជួយកំដរអារម្មណ៍ខ្ញុំ លោកឪពុក ។ នេះថ្ងៃខែ និងទីកន្លែងដែលគេធ្វើសម្ភាសន៍ខ្ញុំ ។ ទាំងអស់គ្នាឃើញហើយគេប្រើពាក្យសម្ភាសន៍ ក៏ប៉ុន្តែលក្ខណៈរបស់ ប៉េស៊្ហូ ប្រកាន់មកលើកខ្ញុំ គឺគេជាអ្នកចម្លើយហើយ ។ ខ្ញុំតវ៉ាគេថា គេមាន*ម៉ង់ដា* របស់សហប្រជាជាតិ ។ គេថាគេមាន*ម៉ង់ដា* របស់សហប្រជាជាតិ អា ហេង ហាំខេង ពួកម៉ាក់ខ្ញុំ វាចាក់បណ្តោយ ហើយសង្កត់ខ្ញុំថែម ។ បើសិនជាយកខ្សែអាត់នោះមកស្តាប់ឡើងវិញ យើងសង្កេតឃើញលក្ខណៈដែលគេសួរចម្លើយខ្ញុំនោះមិនមានលក្ខណៈល្អមឲ្យខ្ញុំសហការនឹងគេបានទេ នេះជាលក្ខណៈដែលខ្ញុំធ្វើទាំងស៊្ញុំទ្រាំ ។ ហើយសូមបញ្ជាក់ថា ហេង ហាំខេង នេះវាជាអ្នកកំពង់ធំដូចខ្ញុំដែរ វារៀនក្រោយខ្ញុំមួយឆ្នាំ ។ វាចូលក្នុងជួរបដិវត្តន៍បានមួយឆ្នាំពីរ តែវាប្រកាន់ឫកមើលតែវានឹងវាស្គាល់ខ្មែរក្រហមច្បាស់ខ្លាំងម៉េះ ។

ដូច្នេះ លក្ខណៈ ហេង ហាំខេង ហ្នឹងដែលធ្វើឲ្យខ្ញុំធុញទ្រាន់បំផុត បាត់បង់ស្មារតីសហការ ។

[១១:៥៥:១២]

ដូច្នេះ ដល់ក្រោយមកខ្ញុំបានខ្សែអាត់ហ្នឹងយកទៅស្ដាប់ នៅពេល១ដែលសហចៅក្រមស៊ើបអង្កេតបានអនុញ្ញាតឲ្យខាងមេធាវីការពារយកខ្សែអាត់ទៅឲ្យខ្ញុំស្ដាប់ ។ ខ្ញុំឃើញមានមួយកំណាត់ ខ្សែអាត់មួយកំណាត់ចាស មានខ្សែអាត់មួយកំណាត់ហ្នឹង គឺមានសំឡេងអ្នកផ្សេង កាត់ផ្ដាច់មួយកំណាត់ខ្សែអាត់ហើយ ។ ដូច្នេះ ខ្ញុំសន្និដ្ឋានថា ខ្សែអាត់នេះមិនមែនជាខ្សែអាត់ដើម ។

សរុបមក ខ្ញុំសូមជម្រាបលោកចៅក្រមនិងអង្គជំនុំជម្រះថា ខ្ញុំមិនសារខ្ញុំជៀសមិនរួចពីនិយាយការពិតទេ ព្រោះខ្ញុំចង់សារភាពការពិត ។ ខ្ញុំចង់រាយការណ៍ជូនជាតិប្រជាជន និងប្រជាជនសាកលលោកថា ខ្ញុំហ្នឹងបានប្រព្រឹត្តខុស ។ ខ្ញុំបានប្រព្រឹត្តខុស បានប្រព្រឹត្តឧក្រិដ្ឋកម្មពិតមែន។ ក៏ប៉ុន្តែ ចំណែកខ្លះក៏មិនពេញចិត្តនឹងឆ្លើយច្បាស់លាស់ដែរ ខ្ញុំខ្វះស្មារតីសហការ ។ ខ្ញុំសូមឆ្លើយនឹងសំណួរលោកចៅក្រមប៉ុណ្ណេះ ។

[១១:៥៨:០៥]

**ស៖** តើលោកអាចប្រាប់យើងបានទេថា កិច្ចសម្ភាសន៍ហ្នឹង ឬកិច្ចសម្ភាសន៍ជាច្រើនដងហ្នឹង ស៊ីពេលអស់រយៈពេលប៉ុន្មានដង? តើជាកិច្ចសម្ភាសន៍តែមួយនៅក្នុងពេលរសៀលនោះ ឬក៏មានធ្វើឡើងជាច្រើនថ្ងៃ?

**ឆ៖** លោកចៅក្រមចៅក្រមជាទីគោរព! ខ្ញុំបានជម្រាបហើយថា ការសម្ភាសនេះចាប់ពីល្ងាចថ្ងៃ៣០ ខែមេសា ១៩៩៩ ថ្ងៃ០១ ថ្ងៃ០២ ថ្ងៃ០៣, មើល៎! ចាប់យប់ថ្ងៃ០៣ ខែឧសភា ។ ព្រឹកពីម៉ោង៧ដល់ម៉ោង១១ គេសួរខ្ញុំ ហើយល្ងាច១ពីម៉ោងប្រហែលជា-- ខ្ញុំភ្លេចហើយសុំទោស ប្រហែលជាម៉ោង២ទៅដល់ម៉ោង៥ ហើយយប់ពីម៉ោង៧ ដល់ម៉ោង៩យប់ ។ ដូច្នេះ បីបួនថ្ងៃនេះគេសួរខ្ញុំជាប់ ។

ខ្ញុំសូមបញ្ចប់ចម្លើយខ្ញុំប៉ុណ្ណេះ ។

[១២:០០:២៥]

**ស៖** អ៊ីចឹងក្នុងអំឡុងពេលបីថ្ងៃនោះ អ៊ីចឹងគឺថាលោកនៅក្នុងចំណោមអ្នកដែលមានវត្តមាន ដែលលោកបាននិយាយប្រាប់ឈ្មោះហើយ គឺលោក ប៉េស៊ូ កញ្ញា ហ្ស៊ូហ្គោ ហើយនិងអ្នកបកប្រែ ហើយនិងលោក ប៉ែកណាត ។ តើជាការត្រឹមត្រូវ?

**ឆ៖** អ្នកកាសែត នេត ថាយ័រ ។ នេត ថាយ័រ មួយទៀត ។

**សៈ** អ៊ីចឹងជាចំណុចជាក់លាក់ទាក់ទងទៅនឹងអ្នកកាសែតនោះ តើលោកបានជួបអ្នកកាសែតហ្នឹងពីមុនមកនៃការជួបជុំនោះឬ? ហើយបើសិនជាមានធ្លាប់ជួបពីមុនមកមែន តើមានបានប្រាប់គាត់ពីអ្វីខ្លះ?

**ឆៈ** លោកចៅក្រមជាទីគោរព! អ្នកដែលទៅជួបខ្ញុំមុនដំបូងគឺ និច ដនឡុប ហើយបន្ទាប់មកថ្ងៃដែលខ្ញុំចាប់ផ្តើមបង្ហាញខ្លួនថាខ្លួនខ្ញុំ ឌុច គឺមាន នេត ថាយ័រ មាន និក ដនឡុប ហើយនិងម្នាក់ទៀតជាជនជាតិ ហ្កាល័រ គាត់ចាស់ គាត់ជាអ្នកថតរូប ។ តែគេទាំងបីនាក់មិនបង្ហាញខ្ញុំជុំគ្នាតែម្តងទេ ។ គេអត់បង្ហាញប្រដាប់ថតសំឡេងឲ្យខ្ញុំឃើញ ។ ជនជាតិ ហ្កាល័រ ហ្នឹងគាត់អត់ធ្វើអីទេ គាត់គិតតែពីថតទេ ។ ឯចំណែក និក ដនឡុប វាថតផង វាសួរខ្ញុំផង ។ នេត ថាយ័រ ក៏សួរខ្ញុំដែរ ដល់ក្រោយមកបានឃើញលិចមុខ គ្រីស្តូប៉េស៊ូ, រុជ ហ្វ៊ូហ្កោ កញ្ញា រុជ ហ្វ៊ូហ្កោ ហើយនិង ហេង ហាំខេង ទៅជួបខ្ញុំ ហើយបបួលខ្ញុំមកភ្នំពេញ អូ! សូមទោស បបួលខ្ញុំមកបាត់ដំបង ។

**សៈ** តើលោកបាននិយាយអ្វីដែលនៅក្នុងអំឡុងពេលសម្ភាសជាមួយអ្នកការសែតនោះ? តើលោកនិយាយប្រាប់គេអំពីអ្វីខ្លះ? តើគេនិយាយអ្វីខ្លះប្រាប់លោកវិញ?

**ឆៈ** ភ្លេចអស់ទៅហើយ ប៉ុន្តែអារឿង១ខ្លះដែលឃើញ និច ដនឡុប វាសរសេរទៅខ្ញុំជឿតាមថាខ្ញុំបាននិយាយមែន ។ ខ្ញុំនិយាយថា ពីដើមមកខ្ញុំបម្រើមនុស្ស ឥឡូវខ្ញុំបម្រើព្រះ ។ ដែល និក ដនឡុប គាត់សរសេរដែរ ហើយខ្ញុំជឿថានេះចេញពីសម្តីខ្ញុំ ខ្ញុំនិយាយថា គឺព្រះគ្រិស្តជាម្ចាស់នាំអ្នកឯងមកជួបខ្ញុំ ។ ខ្ញុំនិយាយជាមួយ និច ដនឡុប ថាគឺព្រះយាស៊ូគ្រិស្តជាអង្គម្ចាស់នាំអ្នកឯងមកជួបខ្ញុំ ។ ខ្ញុំនិយាយប្រាប់ និច ដនឡុប ថា គឺព្រះយាស៊ូគ្រិស្តជាអង្គម្ចាស់នាំអ្នកឯងមកជួបខ្ញុំ ។ និច ដនឡុប វាយកពាក្យហ្នឹងទៅសរសេរ នេះជាពាក្យរបស់ខ្ញុំ ដែលខ្ញុំនិយាយប្រាប់វាមែន ។ ហើយខ្ញុំបាននិយាយថា តាម៉ុក ពីដើមឡូយហ៎ា ឥឡូវនេះអស់កម្លាំងរលីង គេចាប់ដាក់គុកអ៊ីចឹងហើយ ។ នេះខ្ញុំបាននិយាយមួយរឿងទៀត ហើយមួយរឿងទៀត ខ្ញុំបាននិយាយពីរឿង-- ឥឡូវនេះខ្ញុំគិតតែរឿងបីយ៉ាងទេ ។

[១២:០៦:២២]

ខ្ញុំបាននិយាយប្រាប់ និច ដនឡុប ថា ការរវល់របស់ខ្ញុំមានបី ទីមួយរកសាលាឲ្យកូនសិស្សរៀនពីព្រោះខ្មែរក្រហមត្រឡប់មកពីជំរំវិញអត់មានសាលាសោះ សាលាទាំងប៉ុន្មានត្រូវបំផ្លាញខ្ទេច ។ ក្នុងឋានៈខ្ញុំជាប្រធានការិយាល័យអប់រំស្រុក ខ្ញុំត្រូវរកសាលាឲ្យកូនក្មេង ខ្ញុំទីពីរខ្ញុំត្រូវរកវិហារសម្រាប់ថ្វាយបង្គំព្រះ ហើយទីបីខ្ញុំរកបាយចិញ្ចឹមក្រពះ ។

ជម្រាបលោកចៅក្រម ហើយនិងជាតិ ប្រជាជនកម្ពុជាដោយត្រង់ថា ពេលនោះខ្ញុំស្ទើរតែដាច់បាយ ក្រ ។ នេះសូមបញ្ចប់ប៉ុណ្ណឹង រឿងដែលខ្ញុំនៅចាំ ហើយដែលបាននិយាយជាមួយពួកអស់នុ៎ង ។

**ស៖** ក្នុងអំឡុងពេលសម្ភាសជាមួយអ្នកកាសែតនោះ តើលោកមានបាននិយាយអំពីតួនាទីរបស់ ប៉ុល ពត ទាក់ទងទៅនឹងស-២១ ទេ? តើលោកមានបានបង្ហាញអំពីចំណាប់របស់លោកក្នុងការនិយាយអំពីការពិត អំពីស-២១ ដែរឬទេ?

**ឆ៖** ពីរឿងស-២១នេះៗ ខ្ញុំបាននិយាយថា ប៉ុល-- ខ្ញុំបាននិយាយថា ដែល ប៉ុល ពត បដិសេធថា ស-២១ជាស្នាដៃដែលយួនប្រឌិត ។ ខ្ញុំបដិសេធសម្ដី ប៉ុល ពត ហើយ ។ ស-២១ ខ្ញុំធ្វើប្រធាន ឧក្រិដ្ឋកម្មរបស់ស-២១ទាំងប៉ុន្មានគឺខ្ញុំ ។ មេខ្ញុំដំបូង គឺលោកគ្រូ សុន សេន ហើយបន្ទាប់មកគឺ នួន ជា ។ ដូច្នេះ ប៉ុល ពត ថាជាស្នាដៃរបស់យួនអាម៉េចបាន ខ្ញុំមេៗស-២១ ។

**ស៖** អ៊ីចឹងទាក់ទងនឹងអង្គហេតុដែលបានព្រមព្រៀងគ្នានោះ បញ្ជីអង្គហេតុដែលបានព្រមព្រៀងគ្នានោះ គឺលោកបានលើកឡើងថា កថាខណ្ឌខ្លះត្រូវបានលើកឡើងនោះ គឺមិនមានកើតឡើងទេ មិនមានទេ គឺជា*លីស* គឺជាបញ្ជីនៃ ដែលខាងសហព្រះរាជអាជ្ញាលើកឡើងនោះ គឺបង្ហាញអំពីពិរុទ្ធភាព ជាពិសេសទាក់ទងទៅនឹងកថាខណ្ឌមួយដែលខ្ញុំនឹងអាន ហើយខ្ញុំចង់ដឹងថា តើលោកឯកភាពទៅនឹងកថាខណ្ឌហ្នឹងឬក៏អត់?

លោកបាននិយាយថា ឬក៏មានបាននិយាយថា កថាខណ្ឌនេះថា “គាត់បានពន្យល់ថា គេបាននាំខ្ញុំឲ្យចាកចេញពីការលាក់ខ្លួនរបស់ខ្ញុំនៅក្នុងឆ្នាំ៩៩ ដោយជឿជាក់ថា ខ្ញុំហ្នឹងមិនអាចចៀសវាងរួចពីការនិយាយការពិត ពីអ្វីដែលកើតឡើងនៅស-២១ទេ ហើយដែលបានស្ដាប់នូវអ្វីដែល ប៉ុល ពត បាននិយាយដែលបានបដិសេធអំពីអាទិភាពនៃស-២១នោះ ហើយដែលបានគិតថាស-២១ ហ្នឹង គឺជាស្នាដៃរបស់វៀតណាមទៅវិញ” តើលោកឯកភាពទេ?

**ឆ៖** *(មិនឮសំឡេង)*

[១២:១២:១៧]

**ស៖** តើមានបញ្ហាទេ? តើលោកមានបានឮអ្វីដែលអ្នកបកប្រែបានបកប្រែជាភាសាខ្មែរឲ្យលោកស្ដាប់ទេ?

**ឆ៖** សម្ដីដែលលោកចៅក្រមអានអម្បាញ់មិញនេះ មានន័យថា ខ្ញុំឈប់លាក់មុខទៀតហើយ ពីព្រោះ ប៉ុល ពត និយាយហ្នឹងធ្វើឲ្យខ្ញុំទ្រាំមិនបាន ខ្ញុំចេញមុខ ។ ដូច្នេះ សម្ដីនេះ បើតាមខ្ញុំរំឭកឡើងៗ

វិញ គឺពិតជាសម្តីដែលខ្ញុំបាននិយាយជាមួយគេនៅពេលនោះ ។

**ស៖** ខ្ញុំមានសំណួរទៀត ក៏ប៉ុន្តែប្រហែលជាយើងមិនមានពេលដើម្បីនឹងសួរទេ ។ អ៊ីចឹងនៅពេលដែលយើងចូលវិញ ខ្ញុំអាចនឹងមានសំណួរទៀត ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវពិសាអាហារថ្ងៃត្រង់ហើយ ដូច្នេះគឺអង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ ចាប់ពីពេលនេះទៅរហូតដល់ម៉ោង១ និង៣០នាទី អញ្ជើញចូលវិញ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយនិងនាំគាត់មកកាន់សាលសវនាការវិញឲ្យបានមុនម៉ោង១ និង៣០នាទីរសៀលនេះ ។

*[សវនាការសម្រាកពីម៉ោង ១២:១៥នាទី ដល់ម៉ោង ១៤:០១នាទី]*

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការតទៅទៀត ហើយជាបន្តទៅនេះសូមប្រគល់វេទិកាជូនទៅលោកចៅក្រម ហ្សង់ម៉ាក ដើម្បីបន្តនៃការសួរសំណួរមួយចំនួនដែលនៅសេសសល់ទៅដល់ជនជាប់ចោទ ពាក់ព័ន្ធជាមួយនឹងឯកសារដែលធ្វើឡើងដោយអង្គការ *UNHCHR* ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** កាលពីព្រឹកមិញនេះ លោកបានពន្យល់ប្រាប់យើងថា លោកបានជួបអ្នកកាសែត មុននឹងលោកត្រូវបានគេសម្ភាសន៍ ដែលសម្ភាសន៍ដោយលោកប៉េស្ទ័ ។ អ៊ីចឹង ខ្ញុំគិតថាលោកបាននិយាយពីមុនមកថា មិនមែនជាគំនិតមិនល្អទេ ដែលថាត្រូវនិយាយបញ្ជាក់ឲ្យបានច្បាស់លាស់នោះ ។ តើលោកមានបានជួបលោក ប៉េស្ទ័ ដែរទេ? ហើយនិងកញ្ញា ហ្វ៊ូហ្គោ? មុនពេលធ្វើកិច្ចសម្ភាសន៍ ដែលកិច្ចសម្ភាសន៍បានធ្វើកាលពីថ្ងៃទី៣០ ខែមេសា នោះ តើលោកមានបានជួបគាត់ពីមុនពេលនោះ? ហើយបើសិនជាជួបមែន ជួបនៅឯណា?

**ជនជាប់ចោទ៖**

**ឆ៖** លោកចៅក្រមជាទីគោរព! ក្រោយពីខ្ញុំជួបអ្នកកាសែតទាំងពីរនាក់ ហើយនិងអ្នកថតរូបជនជាតិ ខ្ញុំជួបដាច់ដោយឡែកគ្នាបីនាក់ គ្រីស្តូហ្វ ប៉េស្ទ័, ម៉ាឌីម័រហ្សែល រុជហ្វ៊ូហ្គោ ហើយនិង១ ហេង

ហាំខេង ។ បីនាក់ទៀតនេះទៅដល់ផ្ទះប្អូនខ្ញុំនៅនឹងសំឡូតនោះ ។ ប្អូនស្រីទេ ដល់អ៊ីចឹងទៅខ្ញុំបានជជែកគ្នា ។ ពេលនុ៎ងឯងខាង ប៉េស៊ូ គេនាំខ្ញុំទៅមើលកន្លែងដែលប្រុងសង់សាលា ។ ដល់ពេលរួចពីធ្វើឫកជាទៅមើលកន្លែងសង់សាលអ៊ីចឹងមក មកដល់ផ្ទះវិញ ក៏ណាត់ឲ្យខ្ញុំមកបាត់ដំបង ជជែកគ្នាឲ្យស្រួល ។

ហ្នឹងមានជួបដាច់ដោយឡែកពីពួកអ្នកកាសែតហ្នឹងគ្នាបីនាក់ហ្នឹង ខ្ញុំដឹងៗច្បាស់ថាគេហ្នឹងជា-- ដូចជាគេឲ្យកាត *ឌីវីហ្សឹត* ខ្ញុំមួយទៅផង ។ ដូចជាមានម្នាក់ទៅទៀត ដូច រុជ ហ្ស៊ីហ្គោ ឲ្យខ្ញុំមួយ ហើយគ្រីស្តូហ្វ ប៉េស៊ី ឲ្យខ្ញុំមួយ ។ គេប្រាប់ច្បាស់ថា គេហ្នឹងនៅខាងអង្គការ *UNHCHR*។ ហើយគេប្រាប់ទៀតថា ប្រធានរបស់គេឈ្មោះ *ថូម៉ាស់ អាល់មឹប៊ើក* ។ ហើយគេបបួលមកបាត់ដំបងនេះ ក្រោមពាក្យស្ដោកថាៗ មករៀបចំពិគ្រោះគ្នាអារឿងសង់សាលា ។

នេះសូមបញ្ចប់សំណួរលោកចៅក្រមអម្បាញ់មិញនេះតែប៉ុណ្ណេះ ។

[១៤:០៦:០៦]

**ស៖** អ៊ីចឹងអ្វីដែលលោកនិយាយប្រាប់ហ្នឹងគឺថា ហេតុដែលគេឲ្យលោកអញ្ជើញមកបាត់ដំបងហ្នឹងគឺ ដើម្បីពិភាក្សាគ្នាអំពីការសាងសង់សាលារៀន ។ ហើយហ្នឹងគឺជាអ្វីដែលលោកបាននិយាយជាមួយគាត់នៅពេលនោះឬ?

**ឆ៖** ខ្ញុំមកបាត់ដំបងជាមួយនឹងគេនេះ ក្នុងជំនឿជឿជាក់ថា មកពិគ្រោះជាមួយនឹងគេអារឿងរកលុយសង់សាលា ។

**ស៖** តើលោកមានបានប្រាប់ពួកគាត់អំពីតួនាទីរបស់លោក ដែលលោកធ្លាប់មានពីមុនមកទេ? តើលោកមានបានជម្រាបប្រាប់គាត់អំពីតួនាទីរបស់លោកដល់ពួកគាត់ទេនៅពេលនោះ?

**ឆ៖** គេដឹង គឺគេប្រាប់ថា នេត ថាយ័រ ប្រាប់គេ ។ ដូច្នេះគេដឹងថាខ្ញុំជា ឌុច ប្រធានមន្ទីរស-២១ ពីមុនមក ហើយខ្ញុំក៏យកគេទៅបង្ហាញខាងសាលាស្រុកដែរ ។

**ស៖** ដូច្នេះតើលោកមានបានពិភាក្សាគ្នាពី ស-២១ ដែរឬទេ?

**ឆ៖** ជាមួយពួកពីរនាក់នេះ ជាមួយពួក *UNHCHR* នេះ ខ្ញុំមានជជែក ខ្ញុំមានប្រាប់គេ ពីរឿងពីរឿងនៅ ស-២១ ។ ជជែកនៅនឹងផ្ទះប្អូនខ្ញុំហ្នឹងក៏មាន ជជែកពេលធ្វើដំណើរទៅរកមើលដីសង់សាលាហ្នឹងក៏មាន ។

**ស៖** តើនរណាគេជាអ្នកស្នើឡើងអំពីការ ដើម្បីថា ដែលថាគាត់នឹងមកនោះ តើនរណាគេជាអ្នកស្នើឡើង?

**ឆ៖** អញ្ជើញលោក អ្នកដែលអញ្ជើញ ពែរ ប៉ែកណា មកនេះមិនមែន*UNHCR* ទេ គឺនេត ថាយ័រ ។

**ស៖** តើគេមានបានជម្រាបប្រាប់លោកអំពីលោក ប៉ែកណា ថាគាត់នឹងចូលរួមនៅក្នុងការជួបគ្នានោះដែរឬទេ?

**ឆ៖** មុនដំបូង នេត ថាយ័រ វាប្រុងទៅរក ហ្សេហ្ស៊ីប ម្នាក់ទេ ប៉ុន្តែដល់ទៅមិនបាន ហ្សេហ្ស៊ីប ហ្នឹង ក៏ឃើញ ពែរ ប៉ែកណា គាត់អញ្ជើញមក ។

[១៤:០៩:៥៣]

**ស៖** តើនៅពេលណាដែលលោកបានដឹងថា លោក ប៉ែកណា ហ្នឹង នឹងមានវត្តមាននោះ? តើលោកបានព្យាយាមស្វែងរកទេថា ហេតុអ្វីបានជាបុព្វជិតហ្នឹងគាត់មានវត្តមាននោះ? ឬក៏តើគាត់មានពន្យល់ពីហេតុផលនៃវត្តមានរបស់គាត់ទេ?

**ឆ៖** គាត់ទៅអញ្ជើញពួកហ្សេហ្ស៊ីប ម្នាក់មក ឲ្យមកនៅជាមួយខ្ញុំ ។ ខ្ញុំក៏ថាទៅចុះ! ហើយស្រាប់តែមិនបានពួក ហ្សេហ្ស៊ីប ហ្នឹងមក ស្រាប់តែបាន ពែរប៉ែកណា ។ ដែល ពែរប៉ែកណា គាត់អញ្ជើញមកគាត់*ប្រេសង់តេ* ខ្លួនគាត់ ។

**ស៖** គឺនៅពេលនោះពិភាក្សាការសង់សាលា ឬយ៉ាងម៉េច?

**ឆ៖** ពេលហ្នឹងដឹងហើយ ដឹងថាគេចាប់ផ្តើមសួរទៅហើយ ។ នៅពេល ប៉ែកណា គាត់អញ្ជើញមកដល់ហ្នឹង ដឹងខ្លួនគេជជែកគ្នារួចទៅហើយ ពីរឿងគេសួរចម្លើយខ្ញុំ ។

**ស៖** លោករំពឹងថានឹងមានការសួរចម្លើយ ថាតើលោករំពឹងថាគេនឹងសួរចម្លើយលោកអំពីអ្វី?

**ឆ៖** កាលដែលគេសួរចម្លើយខ្ញុំនេះគឺចាប់ពីល្ងាចថ្ងៃ២៩ សូមទោសឈប់-- មិនមែនទេៗឈប់ៗ-- ប្រហែលជាថ្ងៃ៣០ ខែមេសា ។ ថ្ងៃ៣០ មួយថ្ងៃ ថ្ងៃ១ មួយថ្ងៃ ថ្ងៃ២ មួយថ្ងៃ ថ្ងៃបី មួយថ្ងៃ ។ ដូច្នេះខ្ញុំចាប់ផ្តើមជួប ពែរប៉ែកណា នៅព្រឹកថ្ងៃទី៣០ ។ ជជែកគ្នា ចាប់ផ្តើម-- ជជែកគ្នា ហើយគេចាប់ផ្តើមសួរខ្ញុំតាំងពីល្ងាចថ្ងៃទី ២៩ ម្ល៉េះ នេះតាមខ្ញុំចាំ ។

**ស៖** ខ្ញុំសូមឲ្យលោកបញ្ជាក់ឲ្យបានច្បាស់ មុនពេលការសម្ភាសន៍នោះចាប់ផ្តើម មុនពេលដែលលោកទៅៗ ទៅឲ្យគេសម្ភាសន៍ គេបានប្រាប់លោកអំពីសំណួរដែលគេសួរលោកថា គេមានប្រាប់លោកថា លោក ពែរប៉ែកណា នឹងមកជួយលោកដើម្បីផ្តល់ខាង ជំនួយខាងផ្លូវចិត្តដែរឬទេ?

**ឆ៖** នៅពេលដែលគេចាប់ផ្ដើមសួរហ្នឹងហើយ ដែលនេត ថាយ៉រ វាបបួលខ្ញុំថាឲ្យទៅរកអ្នកជួយគាំទ្រខាងស្មារតីម្នាក់មកនៅជាមួយ ។ ហើយវាសម្រេចចិត្តទៅរក ហ្សេហ្ស៊ីប ម្នាក់ ។ សរុបមកគំនិតទៅរកអ្នកដែលមកជួយគាំទ្រខ្ញុំខាងស្មារតីជាគំនិតរបស់ នេត ថាយ៉រ ទេ ។ វាជួយខ្ញុំខាងស្មារតីហ្នឹង ។ ហើយខ្ញុំបញ្ជាក់ថា *ឈើច* របស់ខ្ញុំនៅបាត់ដំបងដែរ នៅចំការសំរោង ក៏ប៉ុន្តែពេលនុ៎ងខ្ញុំខ្វាយខ្វល់ក្នុងអារម្មណ៍នឹកអីអត់ឃើញទេ ។ ដូច្នេះ ខ្ញុំបណ្ដោយតាមនេត ថាយ៉រ វាទៅអញ្ជើញហ្សេហ្ស៊ីប ម្នាក់មក ប៉ុន្តែមិនបានហ្សេហ្ស៊ីប បាន ពែរ ប៉ែកណា ។ សរុបមកការសួរចម្លើយនេះបាន ពែរ ប៉ែកណា គាត់មកនៅជិតខ្ញុំកត់ក្ដៅ គាត់ចេះខ្មែរស្ទាត់ ។

[១៤:១៤:៤៦]

**ស៖** ដូច្នេះលោកទៅ ការប្រជុំដែលបានរៀបចំជាមួយនឹង ប៉េស្ស៊ី ហើយនៅពេលក្នុងប្រជុំនោះលោកបានដឹងថា លោកនឹងមានបុព្វជិតម្នាក់ផ្ដល់ជំនួញដល់លោក ហើយលោកនឹងដឹងថាគេនឹងសួរសំណួរលោក ថាតើត្រឹមត្រូវដែរឬទេ? ថាលោកបានដឹងដែរទេ ថាគេនឹងសួរលោកអំពីស-២១?

**ជនជាប់ចោទ៖**

**ឆ៖** លោកចៅក្រមទីគោរព! មុនដំបូងនៅពេលដែល ប៉េស្ស៊ី មិនទៅដល់ ខ្ញុំមិនគិតថាគេសួរចម្លើយខ្ញុំពីរឿង ស-២១ ទេ ។ ដល់ពេលគេចុះពីកប៉ាល់ហោះ គេយកចម្លើយទៅ បានខ្ញុំថាអុញ៉ ស្ងួរចម្លើយខ្ញុំ-- សុំទោសណ៎ា មិនមែនយកចម្លើយទៅទេ គេយកសំណួរម៉ាលីស ម៉ា១ចំនួន ហើយដល់ទៅយកទៅ ខ្ញុំឃើញ អ្ហ៎! សួរចម្លើយខ្ញុំ? នៅពេលហ្នឹងហើយ ដែលខ្ញុំបានតវ៉ាជាមួយនឹងគេ ថាអ្ហេ៎! សួរចម្លើយអាម៉េច! បើតុលាការមិនទាន់កើត ហើយមិនទាន់មានការអនុញ្ញាតពីរដ្ឋាភិបាលៗផង គេថា គេមានអាណត្តិរបស់សហប្រជាជាតិៗ ខ្ញុំចប់និយាយ ដល់ទៅគេប្រុងថតទាំងរូបផង គេប្រុងថតទាំងសំឡេងផងៗ ខ្ញុំមិនព្រមឲ្យថតតែសំឡេង ។ ហ្នឹងហើយ ដែលខ្ញុំបានជម្រាបលោកចៅក្រមពីដើមទីថាខ្ញុំធ្វើទាំងទើសទាំងទាល់ មិនចិត្ត ។ ដូច្នេះ គ្មានស្មារតីសហការពិតប្រាកដទេ ក៏ប៉ុន្តែ ពេលខ្លះមានស្មារតីខឹងនឹង អាខេង ហ្នឹងទៀត ហេង ហាំខេង ហ្នឹង ។

សរុបមក រឿងនៅនេះ-- រឿងដែលខ្ញុំនិយាយនេះ-- រឿងដែលខ្ញុំនិយាយទាំងអស់នេះ វាពិតជាចេញពីស្មារតីឈឺចាប់របស់ខ្ញុំ ដែលកើតមានឡើងនៅសម័យ ប៉ុល ពត ។ ខ្ញុំមានវិប្បដិសារីប៉ុនណា ខ្ញុំចង់លាតត្រដាងឲ្យពេញទី ក៏ប៉ុន្តែដល់ក្នុងការអនុវត្តស្ដែងជាក់នោះ ដល់គេច្រងេងច្រងាងខ្លាំងពេក ទប់មិនជាប់ដែលជាមួយ អាខេង ហើយជាមួយ ប៉េស្ស៊ី ខ្លួនឯងនោះ ។

**ស៖** ដូច្នេះ លោកបាននិយាយថា លោក ប៉េស៊ូ បានបង្ហាញប្រាប់លោកថា អាណត្តិរបស់អង្គសហប្រជាជាតិ អនុញ្ញាតឲ្យគាត់សួរសំណួរទៅដល់លោក ។ តើលោក ប៉េស៊ូ ប្រាប់លោកថា លោកចាំបាច់ត្រូវឆ្លើយតបសំណួររបស់គេដែរឬទេ?

**ឆ៖** គេប្រាប់ខ្ញុំថា គេមានសិទ្ធិធ្វើ ព្រោះគេមានៗវ៉ែ អាណត្តិរបស់សហប្រជាជាតិ ។ ដូច្នេះ គេសង្កត់ពាក្យម៉ាត់នេះមក នេះពាក្យដែលគេនិយាយ ពេលនោះនៅជាមួយនឹងខ្ញុំ ។ ដូច្នេះ គេសង្កត់ពីសិទ្ធិរបស់គេ គេសង្កត់ពាក្យនេះថា សិទ្ធិរបស់គេនេះ វាៗមានន័យថា បង្ខំឲ្យខ្ញុំត្រូវតែធ្វើហើយ ។

**ស៖** ថាតើគេចាប់បង្ខំលោកទៅ ឬក៏គេរក្សាទុកនៅលោកទីនោះ ដោយផ្ទុយនឹងឆន្ទៈរបស់លោក ហើយសម្ភាសន៍លោកច្រើនថ្ងៃ ឬយ៉ាងម៉េច? ថាតើលោកមានការបង្ខិតបង្ខំដែរឬទេ? តើគេមានបង្ខំលោកច្រើនដងច្រើនសារឲ្យទៅទីនោះដែរឬទេ?

[១៤:២០:៥៥]

**ឆ៖** ការឃាមកាមតាមផ្លូវប៉ូលិស តាមផ្លូវអីគ្មានទេ ។ ក៏ប៉ុន្តែ យើងខ្ញុំនៅទីនោះ ទាំងអស់បួននាក់ នៅប្រចាំនៅជាប់ហ្នឹងនោះទាំងអស់បួននាក់ ខ្ញុំ, គ្រីស្តូហ្វ ប៉េស៊ូ ហើយនឹង ហេង ហាំខេង ហើយនេត ថាយ៉ វានៅបន្ទប់មួយដាច់ដោយឡែករបស់វាទៅ ។ ខ្ញុំបន្ទប់មួយដោយឡែក អាខេង ហើយនិងនៃ ប៉េស៊ូ បន្ទប់មួយដោយឡែក ។ អាខេង ហើយនិង ប៉េស៊ូ នៅបន្ទប់មួយដោយឡែកជាមួយគ្នា ។ ឯចំណែក ពែរ ប៉ែកណា គាត់ទៅប៉ារូស នៃ អេហ្គីស របស់គាត់ គាត់ទៅអេហ្គីរបស់គាត់ ទៅវិហាររបស់គាត់ ។ ឯចំណែក នៃ រុច ហ៊្វូហ្គោ គេទៅទីស្នាក់ការរបស់គេ ។

សរុបមក ដែលនៅប្រចាំជាប់ទាំងអស់បួននាក់ ។ ពីរនាក់ផ្សេងទៀត គេទៅកន្លែងគេនៅពេលណាផុតពីការសួរ ។

**ស៖** លោកបានសួរចម្លើយដោយសហចៅក្រមស៊ើបអង្កេត អំពីការសួរចម្លើយនៅពេលនោះ គឺការសួរចម្លើយដោយ *UNHCR* ហើយមានសំណួរពីសហព្រះរាជអាជ្ញា គឺលោក អាឡិចប៊ែត ។ បាទ, លើកលែងតែខ្ញុំយល់ខុស លោកបានឆ្លើយថា លោកមិនបានលាក់លាមអ្វីពីលោក គ្រីស្តូហ្វ ប៉េស៊ូ ហើយលោកបានឆ្លើយសំណួរនៅពេលសួរចម្លើយដោយ ប៉េស៊ូ ពេលនោះដោយឆន្ទៈ ។ ថាតើលោកបញ្ជាក់យ៉ាងម៉េច ចំពោះអ្វីដែលលោកបាននិយាយចំពោះចៅក្រមស៊ើបអង្កេតវាមាន លក្ខណៈចម្លែកនៅត្រង់នេះបន្តិច?

[១៤:២៤:១១]

**ឆ៖** បញ្ហាខ្ញុំឆ្លើយដោយសេរី គ្មានការបង្ខិតបង្ខំ ជាទិដ្ឋភាពរួមគឺវាពិតជាចេញពីស្មារតីដែលខ្ញុំចង់លាតត្រដាងការពិត ។ ក៏ប៉ុន្តែ ក្នុងករណីខ្លះ ចម្លើយរបស់ខ្ញុំត្រូវគេសង្កុកមក ជាពិសេស អាខេង ហើយនិង ប៉ែស៊ូ ហ្នឹងហ្មង សង្កុកបន្តិចមក ។ ដូច្នេះ ចម្លើយមួយចំនួនៗខ្ញុំឆ្លើយឲ្យរួចតែពីមាត់ៗ អត់មានស្មារតីទទួលខុសត្រូវ ។ ភស្តុតាងខ្សែអាត់ ទោះបីជាខ្សែអាត់មិនមែនជាច្បាប់ដើមក៏ដោយ ក៏អាចមាននៅសល់ការជជែកវែកញែករវាងខ្ញុំ និងអាខេង ហើយនិងជាមួយ ប៉ែស៊ូ ខ្លះ ។ ទោះបីជាខ្សែអាត់មិនមែនជាច្បាប់ដើមក៏ដោយ ក៏វាបង្ហាញនូវការដែលខ្ញុំហើយនិង អាខេង ហើយនឹងប៉ែស៊ូ ជជែកគ្នាតវ៉ាគ្នា ។ ហើយក៏ប៉ុន្តែជាទូទៅ ស្មារតីខ្ញុំដែលនៅតែដក់ជាប់នៅក្នុងពេល នុ៎ងគឺ ជម្រាបដោយត្រង់សហប្រជាជាតិប៉ុនណាណីៗ អង្គការមួយម៉ាសាកលលោក ប៉ុនណាណី ហើយ ប៉ែស៊ូ ទៅធ្វើហ្នឹងដូចជាចោរអ៊ីចឹង អត់មានការស្រុះស្រួលគ្នាជាមួយរដ្ឋាភិបាល ។

ខ្ញុំចាត់ទុក ប៉ែស៊ូ ខ្ញុំមិននិយាយពីស្អីទេ ខ្ញុំចាត់ទុក ប៉ែស៊ូ ដូចជាចោរអ៊ីចឹង មិនទាន់បានយល់ស្របគ្នាជាមួយរដ្ឋាភិបាល តុលាការមិនទាន់កើត ហើយក៏ធ្វើហ្នឹង វាយកឈ្មោះសហប្រជាជាតិមកដាក់នៅក្នុងអារម្មណ៍ខ្ញុំពេលឆ្លើយហ្នឹង គឺនៅអាហ្នឹង ។

តាមគំនិតខ្ញុំៗ គឺសហប្រជាជាតិត្រូវធ្វើឲ្យខែងរែងឲ្យវាអំណាចជាងរដ្ឋាភិបាល ហើយមកធ្វើអ៊ីចឹង ខ្ញុំមិនពេញចិត្ត ប៉ែស៊ូ ធ្វើអ៊ីចឹង ខ្ញុំអត់ពេញចិត្តទេ ។ ហើយសូមជម្រាបថា ការដែលខ្ញុំពេញចិត្តពេលហ្នឹង គឺនែ៎ ថូម៉ាស់ហាម៉ាប៊ើកៗ ធ្វើ*ប្រេស រីលីស* មួយប្រហែលជានៅក្នុងថ្ងៃ៣០ ។ ប្រាប់ថារកឈ្មោះខ្ញុំ ហើយជូន *ប្រេស រីលីស* ហ្នឹងទៅ សុខ អាន ៗ ទៅនែ៎ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ទៅ ប៉ុលសារឿន បើធ្វើប៉ុណ្ណឹង វាដូចជាសមរម្យជាង ហើយស្រាប់តែមកលែងសួរចម្លើយ ខ្ញុំជម្រាបដោយត្រង់ចុះ ពេលនេះ វាហាក់ដូចជា គ្រីស្តូហ្វ ប៉ែស៊ូ ហើយនឹង ថូម៉ាស់ហាម៉ាប៊ើក គ្រីស្តូហ្វ ប៉ែស៊ូ ធ្វើហ្នឹងដូចចោរអ៊ីចឹង ។ នេះស្មារតីខ្ញុំ ។

**ស៖** តើមានរយៈពេលប៉ុន្មានក្រោយពេលដែលលោកសម្ភាសន៍នេះ លោកត្រូវបានគេឃុំខ្លួនរយៈពេលប៉ុន្មាន?

**ឆ៖** អរគុណលោកចៅក្រម ដែលបានសួរបញ្ហានេះ ។ យប់ថ្ងៃទីបួន ព្រឹកថ្ងៃទីបួន ឧសភា ខ្ញុំចេញពីអូរតែលមនោរម្យ ទៅដេកនៅបាត់ដំបង ។ យប់ថ្ងៃទីប្រាំ ខ្ញុំទៅដេកនៅឯផ្ទះខ្ញុំ យប់ថ្ងៃទីប្រាំមួយខាងប៉ូលិសហៅមក មកដេកនៅនឹងគុកបាត់ដំបង ប៉ុន្តែគេមិនឲ្យខ្ញុំដេកក្នុងគុកទេ គេឲ្យដេកនៅកន្លែងការិយាល័យបុគ្គលិកពន្ធនាគារហ្នឹងធ្វើការ ។ ព្រឹកឡើងថ្ងៃទីប្រាំពីរ គេដាក់អេលីកូ នាំខ្ញុំមកដល់ភ្នំពេញ

ហើយដល់ថ្ងៃទីប្រាំពីរ យប់ថ្ងៃទីប្រាំពីរ ខ្ញុំដេកនៅនៅខណ្ឌ-- (សូមទោស) ខ្ញុំមកដេកនៅនឹងអធិការដ្ឋានខណ្ឌមានជ័យមួយយប់ ។ អធិការដ្ឋាន *អាំងស្ពាច់ស្យុង (Inspection)* ឃើញខាងក្រសួងមហាផ្ទៃគេទៅសួរចម្លើយខ្ញុំ លោក សឿន មិនដឹងឈ្មោះស្អី សឿនទេ គេទៅសួរចម្លើយខ្ញុំ ហើយបានដល់បន្តិចមកបានឃើញខាងនៃតុលាការយោធានេះ គេទៅទទួលខ្ញុំ ។ ខ្ញុំចូលមកដល់តុលាការយោធាយប់ម៉ោងប្រាំពីរថ្ងៃប្រាំបី ។

[១៤:៣១:០៣]

**ស៖** ដូច្នេះ នៅក្នុងអំឡុងពេល ដែលលោកបានជួប ឬក៏ដែលលោកត្រូវបានគេសម្ភាស ឬក៏សួរជា មួយលោកសឿន អ្នកមកពីក្រសួងមហាផ្ទៃនោះ ឬក៏ចៅក្រមមកពីខាងតុលាការយោធានោះ តើគេមាន បានបង្ហាញជូនលោកនូវអត្ថបទនៃកិច្ចសម្ភាសន៍ ដែលលោកបានធ្វើជាមួយ ប៉េស្ទ ដែរ ឬទេ? អ៊ីចឹងគេមាន យកកិច្ចសម្ភាសន៍ ដែលលោកបានសម្ភាសជាមួយ ប៉េស្ទ មកបង្ហាញលោកដែរឬទេ?

**ឆ៖** លោកចៅក្រមជាទីគោរព! នៅពេលដែលព្រះរាជ-- ចៅក្រមស៊ើបអង្កេតនៃតុលាការយោធាសួរចម្លើយខ្ញុំ គាត់គ្មានយកខ្សែអាត់ ឬក៏គ្មានយកអត្ថបទចម្លង-- សូមទោស គាត់គ្មានយកខ្សែអាត់ ឬក៏អត្ថបទចម្លងខ្សែអាត់នេះរបស់ គ្រីស្ទូហ្វ ប៉េស្ទ យកទៅបង្ហាញខ្ញុំ ទៅសួរចម្លើយខ្ញុំទេ ហើយគាត់ក៏មិនដែល បើតាមខ្ញុំចាំ គាត់មិននិយាយប៉ះដល់រឿងហ្នឹងផង ។

**ស៖** នៅក្នុងបទសម្ភាសរបស់លោក គេបានលើកស្នើឡើងថា នឹងនាំយកលោកទៅប្រទេសថៃ ដូច្នេះ គឺគេថាលោកអាចនឹងរៀបចំនៅទីនោះ ហើយដើម្បីកាត់ទោសនៅប្រទេសប៊ែលហ្ស៊ិក ហើយគេក៏បាននិយាយផងដែរ ថាគេនឹងផ្តល់លុយឲ្យលោកមួយចំនួន ដើម្បីឲ្យលោកធ្វើដំណើរទៅប្រទេសថៃ តើលោកអាចប្រាប់បានទេ អំពីរឿងនេះ ឬក៏ចំណុចជាក់លាក់ណាមួយដែលថា សំណើនេះត្រូវបានគេធ្វើដល់លោកនោះ?

**ឆ៖** លោកចៅក្រម សូមអរគុណលោកចៅក្រម ដែលលើកបញ្ហានេះឡើង ។ នៅចុងបញ្ចប់ ប៉េស្ទ និងរ៉េអ៊ីហ្គ គេប្រាប់ខ្ញុំថា ប៉េស្ទ បានរត់ចុះ រត់ឡើងពេញមួយសាកលោក ដើម្បីឲ្យខ្ញុំទៅសុំជ្រកកោន ដើម្បីសុំជ្រកកោនខ្ញុំជា-- ឲ្យខ្ញុំទៅជ្រកកោនទៅក្នុងឋានៈ ជាអ្នកភៀសខ្លួននយោបាយ ។ ហើយដល់ចុងបញ្ចប់ គេថារកមិនបាន ឥឡូវទៅជាប់គុកនៅប៊ែលហ្ស៊ិកទៅ ។ ឲ្យខ្ញុំទៅប៊ែលហ្ស៊ិកទៅ ទៅជាប់គុកនៅប៊ែលហ្ស៊ិក ។ ខ្ញុំហួសចិត្តៗ ។ ដល់អ៊ីចឹង ខ្ញុំសួរច្រាសទៅវិញ ខ្ញុំថាទៅប៊ែលហ្ស៊ិក ហ្នឹងបើសិនជាគេកាត់ទោសខ្ញុំមិនដល់មួយជីវិត ខ្ញុំនៅសល់ទោសខ្លះ ត្រឡប់មកផ្ទះវិញ បានលុយឯណាជិះ

កប៉ាល់ហោះ។ ហើយខ្ញុំសួរទៀត បើខ្ញុំថា បើសិនជាខ្ញុំទៅជាប់គុកនៅប៉ែលហ្សិក បងប្អូនខ្ញុំទៅ សួរអីកើតដែរ? បានលុយឯណាជិះកប៉ាល់ហោះទៅ ។ នេះជាពាក្យខ្ញុំសម្រាប់បដិសេធ របៀបមួយម្យ៉ាងមិនចំមុខពេក របៀបទន់ភ្លន់ ។ ក៏ប៉ុន្តែ គេនៅតែបង្ខំចិត្តឲ្យខ្ញុំទៅ ឲ្យលុយខ្ញុំ៥០ដុល្លារ ឲ្យខ្ញុំជិះកង់ -- ជិះឡានទៅ ។ ឲ្យខ្ញុំចេញទៅហួសប៉ោយប៉ែតទៅ ទៅឲ្យពួកប៉ូលិសអន្តរជាតិចាប់ខ្ញុំនៅនុ៎ង ។ ហើយគេបញ្ជូនទៅប៉ែលហ្សិកតាមរយៈហ្នឹង ។ ខ្ញុំហួសចិត្ត ខ្ញុំចេញមក ព្រឹកឡើងខ្ញុំចេញមក នៅពេលហ្នឹងហើយដែល ប៉ែកណាត គាត់និយាយមួយម៉ាត់ដាក់ ប៉ែស្ស៊ូ គាត់ថា “ឆ្អែតចិត្ត” ។ ឈប់ៗ ខ្ញុំសូមនិយាយសារឡើងវិញ នៅពេលហ្នឹងហើយៗ ដែល ពែរ ប៉ែកណាត ដាក់ផ្ដែឲ្យគ្រីស្តូហ្វ ប៉ែស្ស៊ូ ។ ប៉ែស្ស៊ូ សួរខ្ញុំថា “ញ៉ាំ បាយឆ្អែតទេ” ពាក្យខ្មែរយើង គេប្រើពាក្យថា “ឆ្អែតចិត្ត” ពាក្យ ប៉ែកណាត គាត់ថា-- ឈប់ៗលោកបកប្រែឈប់ ។ ដល់ពេលគ្រីស្តូហ្វ ប៉ែស្ស៊ូ សួរខ្ញុំថា ញ៉ាំបាយឆ្អែតទេ ហើយខ្ញុំឆ្លើយថា ឆ្អែត ។ ពែរ ប៉ែកណាត ថា “ឆ្អែតចិត្ត” ។ ឆ្អែតចិត្តនេះ មិនមានន័យថា *ឆ្នាំសែកទីសាកសុង* ទេ មានន័យថាវាហួសចិត្ត វាដល់ក វាខ្លាំង វា *វិចសេ* ។ អាហ្នឹងត្រូវ ។

**ស៖** អ៊ីចឹងនៅពេលណាទៅដែលលើកទី១ ដែលគេបានផ្ដល់ឱកាសឲ្យលោកធ្វើដំណើរទៅប្រទេសថៃនោះ តើនៅពេលណា?

**ឆ៖** ចុងថ្ងៃទី៣ ខែឧសភា ។

[១៤:៣៩:៥៥]

**ប្រធានអង្គជំនុំ៖**

លោករៀបចំសំណួរសាជាថ្មី លោក ហ្សង់ម៉ាក ដោយហេតុជនជាប់ចោទប្រញាប់ប្រញាល់ក្នុងការស្ដាប់ភាសាបារាំង ហើយគាត់ឆ្លើយនឹងសំណួរ អ៊ីចឹងអ្នកបកប្រែហ្នឹង អត់អាចស្ដាប់បានទេ អ៊ីចឹងចាប់សំណួរអំមិញហ្នឹងសារជាថ្មី ហើយសូមរំឭកដល់ជនជាប់ចោទថា រងចាំស្ដាប់ការបកប្រែភាសាឲ្យចប់សិន សូមឆ្លើយនឹងសំណួរ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំនឹងសួរសំណួរលោកម្ដងទៀត ។ តើនៅពេលជាក់លាក់ណាមួយ ដែលគេបានលើកឡើងពីលទ្ធភាពអំពីការធ្វើដំណើរទៅប្រទេសថៃ ដើម្បីឲ្យធ្វើការកាត់ទោសខ្លួនលោកនៅបរទេសនោះ?

**ឆ៖** លោកចៅក្រមជាទីគោរព! គេចាប់ផ្ដើមបង្ហាញគោលបំណងគេ ចង់នាំខ្ញុំទៅជាប់គុកនៅប្រ៊ុលសែល នៅពេលដែលគេសួរចម្លើយខ្ញុំចប់ ។ គឺនៅល្ងាចថ្ងៃទី៣ ឧសភា ១៩៩៩ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំអត់មានសំណួរអ្វីទៀតទេ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មានបំណងយ៉ាងម៉េចទៅ លោកសហព្រះរាជអាជ្ញា ចង់និយាយរឿងអីទៅ និយាយបញ្ហាជាមុនសិន ដើម្បីបានយល់ ថាគួរអនុញ្ញាតឲ្យនិយាយតទៅ ឬក៏បញ្ចប់ ពីព្រោះដល់ដំណាក់កាលតុលាការនឹងប្រកាសបញ្ឈប់ការពិភាក្សាការដេញដោលម-១៣ ត្រឹមនេះសិន ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន។ ខាងសហព្រះរាជអាជ្ញាមានសំណួរពីរបីសំណួរដែលត្រូវសួរបន្ថែមទៀតទៅលើសំណួរអ្វី ដែលលោកចៅក្រមឡាវែន៍ បានសួរទៅឲ្យជនជាប់ចោទទាក់ទងទៅនឹងព្រឹត្តិ-ការណ៍ដែលបានកើតមានឡើងនៅឆ្នាំ១៩៩៩ ហើយយើងខ្ញុំមិនមានសំណួរអ្វីបន្ថែមពីលើនេះទៀតទេ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ, ប៉ុន្តែ រំឭកឡើងវិញ បញ្ហាកាលដើមឡើយ គឺលោកមេធាវីការពារក្តីបានបញ្ជាក់យ៉ាងច្បាស់លាស់ ការសួរដេញដោលមិនឲ្យចូលក្នុងខ្លឹមសារនៃអង្គកំណត់ហេតុបទសម្ភាសន៍នោះទេ គឺកាលពីព្រឹកមិញ គឺយើងចាំច្បាស់ថា កិច្ចស៊ើបសួរហ្នឹង គឺតែកាលបរិច្ឆេទនៃទីកន្លែងនៃការប្រព្រឹត្តទៅតែប៉ុណ្ណោះ ។

[១៤:៤៤:00]

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណ គឺខ្ញុំបានយល់ច្បាស់ណាស់ពីចំណុចនេះ ។

លោក កាំង ហ្គេកអ៊ាវ អ៊ីចឹងលោកបានធ្វើការចោទប្រកាន់ធ្ងន់ធ្ងរអំពីការប្រព្រឹត្តទៅរបស់អ្នកដែលបានមកសម្ភាសលោក លោកបាននិយាយថា លោក គ្រីស្តូហ្វ ប៉េស៊ូ និង ហាំ ហេងខេង បានស្រែកដាក់លោកជាច្រើនដង ហើយលោកក៏បាននិយាយផងដែរថា លោក ប៉េស៊ូ ដូចជាចោរអ៊ីចឹង ដែលបានមកលួចព័ត៌មានពីលោក ។

**ស៖** តើមានហេតុផលអ្វីដែលលោកមិនប្រាប់ខាងសហចៅក្រមស៊ើបអង្កេតអំពីចំណុចអស់ទាំងនេះ នៅពេលដែលលោកមានឱកាសក្នុងការនិយាយ ឬក៏ការឆ្លើយតបនៅពេលនោះជាលាយលក្ខណ៍អក្សរក្តី ឬក៏ដោយផ្ទាល់មាត់ក្តី? នេះជាសំណួរ ។

[១៤:៤៥:១៥]

**ឆ៖** ឥឡូវសូមគោរពលោកព្រះរាជអាជ្ញាជាទីគោរព! ខ្ញុំសូមនិយាយថា ភស្តុតាងសម្រាប់បញ្ជាក់អំពីការជជែកវែកនិងការបង្ខំខ្ញុំយ៉ាងម៉េចនៅក្នុងខ្សែអាត់មានហើយ សូមអញ្ជើញលោកយកមកពិនិត្យចុះ ។ ទីពីរ សេចក្តីសន្និដ្ឋានរបស់ខ្ញុំ វាជាសេចក្តីសន្និដ្ឋាន។ ដូច្នេះ បើសិនជាមានទោសដោយសារតែសន្និដ្ឋានខ្ញុំទទួល ។ ខ្ញុំសន្និដ្ឋានមែន ប៉េស៊្វ ធ្វើដូចចោរអឺចឹង។ ប្រទេសគេមានអធិបតេយ្យភាព ម៉េចមិនឯកភាពជាមួយនឹងរដ្ឋាភិបាលសិន ។ នេះជាសេចក្តីសន្និដ្ឋានរបស់ខ្ញុំ បើខ្ញុំមានទោសត្រឹមតែសន្និដ្ឋានសូមទទួលទោស ។

**ស៖** ខ្ញុំចង់បញ្ជាក់អំពីចំណុចឲ្យបានជាក់លាក់បន្តិចលោក កាំង ហ្កេកអ៊ាវ ។ លោកគឺមានឱកាសដើម្បីបង្ហាញអំពីការគំរាមកំហែងទាំងនេះ ដែលលោក ប៉េស៊្វ បានធ្វើមកលើលោក ដែលលោក ហេង ហាំខេង បានធ្វើមកលើលោក គឺលោកមានឱកាសដើម្បីឲ្យគេស្តាប់ខ្សែអាត់នោះនៅផ្នែកនៃកាសែតដែលមានចំណុចនេះ ដែលលោកបានអះអាងថា មានការគំរាមកំហែងពីពួកគេ ឬក៏មានការស្រែកពីពួកគេ ។ តើលោកអាចពន្យល់ប្រាប់តុលាការបានទេ ហេតុអ្វីបានជាលោកមិនព្រមធ្វើដូច្នោះពីមុនមក?

**ឆ៖** លោកសហព្រះរាជអាជ្ញាជាទីគោរព! សូមលោកងាកទៅក្រោយវិញ មើលពេលវេលាយើងនៅពេលនុ៎ងប៉ុន្មានមីនុត? សូមលោកពិនិត្យមើលបញ្ហាហ្នឹងបន្តិចមើល ប៉ុន្មានមីនុតដែលលោកចៅក្រមលោកសួរខ្ញុំ ។

**ស៖** លោកប្រធានខ្ញុំចង់សូមអាននូវឯកសារពីសំណុំរឿងដែលឯកសារហ្នឹងបានលើកយកមកនិយាយរួចហើយដោយចៅក្រម ឡាវែន៍ គឺជាកំណត់ហេតុនៃកិច្ចសម្ភាសន៍រវាងជនជាប់ចោទចុះថ្ងៃទី២១ ខែមួយ កាលពីឆ្នាំទៅ គឺលេខ D-៣០ ហើយនិងមានលេខ ERN00159555 ។ នៅក្នុងការឆ្លើយតបរបស់សហចៅក្រមស៊ើបអង្កេតលោក ម៉ាកសែល ឡឺម៉ុងដ៍ ទាក់ទងទៅនឹងស្ថានភាពនៃការជួបប្រជុំគ្នាដែលបានធ្វើឡើងកាលពីខែឧសភា ឆ្នាំ១៩៩៩ ។ ជនត្រូវចោទបានឆ្លើយថា បានឆ្លើយដោយលម្អិតថាៗ ហើយនៅចុងបញ្ចប់គាត់និយាយថា "ខ្ញុំនឹងផ្ញើនូវក្តីអង្កេតរបស់ខ្ញុំជូនឲ្យលោកអ្នកនៅពេលថ្ងៃណាមួយនៅពេលក្រោយ" ។ នោះគឺទាក់ទងទៅនឹងបទសម្ភាសន៍ដែលយើងបានពិភាក្សាគ្នានៅថ្ងៃនេះ ។

[១៤:៤៨:៣៨]

ខ្ញុំបាទសុំសួរម្តងទៀតលោក កាំង ហ្កេកអ៊ាវ តើមានហេតុផលអ្វីបានជាលោកមិនបង្ហាញអំពីការចោទប្រកាន់ដ៏ធ្ងន់ធ្ងរបំផុតបែបនេះអំពីអាកប្បកិរិយារបស់លោក ប៉េស៊្វ មុននឹងថ្ងៃនេះ ។

**ឆ៖** លោកសហព្រះរាជអាជ្ញាជាទីគោរព! ដំបូងអត្ថបទដែលលោកអាននេះ ខ្ញុំគួរតែសុំលោកឲ្យអានហួរហែពីមុនមកបន្តិច ដើម្បីឲ្យយល់សភាពការណ៍យើងនាពេលនោះ ។ ហើយយកល្អឲ្យអ្នកណា--លោក១ព្រះរាជអាជ្ញាខ្មែរ លោកអានជាភាសាខ្មែរផង នេះទីមួយ។ ទីពីរ សូមលោក អាឡិចប៊ែត ខ្លួនលោកនៅថ្ងៃនុ៎ង គឺនៅជួបជុំជាមួយយើង លោកពិនិត្យមើលប៉ុន្មានមីនុតដែលយើងមានពេលសម្រាប់ជជែកគ្នា? រួចឥឡូវយើងមានពេលប៉ុន្មានមីនុត ប៉ុន្មានម៉ោង ដើម្បីខ្ញុំរាយការណ៍ជូនលោកចៅក្រមឡាវែន៍ ។

**ស៖** ខ្ញុំមានការពេញចិត្តក្នុងការអញ្ជើញខាងសហសេវិករបស់ខ្ញុំខាងជាតិឲ្យធ្វើការអានឯកសារជាភាសាខ្មែរ ។ សូមអនុញ្ញាតចំណាយពេលប៉ុន្មាននាទីនេះ ដើម្បីរៀបចំការអានជាភាសាខ្មែរ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ, អនុញ្ញាតអញ្ជើញសហព្រះរាជអាជ្ញាខ្មែរឡើងអានឯកសារជាភាសាខ្មែរតាមការស្នើសុំរបស់ជនជាប់ចោទ ។

**លោក តាន់ សេណារ៉ុង៖**

សូមអរគុណលោកប្រធានដែលបានអនុញ្ញាតឲ្យខ្ញុំអានជាភាសាខ្មែរនូវកំណត់ហេតុរបស់ជនជាប់ចោទឈ្មោះ កាំង ហ្កេកអ៊ាវ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨ វេលាម៉ោងប្រាំបួន និងដប់នាទីព្រឹក ។ នៅក្នុងទំព័រទីបួន ដែលមានលេខERN158838 ដែលត្រង់ចំណុចដែលជនជាប់ចោទបានឆ្លើយថា "ខ្ញុំត្រូវបានសួររៀងរាល់ថ្ងៃពីម៉ោងប្រាំពីរដល់ម៉ោងដប់មួយ និងពីម៉ោងដប់បួនដល់ដប់ប្រាំមួយចាប់ពីថ្ងៃទី៣០ ខែមេសា ឬថ្ងៃទី១ ខែឧសភា រហូតដល់រសៀលថ្ងៃទី៣ ខែឧសភា ។ កិច្ចសម្ភាសន៍នេះធ្វើឡើងនៅសណ្ឋាគារដែលគេបានជួលឲ្យខ្ញុំ ហើយរាល់ចំណាយរបស់ខ្ញុំត្រូវបានបង់ដោយ គ្រីស្តូហ្វ ប៉េស៊្វ ។ សំណួរសួរដោយលោក គ្រីស្តូហ្វ ប៉េស៊្វ ជាភាសាបារាំងត្រូវបានបកប្រែជាភាសាខ្មែរដោយអ្នកបកប្រែជាភាសាខ្មែរដោយអ្នកបកប្រែ ហើយខ្ញុំបានឆ្លើយសំណួរជាភាសាខ្មែរ ហើយអ្នកបកប្រែបានបកប្រែជាភាសាបារាំង ។

លោកចៅក្រមបានសុំផ្ដល់ឲ្យលោកចៅក្រមនូវកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរដែលខ្ញុំ--របស់ខ្ញុំលើឯកសារទាំងពីរលេខ T00១ ដែលមាចំណងជើងថា "ការសួរចម្លើយលោក កាំងហ្កេកអ៊ាវ ហៅ ឌុច ប្រធានមន្ទីរស-២១ ខែទីបួន ទីប្រាំ ទីប្រាំមួយ ខែឧសភា ឆ្នាំ១៩៩៩" និង T0៧ និងD៩ ដែលមានចំណងជើងថា "កិច្ចសម្ភាសន៍ជាមួយ ឌុច" ។ ខ្ញុំនឹងផ្ដល់ជូនលោកចៅក្រមនូវការកត់សម្គាល់

លាយលក្ខណ៍អក្សររបស់ខ្ញុំក្នុងពេលវេលាសមស្របនិងយ៉ាងយូរបំផុតនៅដើមខែកុម្ភៈ ។

នេះគឺជាអ្វីដែលលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច បានឆ្លើយ ដូចសហការីរបស់ខ្ញុំបានលើកឡើងអម្បាញ់មិញហ្នឹង ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

លោកប្រធានជាទីគោរព! ខ្ញុំទម្លាប់ឲ្យសុំឲ្យអានឯកសារទាំងអស់នៅពេលដែលយើងអានឯកសារ ហើយខ្ញុំសូមអានជាភាសាបារាំងក្នុងករណីនេះ ។ គឺខ្ញុំអានឯកសារចុះថ្ងៃទី២១ ខែមករា ចាប់ពីចំណុចចាប់ផ្តើមមិនមែនចាប់ពីចំណុច ដែលលើកឡើងអំពីសហព្រះរាជអាជ្ញានោះទេ ។ គឺធ្វើឡើងពីចៅក្រម យូ ប៊ុនឡេង ដែលធ្វើឡើងនៅក្នុងថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨ ហើយបានសួរ ឌុច ថា តើលោកចាំបានដែរ ឬទេនៅថ្ងៃទី៤, ៥, ៦ ខែឧសភា ឆ្នាំ១៩៩៩ លោកត្រូវបានសម្ភាសដោយអ្នកកាសែត និងសម្ភាសដោយអ្នកតំណាងរបស់ *UNHCHR* ។ ហើយកថាខណ្ឌបន្ទាប់មក គឺមានចំណងជើងថា“កំណត់សម្គាល់របស់មេធាវី ហ្រ្វង់ស្វ័រ រូ” ដូច្នេះខ្ញុំសូមឲ្យសហព្រះរាជអាជ្ញាអាននៅក្នុងចំណុចហ្នឹង ។ ថាតើខ្ញុំបាននិយាយអ្វីខ្លះ? នៅក្នុងកំណត់សម្គាល់នេះ ។ មុនពេលដែលកូនក្តីរបស់ខ្ញុំឆ្លើយនឹងសំណួរនេះ ខ្ញុំសូមឲ្យកត់ត្រានៅក្នុងកំណត់ហេតុនេះនូវការរក្សាសិទ្ធិមួយចំនួនទាក់ទងនឹងឯកសារទាំងនោះ ។ ការរក្សាសិទ្ធិនេះមានពីរប្រភេទ ។ ទីមួយ លោក ឌុច មិនមែនត្រូវបានសម្ភាសតែដោយអ្នកកាសែតនោះទេ ប៉ុន្តែ ដោយអ្នកតំណាងនៃអង្គការសហប្រជាជាតិផងដែរ ។ ដែលអ្នកតំណាងនេះ គួរតែរំឭកគាត់ឲ្យដឹងអំពីសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយ ប៉ុន្តែគេមិនបានធ្វើវាទេ ។ ទីពីរ វាមានភាពច្រលំបល់ច្ចូលគ្នាទាក់ទងទៅនឹងការបកប្រែខុសគ្នាជាច្រើននៃការសម្ភាសន៍នេះ ដែលត្រូវបានដាក់នៅក្នុងសំណុំរឿង ។ មេធាវីការពារក្តី សូមឲ្យផ្តល់កាសែតថតចម្លងមួយច្បាប់ដល់យើង ។ ការរក្សាសិទ្ធិទាំងនេះត្រូវបានកត់ត្រារួចហើយ ដូច្នេះកូនក្តីរបស់ខ្ញុំអាចឆ្លើយទៅនឹងសំណួរនេះបាន ។ ហើយបន្តមកទៀត ចៅក្រមបានសួរសំណួរ ។ ឧទាហរណ៍ ដូចដែលសំណួរលោកចៅក្រម ឡាវ៉ែន៍ គាត់បានសួរ ។ គឺអំពីការសម្ភាសន៍បានកើតឡើង លក្ខខណ្ឌណាខ្លះដែលការសម្ភាសន៍នោះបានកើតឡើង ហើយនៅពេលនោះគឺមានលទ្ធភាពផ្តល់ដល់ ឌុច ក្នុងការបង្ហាញអំពីយោបល់របស់ ឌុច ។ នៅពេលនោះ ឌុច គាត់បានរង់ចាំៗសហព្រះរាជអាជ្ញាឲ្យផ្តល់កាសែតថតចម្លងមួយច្បាប់ដល់គាត់ ។ ប៉ុន្តែ ដោយសារមានភាពលំបាក

ផ្សេងៗនោះទាក់ទង-- ដោយមានការលំបាកទៅនឹងឯកសារជាលាយលក្ខណ៍អក្សរដែលយើងបានដាក់នោះ យើងមិនមានការយល់អំពីឯកសារហ្នឹង ។ គឺឯកសារនោះ គឺមានការសម្គាល់ដោយ ប៉េស្ទី ដោយខ្លួនឯង ហើយឯកសារមួយចំនួនទៀតនៅក្នុងភាសាអង់គ្លេសនៃសេចក្តីប្រកាសដែល ឌុច បានឆ្លើយនោះនៅថ្ងៃដែលយើងជួប ជួបម្តងទៀតនៅថ្ងៃ៥ ខែ៥ ឆ្នាំ២០០៨ នៅមុខចៅក្រមស៊ើបអង្កេតបន្ទាប់ពី ឌុច បានស្តាប់នូវកាសែតថតនោះ ។ គឺខ្ញុំសុំអនុញ្ញាតផ្តល់ពេលឲ្យខ្ញុំប្រាំនាទី សូមអភ័យទោសលោកចៅក្រម ។

[១៤:៥៨:០៩]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

វាហាក់ដូចជាមិនអាចឲ្យខ្ញុំបន្ថែមទៅលើជំហរនេះដែលថា គោលការណ៍របស់គឺយុត្តិធម៌ ។ ឯកសារ៧៨ គឺវាមានលិខិតដែល ប៉េស្ទី បានបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត គឺឯកសារនេះចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០០៨ ហើយនៅក្នុងលិខិតនោះ គឺលោក ប៉េស្ទី បានបង្ហាញថា កាសែតថតចម្លងនោះ គឺបានបញ្ជូនទៅហើយ ។ ហើយខ្ញុំអត់ដឹងថា តើនៅថ្ងៃ៥ នោះគួរតែកាសែតនោះនឹងបានបញ្ជូនទៅយ៉ាងណានោះទេ ដោយសារតែលិខិតនេះចុះថ្ងៃ៨ ។

យើងបានទទួលកាសែតចម្លងនេះមុនពេលហ្នឹង ដោយសារតែនៅថ្ងៃ៥ ខែ៥ គឺមានការសួរចម្លើយដោយចៅក្រមស៊ើបអង្កេតម្តងទៀត ។ ហើយគាត់បានលើកដូចតទៅ៖ លោកចៅក្រមធ្វើត្រូវ គឺកាសែតចម្លងនោះគឺមិនបានបញ្ចូលទៅក្នុងសំណុំរឿងនៅឡើយទេ ។ គឺខ្ញុំមិនដែលដឹងថាកាសែតថតនោះគឺប្រើប្រឆាំងចំពោះខ្ញុំ ហើយខ្ញុំមិនទទួលបានសិទ្ធិក្នុងការនៅស្ងៀមនោះទេ ។ ដូច្នេះហើយ ខ្ញុំចង់លើកបញ្ហាទាក់ទងទៅនឹងកាសែតនេះ ។ ដូច្នេះហើយ ខ្ញុំក៏កត់សម្គាល់ឃើញផងដែរថា កាសែតថតចម្លងគឺមិនទាន់បានដាក់នៅក្នុងសំណុំរឿងនៅថ្ងៃ៥ ហើយនៅថ្ងៃ៥ ខែឧសភា ឆ្នាំ២០០៨ កាសែតនោះគឺមិនទាន់បានបញ្ចូលទៅក្នុងសំណុំរឿងនៅឡើយទេ ។ ហើយ ឌុច គាត់បានសន្និដ្ឋាននៅចំពោះមុខចៅក្រមស៊ើបអង្កេតថា ក្នុងដំណាក់កាលស៊ើបអង្កេតខ្ញុំព្យាយាមក្នុងវត្តមានរបស់មេធាវីរបស់ខ្ញុំ ខ្ញុំព្យាយាមឆ្លើយសំណួរទាំងអស់របស់ចៅក្រម ។ ហើយខ្ញុំចាត់ទុកថា សេចក្តីប្រកាសនេះ សេចក្តីប្រកាសជូន *UNHCHR* គឺវាមិនមានផលប្រយោជន៍អ្វីទេសម្រាប់ថ្ងៃនេះ ។

[១៥:០០:៥៦]

នេះគឺជាការឆ្លើយតបរបស់ខ្ញុំទៅដល់សហព្រះរាជអាជ្ញាដែលចង់ដាក់បន្ទុកទៅលើ ឌុច ដែលគឺ

នៅពេលនោះ ឌុច មិនបានផ្តល់យោបល់នោះទេ ។ ដូច្នេះ សូមឲ្យសហព្រះរាជអាជ្ញាមើលទៅលើឯក-សារ ឆ្នាំ២០០៨ ហើយគាត់បានបង្ហាញចៅក្រមស៊ើបអង្កេត ។ ហើយជនជាប់ចោទមិនមានបំណងផ្តល់យោបល់ផ្សេងៗណាមួយនោះទេ ដោយសារតែគាត់បានពន្យល់ទៅលើយោបល់និងគំនិតនិងជំហររបស់គាត់ចំពោះមុខចៅក្រមស៊ើបអង្កេតរួចហើយនោះ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ខ្ញុំយល់ទៅលើចំណុចលើកឡើងរបស់លោក រូ ប៉ុន្តែ វាជាចំណុចមួយមិនជាសូវល្អប៉ុន្មានទេ ។ ហើយខ្ញុំមិនស្នើសុំ ឬក៏ខ្ញុំមិនព្យាយាមសុំឲ្យចំណុចតូចៗទាំងអស់នៅក្នុងហ្នឹង ដាក់ចូលនៅចំពោះមុខតុលាការនោះទេ ។ ហើយវាមិនមែនទាក់ទងនឹងបញ្ហាព័ត៌មានតូចៗនោះទេ គឺវាទាក់ទងទៅនឹងព័ត៌មានសំខាន់ៗដែលជនជាប់ចោទគាត់ចោទប្រកាន់ថាមានការស្រែកដាក់និងមានគំរាមកំហែង ។ ដោយសារចំណុចហើយនេះ ទើបខ្ញុំដាក់ជូនឲ្យអង្គសាលាដំបូងជ្រាប ហើយគឺខ្ញុំលើកសំណួរមួយ ហើយខ្ញុំមិនទទួលបានចម្លើយនោះទេ ។ ហើយសុំឲ្យអង្គសវនាការធ្វើការទាញសេចក្តីសន្និដ្ឋានទៅលើចំណុចនេះដោយខ្លួនឯង ។

**ស៖** ខ្ញុំមានសំណួរមួយទៀត ដែលចង់ចោទសួរទៅកាន់ជនជាប់ចោទ ហើយសំណួរនោះគឺថាតើលោក កាំង ហ្គេកអ៊ាវ ទទួលស្គាល់មូលហេតុជាក់ស្តែងដែលគាត់មិនចង់ធ្វើការឆ្លើយតប គាត់មិនឆ្លើយតបទៅនឹងចម្លើយ ឬសេចក្តីប្រកាសដែលស្នើ ដែលរៀបចំដោយ ប៉េស្ស៊ូ ដោយសារតែមានលក្ខណៈដាក់បន្ទុកជាងចម្លើយផ្សេងៗដែលគាត់បានផ្តល់ ។ ហើយៗថ្ងៃនេះ គឺគាត់មិនចង់យកចម្លើយនោះ ដើម្បីប្រើដាក់បន្ទុកចំពោះគាត់ ។

**ឆ៖** ខ្ញុំស្តាប់មិនបានទេ មិនដឹងជាលោកព្រះរាជអាជ្ញាសួរខ្ញុំឬយ៉ាងម៉េច? បើសួរចង់សួរថា ម៉េចខ្ញុំស្តាប់អត់បានទេ ។ សូមបញ្ជាក់។

[១៥:០៤:00]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញា លោកចង់តាំងសំណួរទៅជនជាប់ចោទ ពីព្រោះអង្គជំនុំជម្រះស្តាប់ថាលោកមានសំណួរមួយទៀតទៅជនជាប់ចោទ ។ ប៉ុន្តែ តាមយើងស្តាប់គឺអត់ដឹងថា លោកជាការសួរ ឬក៏ជាការបកស្រាយរបស់ខ្លួនលោកទេ? អ៊ីចឹងជាបន្តនេះប្រសិនបើលោកសួរ សូមលោកតាំងសំណួរឲ្យបានជាក់លាក់ ច្បាស់លាស់ដល់ជនជាប់ចោទ ដើម្បីឲ្យជនជាប់ចោទស្តាប់យល់នូវសំណួរ ហើយគាត់ឆ្លើយ

តប ជៀសវាងសួរមិនច្បាស់ ហើយគាត់មិនឆ្លើយតប យើងថាគាត់មិនមានសមត្ថភាពមិនអាចឆ្លើយតបនឹងសំណួររបស់លោកបាន ។ សូមរៀបចំម្តងទៀត ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ើត៖**

**ស៖** ពិតប្រាកដណាស់លោកប្រធាន សូមអរគុណ ។ សំណួរនេះ គឺថា តើជនជាប់ចោទមានការភ័យខ្លាចចំពោះចម្លើយដែលគាត់បានផ្តល់ទៅឲ្យអ្នកតំណាងឲ្យខាងអង្គការសហប្រជាជាតិខាងផ្នែកសិទ្ធិមនុស្សគឺលោក ប៉េស៊្វ ហ្នឹងឬ?

**ឆ៖** ខ្ញុំសូមជម្រាបលោកសហព្រះរាជអាជ្ញាដោយត្រង់ ខ្ញុំអត់មានការភ័យខ្លាចទេ ។ ចិត្តខ្ញុំ ចង់បានតែអ្វីដែលខ្ញុំនិយាយដោយជ្រះស្រឡះក្នុងចិត្ត ហើយនិងអ្វីដែលខ្ញុំនិយាយឲ្យរួចតែពីមាត់ ។ នេះចំពោះការដែល ប៉េស៊្វ សួរចម្លើយខ្ញុំ ។ នេះខ្ញុំសូមនិយាយតែពីរឿងករណីខ្ញុំហើយនិង ប៉េស៊្វ ពីរឿងសួរចម្លើយខ្ញុំ ហើយនិងចម្លើយដែលខ្ញុំឆ្លើយ ។

**លោក ហ្រ្វង់ស៊័រ រូ៖**

លោកប្រធាន តាមរយៈសំណួរនេះសហព្រះរាជអាជ្ញា គឺព្យាយាមចង់ឲ្យជនជាប់ចោទនិយាយអំពីខ្លឹមសារនៃការសម្ភាសន៍នោះ ហើយចំណុចនេះយើងមិនបានលើកឡើងនិងចង់ពិភាក្សានៅទីនេះទេ។ យើងបាននិយាយហើយ យើងចង់និយាយតែពីលក្ខខណ្ឌ និងស្ថានភាពនៃការធ្វើកិច្ចសម្ភាសន៍នោះទេ ហើយសហព្រះរាជអាជ្ញា ព្យាយាមទៅតាមច្រកបង្អួចវិញ ដោយសារតែច្រកទ្វារយើងបានបិទមិនឲ្យសួរ ។ ដូច្នេះ ខ្ញុំនឹងសូមលើកឡើងថា កុំឲ្យសួរសំណួរណាមួយដែលទាក់ទងទៅនឹងខ្លឹមសារ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

សូមអរគុណលោក ប្រធាន ខ្ញុំអស់សំណួរក្នុងការចោទសួរទៀតហើយ ។

**សួរដោយប្រធានអង្គជំនុំ៖**

ការកត់សម្គាល់របស់មេធាវីការពារក្តីជាការសមរម្យហើយ ។ ឥឡូវនេះ អង្គជំនុំជម្រះបានទទួលព័ត៌មានផ្សេងៗពាក់ព័ន្ធជាមួយនឹងឯកសារទាំងអស់នោះហើយ ។ ហើយដោយសារកិច្ចការទាំងនោះអង្គជំនុំជម្រះបានសន្យាថានឹងចេញសេចក្តីសម្រេចនៅពេលខ្លីខាងមុខនេះ ។ ហើយអ៊ីចឹង គឺដល់ពេលនេះអង្គជំនុំជម្រះប្រកាសបញ្ឈប់ការធ្វើសវនាការលើអង្គហេតុ ម-១៣ ត្រឹមនេះសិន ។

ហើយជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមជម្រាបដល់អង្គសវនាការថាចាប់ពីពេលនេះតទៅអង្គជំនុំជម្រះចាប់ផ្តើម ធ្វើសវនាការពិភាក្សាដេញដោលលើអង្គហេតុការបង្កើតមន្ទីរសន្តិសុខស-២១ និងគុក

នៅមន្ទីរពេទ្យឆ្កួតនៅតាខ្មៅ ។ ហើយក៏អង្គជំនុំជម្រះសូមរំឭកដល់ភាគីដែលពាក់ព័ន្ធផងដែរថា តាមសេចក្តីណែនាំ អំពីការពិភាក្សាដេញដោលយើងបានបំបែកអង្គហេតុទាំងមូលនេះជា៧អង្គហេតុ ។ នៅក្នុងនោះមានអង្គហេតុ ទីមួយ គឺបញ្ហាទាក់ទិននឹងម-១៣ ហើយអង្គហេតុបន្ទាប់ គឺការបង្កើតមន្ទីរស-២១ និងគុកតាខ្មៅ ។ នេះជាការរៀបចំធ្វើឡើងដើម្បីឲ្យការពិភាក្សាដេញដោលមានលក្ខណៈច្បាស់លាស់ជាក់លាក់ ហើយទៅតាមកាលប្បវត្តិនៃដំណើរការប្រព្រឹត្តទៅនៃមន្ទីរស-២១ ហើយនឹងសមស្របទៅនឹងដីកាដំណោះស្រាយផងដែរ ដើម្បីជាការងាយ ។ ហើយក៏សុំចាប់អារម្មណ៍ផងដែរ ដោយសារអង្គហេតុហ្នឹងអាចមានការច្របូកច្របល់គ្នា អ៊ីចឹងដោយសារយើងបំបែកអង្គហេតុ អ៊ីចឹងគឺសូមភាគីទាំងអស់ពិភាក្សាដេញដោល ហ្នឹងពាក់ព័ន្ធទៅនឹងអង្គហេតុជាក់លាក់ ដែលយើងបានកំណត់នៅក្នុងរបៀបវារៈនៃការធ្វើសវនាការ ដើម្បីងាយយល់ ដើម្បីជៀសវាងភាពច្របូកច្របល់នៅក្នុងរឿងនេះ ។

ហើយជាកិច្ចបន្តនេះ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទមកកាន់ឈើរាងវង់ក្រចកសេះ ហើយយើងចាប់ផ្តើមសវនាការលើអង្គហេតុដូច បានជម្រាបជូនអម្បាញ់មិញនេះ ។

[១៥:១០:០៦]

លោក កាំង ហ្គេកអ៊ាវ លោកយល់ទេ ឥឡូវនេះអង្គជំនុំជម្រះជម្រាបថា ចាប់ពីពេលនេះតទៅយើងចាប់ផ្តើមធ្វើសវនាការដេញដោលលើអង្គហេតុនៃការបង្កើតមន្ទីរសន្តិសុខស-២១ ហើយក៏មានការរួមផ្សំនូវគុកមួយទៀត គឺនៅពេទ្យឆ្កួតតាខ្មៅ ។

មុននឹងចាប់ផ្តើមពិភាក្សា យើងខ្ញុំសូមជម្រាបទៅលោក កាំង ហ្គេកអ៊ាវ អំពីអង្គហេតុដែលយើងដែលយើងចាប់ផ្តើមធ្វើសវនាការនេះ គឺយើងចូលទៅអង្គហេតុស-២១ ដោយអង្គហេតុដំបូងនេះជាអង្គហេតុនៃការបង្កើតមន្ទីរស-២១ ហើយនិងអង្គហេតុមួយទៀត បន្ទាប់បន្សំទេគឺគុកនៅមន្ទីរពេទ្យឆ្កួត តាខ្មៅ ។ នេះជាអង្គហេតុដែលយើងត្រូវចាប់ផ្តើមធ្វើសវនាការនាពេលនេះ ។

ហើយនៅក្នុងអង្គហេតុ ដោយសារអង្គហេតុនៅក្នុងរឿងក្តីនេះ វាមានអង្គហេតុច្រើន ។ អ៊ីចឹងយើងធ្វើអង្គហេតុតាមកាលប្បវត្តិនៃដំណើរការប្រព្រឹត្តទៅនៃ ស-២១ តាំងពីដើមរហូតដល់ទៅប្រតិបត្តិការ ។ ហើយដើមនេះគឺយើងនិយាយតែពីអង្គហេតុនៃការបង្កើត ស-២១ និងការបង្កើតនូវគុកពេទ្យឆ្កួតតែប៉ុណ្ណោះ ។ លោកយល់ទេ?

**ស៖** លោក កាំង ហ្គេកអ៊ាវ តើលោកអាចនិយាយជម្រាបប្រាប់ដល់អង្គសវនាការបានអ្វីខ្លះទៅនូវអ្វី ដែលលោកចងចាំ អំពីការបង្កើតឡើងនូវមន្ទីរសន្តិសុខ ស-២១? សូមលោក សូមអញ្ជើញ។

**ឆ៖** លោកប្រធានជាទីគោរព ។ ដំបូងខ្ញុំបាទសូមបញ្ជាក់ថា ស-២១ នេះ វាជាការផ្តុំគ្នារវាងមន្ទីរសន្តិសុខកងពលលេខ៣ ដែលហៅថាមន្ទីរ០៣ របស់ ណាត ហើយនិងកម្មាភិបាលមួយចំនួន ដែលមកអំពីមន្ទីរ១៣ ។ សរុបមកវិញ សេចក្តីផ្តើមរបស់ខ្ញុំ គឺមន្ទីរស-២១ វាកើតឡើងចេញពីមន្ទីរសន្តិសុខ៧០៣ និងកម្មាភិបាលមកពី មន្ទីរ១៣ ។ ខ្ញុំសូមរំឭកជម្រាប--

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន គឺមានការបកប្រែមានបញ្ហា គឺមិនមែនការិយាល័យ០៣ នោះទេ គឺមន្ទីរ៧០៣ គឺកងពល៧០៣ អ៊ីចឹងគឺវាមានលក្ខណៈខុសគ្នាចំពោះតួលេខនៅទីនេះ ។

**ជនជាប់ចោទ៖**

**ឆ៖** ...សូមជម្រាបថាកងពលនោះឈ្មោះកងពល៧០៣ ឯមន្ទីររបស់កងពលនោះឈ្មោះ មន្ទីរ០៣ ។ ឯចំណែកសន្តិសុខនោះ បើយើងហៅពីក្រៅថាមន្ទីរសន្តិសុខរបស់កងពល៧០៣ ឬក៏មន្ទីរ-០៣ ។ ពាក្យមន្ទីរ-០៣ នេះ ខ្ញុំទើបតែហ្នឹងយកមកនិយាយទេ ហើយណាត ខ្លួនឯងហ្នឹងមានឈ្មោះសំងាត់មួយ ឈ្មោះ មាស មួយគឺបង០៣ ។

[១៥:១៥:០៥]

សូមតទៅទៀត ខ្ញុំនៅចាំបានថា ខ្ញុំសូមនិយាយជម្រាបអង្គសវនាការទាំងមូលថា ខ្ញុំនិយាយដំបូងតែអំពីរឿងភាគចំណែករបស់កម្មាភិបាលមកពី៧០៣ ដើម្បីរួមគ្នាក្នុងមន្ទីរស-២១ នេះ ។ ថ្ងៃ២០ ខែមិថុនា ១៩៧៥ ខ្ញុំត្រូវបានហៅយកមករៀន យើងខ្ញុំមកគ្នាបួននាក់ គឺខ្ញុំ អនុប្រធានរបស់ខ្ញុំឈ្មោះមិត្តស៊ុំ ហើយនិងខ្មោច មិត្តមាស បក្ខជនម្នាក់ ហើយនិង បង ម៉ម ណៃ ហៅ ចាន់ បក្ខជនម្នាក់ទៀតមករៀននៅភ្នំពេញ យើងខ្ញុំចាប់ផ្តើមរៀននៅថ្ងៃ២៤ ខែមិថុនា ១៩៧៥ ។ ហេតុអីបានជាខ្ញុំបាទចាំថ្ងៃខែម្ល៉េះ? មានសំណល់ឯកសារជាភស្តុតាងគឺ សៀវភៅកំណត់កត់ត្រារបស់ បង ម៉ម ណៃ ដែលខាងការិយាល័យចៅក្រមស៊ើបអង្កេតលោកប្រគល់ឲ្យខ្ញុំ ។ យើងខ្ញុំរៀនប្រហែលជាកន្លះខែ មេគឺលោកគ្រូ សុន សេន ឲ្យខ្ញុំទៅនៅចាំសេចក្តីសម្រេចនៅនឹងស្ថានីយ៍រថភ្លើងក្រុងភ្នំពេញ ឯចំណែកកម្មាភិបាលផ្សេងទៀត គាត់ឲ្យទៅកន្លែងវិញ ។ ដោយឡែកមិត្តស៊ុំ មេអនុញ្ញាតឲ្យទៅរកប្រពន្ធនៅឯខាងសៀមរាប ។ ដូច្នេះ យើងខ្ញុំនៅចាំការងារ នៅស្ថានីយរថភ្លើងក្រុងភ្នំពេញ ដែលគេហៅថានីរសារសេនាធិការ ។ និយាយមកដល់ត្រឹមនេះ ខ្ញុំសូមឆ្លៀតឱកាសបញ្ជាក់ការពិតមួយដែលគេសន្និដ្ឋានខុស គេថាខ្ញុំបាទមកនៅមន្ទីរនីរសាររបស់មេដឹកនាំ គឺនៅជាមួយនឹងមេដឹកនាំ តាមពិតមិនមែនទេ ។ កន្លែងនេះជាកន្លែងនីរសារ

របស់លោកគ្រូ សុន សេន សម្រាប់ឲ្យកម្មាភិបាល ដែលមិនទាន់មានភារកិច្ចស្នាក់នៅជាបណ្តោះអាសន្ន រង់ចាំសេចក្តីចាត់តាំង ។ កន្លែងនេះ គឺស្ថានីយ៍រថភ្លើងក្រុងភ្នំពេញនេះ ពីមុនមកមានកម្មាភិបាលដឹកនាំស្នាក់នៅមែន គឺ ប៉ុល ពត ក៏នៅហ្នឹង សុន សេន ក៏នៅហ្នឹង ក៏ប៉ុន្តែគេចេញបាត់អស់ទៅហើយ ។ ភស្តុតាង គឺចម្លើយសារភាពរបស់ ខៀវ សំផន និយាយថា ប៉ុល ពត, នួន ជា ហើយនិងគាត់នៅស្ថានីយ៍រថភ្លើង ចេញពីស្ថានីយរថភ្លើងទៅដល់ ទៅនៅនឹងវិហារព្រះកែវមរកត ដែល ខៀវសំផនខ្លួនគាត់ គាត់ហៅថា ប្រាសាទប្រាក់ ។ ដល់ទៅនៅនោះបានមួយរយៈបន្តិចទេ ក៏ចេញទៅនៅក-១ ហើយនិង ក-៣ នេះតាមចម្លើយរបស់គាត់ ។

គាត់ថាសរុបមក ប្រហែលជាទៅដល់ខែប្រាំមួយ ទៅដល់នុ៎ងហើយ ទៅដល់មន្ទីរក-១ និងក-៣ រួចអស់ទៅហើយ នេះជាភស្តុតាងបញ្ជាក់ថា យើងខ្ញុំអត់បាននៅជាមួយនឹងថ្នាក់ដឹកនាំណាម្នាក់ទេនៅរទេះភ្លើង ។

ទន្ទឹមនេះ យើងខ្ញុំក៏សុំបញ្ជាក់ជូនលោកចៅក្រមដែរថា នីរសាររបស់ សុន សេន មានបីប្រភេទ ប្រភេទទី១ គឺ នីរសាដែលនៅជាប់ខ្លួន ពាក្យខ្មែរក្រហមគេហៅថា នីរសាការពារ ។ បុគ្គលពីរនាក់នេះ គឺ មិត្តនឿន ហើយនិង មិត្តផន ជានីរសារការពាររបស់មេខ្ញុំ គឺរបស់លោកគ្រូ សុន សេន ។ មេខ្ញុំអញ្ជើញទៅណាយប់ថ្ងៃពីរនាក់ហ្នឹង តាមជាប់ នៅជាមួយនឹងមេ ។ ដូច្នេះ ឮថាពាក្យនីរសារ គឺមិនមានខ្ញុំបាទទៅនៅជាមួយមេទេ នេះនីរសារប្រភេទទី១ ។

[១៥:១៨:៤៩]

នីរសារប្រភេទទី២ មានគ្នា១២នាក់ គ្រប់គ្រងដោយ មិត្តថា នៅចាំទីស្នាក់ការដែលមេធ្វើការ គឺលោកគ្រូ សុន សេន គាត់អញ្ជើញទៅធ្វើការ កន្លែងធ្វើការនៅខាងជើងបុរីកីឡារ ដែលក្នុងផែនទីយើងខ្ញុំបានប្រគល់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត ផែនទីភ្នំពេញហ្នឹង ខ្ញុំដាក់អក្សរ “បេ”*(B)* ។ មានគ្នា១២នាក់ ពួកមិត្តថា សង់ត្រាល់ទូរស័ព្ទក៏នៅហ្នឹង *អង់តែនប៉ារ៉ាក្លុយ* របស់មេទាក់ទងជាមួយនឹងកងនានា ក៏នៅនុ៎ង ។ យើងខ្ញុំទៅធ្វើជាមួយនឹងមេ ក៏ធ្វើការនៅកន្លែងអក្សរ “B” ហ្នឹង ឯចំណែកកន្លែងចុងបំផុតរបស់មេខ្ញុំគឺអក្សរ “អា”(A) គឺស្ថានីយ៍រថភ្លើងដែលយើងខ្ញុំសរសេរអក្សរ “A” នៅលើផែនទី ។ កន្លែងនេះសម្រាប់តែកម្មាភិបាលដែលមិនទាន់មានភារកិច្ច កម្មាភិបាលមធ្យម មិនមែនកម្មាភិបាលធំទេ កម្មាភិបាលមធ្យមដែលមិនទាន់មានភារកិច្ចមករង់ចាំនៅទីនេះ ។

សរុបមកវិញ ក្រោយពីរៀនយើងខ្ញុំបានទៅនៅស្នាក់ហ្នឹងស្ថានីយ៍រថភ្លើង ដែលជាកន្លែងចាំ

ទទួលភារកិច្ច តែមិនមែនបានស្នាក់នៅជាមួយនឹងថ្នាក់ដឹកនាំណាម្នាក់ទេ ។ នេះខ្ញុំសូមសរុបប៉ុណ្ណេះ ។ ដល់យើងខ្ញុំនៅបានមួយរយៈស្រាប់តែមេប្រើឲ្យ ណាត យកខ្ញុំចេញពីស្ថានីយ៍រថភ្លើង មកនៅជាមួយ ណាត និងកន្លែងអគ្គសេនាធិការចាស់របស់ *សូស្តេន ហ្វៃណង់ដេស* នៅផ្លូវព្រះនរោត្តម ណាតក៏តាំងទីនៅអគ្គសេនាធិការ យើងខ្ញុំក៏នៅដេកនៅនុំង រង់ចាំភារកិច្ច ។

ដល់ថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧៨ ទើបបានមេហៅទៅឧទ្ទេសនាម ការបង្កើតអង្គភាពថ្មីឈ្មោះ មន្ទីរស-២១ ដែលមាន ណាត ជាប្រធាន រូបខ្ញុំ កាំង ហ្កេកអ៊ាវ ហៅ ឌុច ជាអនុប្រធាន ហើយនិង មិត្តម្នាក់ទៀតឈ្មោះ ឃឹម វ៉ាក ហៅ ហ៊ រ ជាសមាជិក ។ រឿងល្អិតយ៉ាងម៉េច មេមិនទាន់កំណត់ទេ គ្រាន់តែឧទ្ទេសនាមប៉ុណ្ណឹង បានមេចាត់តែថា មិត្តឌុច មិត្តឯងឲ្យគេទៅនាំកម្លាំងកម្មាភិបាលរបស់មិត្តពី អមលាំង យកមកភ្នំពេញ ។ ឯចំណែក មិត្តណាត មិត្តឯងនៅបង្ហើយការងារនគរបាល ការងារ នគរបាលកងពល៧០៣នេះឲ្យចប់ ។ ហើយទន្ទឹមគ្នានឹងពេលដែលមិត្តឯងចេញទៅឲ្យគេទៅយកកម្លាំង មិត្តឯងនៅនេះ មិត្តឯងដើររើឯកសារពីផ្ទះមេទាហាន មេប៉ូលិស ហើយនិងអគារសាធារណៈទាំងឡាយ ណាប្រមូលឯកសារយកមកទុក ចងក្រងឲ្យស្រួល ។ ខ្ញុំក៏ដើរប្រមូល ។ សូមជម្រាបជូនលោកចៅក្រម ថា ខ្ញុំដើរប្រមូលនេះដោយពឹងផ្អែកលើ មិត្តសុខ ប្រធានកម្លាំងសម្ងាត់របស់ក្រុងភ្នំពេញ មិត្តសុខ ថ្ងៃមុន ខ្ញុំបានលើកបង្ហាញរូប មិត្តសុខ ជូនលោកចៅក្រមឡាវែន៍ហើយ រូបពីរនាក់ខ្ញុំហើយនិងមិត្តសុខ ឈរនៅ ខ្នងសៀវភៅ *ឡឺ ព័រតែល* ។ យើងខ្ញុំដើរទៅប្រមូលឯកសារហ្នឹងតាមមិត្តសុខប្រាប់កន្លែង ។ ដូច្នេះ យើងយើងខ្ញុំចេះតែដើរប្រមូលយកមកទុក សូមជម្រាបធាតុ-- បើករង់ក្រចកបន្តិចជម្រាបអង្គសវនាការ ថា នៅពេលដែលខ្ញុំបានទៅរើនៅកន្លែងមួយនោះ ឈ្មោះ “ស៊ីប្រា”(*CEPRA)*។ ស៊ីប្រាហ្នឹងជាពាក្យ កាត់ទេ សរសេរតាមអក្សរបារាំង គឺសរសេរ *CEPRA* ។ *“C”* ហ្នឹងគឺសង់ត្រ៏ស៍ ប្រែថាមជ្ឈមណ្ឌល *“E”* ប្រែ *ដាំវេរូកាទ័រ* មជ្ឈមណ្ឌលសួរចម្លើយ *“P”* ហ្នឹង *ឌីព្រឹសង់ញ៉េ* *“R”* ហ្នឹង *រីវ៉ាល់យេ* *“A”* ហ្នឹង *អាឡារីម៉េ* គឺមជ្ឈមណ្ឌលសួរចម្លើយ ។ គឺ *CEPRA* នេះប្រែឲ្យចំជាភាសាខ្មែរ ហៅថា មជ្ឈមណ្ឌល សួរចម្លើយឈ្លើយសឹកនិងអ្នកចុះចូលមកហ្នឹងកងទ័ព ។ នេះឯកសារដែលសហព្រះរាជអាជ្ញាចង់សួរខ្ញុំ នេះ ស៊ីប្រា មិនមែនជាឯកសាររបស់ *ឌីស៊ីខែម* ទេ ។ *ឌីស៊ីខែម* ទៅប្រមូលយកពី*ស៊ីប្រា* មកទេ ខ្ញុំ ស្គាល់ឯកសារហ្នឹង ព្រោះខ្ញុំទៅរើខ្ញុំទុកអា *កុងហ្វេស្យុង* អស់ហ្នឹងនៅចោលទាំងកំភ្នុះ ហើយខ្ញុំអត់ យកចូលមកទេ ប៉ុន្តែគ្រាន់តែឃើញខ្ញុំដឹង ។ នេះសូមបើករង់ក្រចកប៉ុណ្ណឹង ។ ទីតាំងរបស់អា *ស៊ីប្រា* នៅខាងជើងផ្លូវប៉ាស្ទ័រ ក៏ប៉ុន្តែខាង-- (សុំទោស) នៅខាងកើតផ្លូវប៉ាស្ទ័រ ក៏ប៉ុន្តែខាងលិចផ្លូវព្រះនរោត្តម។

លោកសម្បត្តិ នៅខាងជើងវិទ្យាល័យព្រះស៊ីសុវត្ថិប្រហែលជាមួយផ្លូវនៅត្រង់ហ្នឹង ជិត *ស្បែរ* ចាស់របស់ *អំស៊ិក* នេះខ្ញុំទៅរើយកមក ។ ប៉ុន្តែ *កុងហ្វេស្យុង* របស់ពួកនេះខ្ញុំអត់យកទេ ខ្ញុំទុកចោលនៅនុ៎ង ដូច្នេះ *ឌីស៊ីខេម* ទៅប្រមូលពីក្រោយខ្ញុំទេ ។

[១៥:២៤:១៩]

ដូច្នេះ សូមសរុបមកបានន័យថា យើងខ្ញុំដើរប្រមូលគ្រប់ហើយ តាំងពី *គុយស្បែរអាអា* ក៏យើងខ្ញុំប្រមូលដែរ *គុយស្បែរអាអា* គឺ *កាត់ដេស្បែនេរ៉ាល់ ឌឺ ឡា មីនីស្ត្រាស្យុង ឌឺ ឡា រ៉ឺមែ* ក៏ខ្ញុំប្រមូលផ្ទះ វ៉ាន់ ស ក៏យើងខ្ញុំទៅ ។ ផ្ទះ លន់ នល់ ខ្លួនឯងនៅទួលគោក ខ្ញុំទៅខ្លួនឯងពីរថ្ងៃ រើខ្ទេចរើខ្ទីរបស់គាត់ទៅរើយកឯកសារ ។ ដូច្នេះ ខ្ញុំនៅប្រមូលឯកសារ ខ្មោចមិត្តមាស នាំកម្លាំងរបស់ម-១៣ ពីអមលាំងយកមកភ្នំពេញមកដល់ភ្នំពេញ ណាត ចាត់ចែងឲ្យនៅចន្លោះវត្តសន្សំកុសល និងផ្លូវខេមរភូមិន្ទ ។ ផ្លូវខេមរភូមិន្ទដូចជាគេហៅថា ផ្លូវលេខ៣៧១ អីមិនដឹងភ្លេច ។ យើងខ្ញុំនៅនុ៎ង ខ្ញុំដើរប្រមូលឯកសារក្មេងៗអស់ហ្នឹង គេដើររៀបចំផ្ទះ រៀបចំចាប់ជ្រូកអីយកមកចញ្ចឹម អត់ទាន់មានភារកិច្ចអីទេ ។

ដល់ពេលហ្នឹងឯងខ្ញុំប្រមូលឯកសារបានគួរសមហើយ ណាត គាត់ហៅខ្ញុំទៅតាខ្មៅ តែក្នុងថ្នាក់ជាអនុប្រធានហើយ គេនាំយើងដើរហើយ ។ ដល់នាំទៅតាខ្មៅ ទៅមើលគុកនៅតាខ្មៅហ្នឹងមួយភ្លែតទាល់ចូលភ្លុចទៅខ្ញុំទៅស្គាល់អាមនុស្សម្នាក់ដែលជិតស្និតនឹងខ្ញុំ ជាប់គុកនៅនុ៎ង ខ្ញុំដកខ្លួនថយ ។ ខ្ញុំថាអុញ្ញតទៀតហើយ អញគេចអារឿងហ្នឹង ឥឡូវមកជួបទៀតហើយ ។ ដូច្នេះ អាការចេះតែជួបអញ្ចឹងយើង ដែលខ្ញុំអត់ទៅអើតកន្លែងឃុំឃាំងនៅស-២១ ម៉ាអាយុ ។ ដល់ក្រោយមក ណាត នាំខ្ញុំទៀតមកគុកពិសេសរបស់គេ គុកពិសេសហ្នឹង គឺដាក់អ្នកមនុស្សសំខាន់ ។ គុកពិសេសហ្នឹង អត់យកនេះទេ គឺយកវីឡាស្តេចក្រុមព្រះ ស៊ីសុវត្ថិមុនីរ៉េត យកទៅប្រើ។ វីឡាស្តេចក្រុមព្រះ ស៊ីសុវត្ថិមុនីរ៉េត នៅផ្លូវព្រះនរោត្តម ខាងត្បូងបង់ក្រហាមបន្តិច ។ ណាត នាំខ្ញុំចូល ដល់ចូលឃើញ សោ ភន កំពុងសរសេរចម្លើយ ខ្ញុំដកខ្លួនអ៎ សោ ភន សូមបញ្ជាក់ថា សោ ភន នេះ គឺជាអភិបាលរងខណ្ឌដូនពេញ របស់ លន់ នល់ ។

រឿងខ្ញុំទៅមើលគុកចាស់ប៉ុណ្ណឹង ដូច្នេះ ដល់ខ្ញុំនិយាយចប់ពីគុកចាស់ ខ្ញុំសូមនិយាយពីរឿងតាខ្មៅ។ តាខ្មៅនេះ ណាត គាត់ប្រើទុកជាគុករបស់កងពល៧០៣ ឬក៏ហៅថាមន្ទីរ០៣ ឃុំទុកអ្នកទោសសាមញ្ញរហូត ។ ហើយសូមបញ្ជាក់ជូនតុលាការថា ណាត គាត់ប្រើពាក្យ “០៣” នេះរហូតដល់ចុងខែវិច្ឆិកា ហើយក៏នៅប្រើដែរ នៅសល់ឯកសារដែលតាមដានអំពីប្រវត្តិ គាម ទត ស្អីៗហ្នឹង គាត់សរសេរ

ស៊ីញៀគាត់ ។ ដូច្នេះ គាត់ប្រើពាក្យសូម្បី កើតមកស-២១ ហើយក៏ដោយ ក៏នៅប្រើពាក្យ០៣ យើងខ្ញុំនិយាយពាក្យ០៣នេះ មិនមែនចង់គេចថា អូ!សម័យ០៣នេះ អត់មានតួនាទីរបស់ខ្ញុំអីទេគ្រាន់តែចង់សូមបញ្ជាក់ថា ស-២១នេះ វាជាអង្គធ្នឹររវាងកម្លាំងរបស់មន្ទីរ១៣ និងកងពលមន្ទីរសន្តិសុខ៧០៣ហ្នឹងប៉ុណ្ណឹងឯង ។ ដល់ប្រហែលជាខែ០៩ ខែ១០ ខ្ញុំមិនច្បាស់ទេ ប្រហែលជាខែ១០ និយាយតាមខ្ញុំចាំទៅចុះ គឺណាត ឱ្យខ្ញុំនៅផ្ទះមួយផ្លូវលេខ ដូច៤១៣ ឬ៤៣១ ខាងក្រោយសារមន្ទីរទួលស្លែងបច្ចុប្បន្ននេះមួយផ្លូវ ផ្ទះនោះជាផ្ទះរបស់ឧត្តមសេនីយ៍ ជា គឹមអេង ដែល ជា គឹមអេង ជួលឱ្យ *យូអិនទីភី* ។ ខ្ញុំនៅហ្នឹង គាត់ឱ្យគេដឹកអ្នកទោសយកពីតាខ្មៅមកដាក់ទុកនៅនឹងផ្ទះមួយឱ្យកម្មាភិបាលសួរចម្លើយ សួររៀនសួរការងាររបស់ខ្ញុំចាប់ផ្តើមពីពេលហ្នឹងសរុបឯកសារស្អីៗ ដែលប្រមូលបានហ្នឹងនេះទៅ ។ ដូច្នេះ ការកកើតមន្ទីរស-២១ ចាប់តាំងពីពេលហ្នឹងមក មានខ្ញុំជាអនុប្រធាន គុកតាខ្មៅនៅជាគុកធំ ឯចំណែកគុកនៅត្រង់កន្លែង ដែលខាងត្បូងស-២១ ខាងត្បូងសារមន្ទីរទួលស្លែងបច្ចុប្បន្ននេះតាំងនៅ ជាកន្លែងសម្រាប់សួរចម្លើយ ។ មួយសន្ទុះ! ខ្ញុំឃើញ ណាត គាត់ប្តូរ ប្តូរកន្លែងសួរចម្លើយពីអាកន្លែងខាងលិចសារមន្ទីរទួលស្លែងបច្ចុប្បន្ននេះ យកទៅដាក់នៅ *ដេរិចស្យុងស្សេនេរ៉ាល់ ឌឺ ឡា ប៉ូលិស ណាស្យូណាល់* អគ្គនាយកដ្ឋាននគរបាលជាតិ ដែលភាសាទូទៅគេហៅថា *ប៉េហ្ស៊ី(PJ)* ប៉ូលីសហ្សូឌីសែ យកទៅដាក់នៅហ្នឹង ។ ប៉ុន្តែ ទីនោះគ្រាន់តែជាកន្លែងសួរចម្លើយទេ គុកនៅតាខ្មៅនោះ នេះតាមការវិភាគលើឯកសារដែលមានសល់ ឃើញអ៊ីចឹង ។ ដល់ទៅនៅនុ៎ងបានមួយរយៈមេដេញ ថាមិត្តណាត នៅហ្នឹងមិនបានទេណា ភៀវចិនណ៎ា មិត្តប្តូរ ។ ណាត ក៏គាត់ប្តូរកន្លែងមកនៅទីតាំងចាស់ ខាងលិចសារមន្ទីរទួលស្លែង ពេលហ្នឹងគាត់ឱ្យខ្ញុំផ្លាស់ចេញអំពីអាផ្លូវ អាផ្ទះនៅផ្លូវលេខ៤១៣នោះ ទៅនៅផ្ទះមួយទៀត ដែលខ្ញុំដាក់លេខ២ នៅក្នុងផែនទីរបស់ខ្ញុំ ។ សូមបញ្ជាក់ថាអាផ្ទះលេខ២ហ្នឹង គឺជាវីឡាចាស់របស់ដុកទ័រនីសាម៉ឺឌី ។ ខ្ញុំទៅនៅនុ៎ង ។ នៅពេលដែលកម្លាំងសួរចម្លើយនៅឯអគ្គនាយកដ្ឋាននគរបាលជាតិ ។ ដល់ណាត គាត់ចេញទៅ ខ្ញុំក៏ចេញពីអាផ្ទះដុកទ័រ នីសាម៉ឺឌី មកនៅហ្នឹងអាផ្ទះដែលខ្ញុំថតជាមួយមិត្តសុខដែលខ្ញុំសរសេរលេខ៣ ។ ដូច្នេះ នៅពេលដែល ណាត គាត់ចេញទៅខ្ញុំកាន់កាប់មន្ទីរ ស-២១ ទាំងស្រុងម្នាក់ឯងហើយ ។ នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

[១៥:៣១:១៧]

**ស៖** ហេតុផលយ៉ាងដូចម្តេចទៅបានជាមន្ទីរសន្តិសុខហ្នឹងដាក់ឈ្មោះថា មន្ទីរសន្តិសុខស-២១? តើឈ្មោះស-២១ នេះមានចាប់តាំងពីពេលណាមក? ហើយអ្នកណាជាកំណត់ឈ្មោះមន្ទីរនេះ?

**ឆ៖** ខ្ញុំបាទសូមបញ្ជាក់ថា ពាក្យ "ស-២១" នេះដាក់នៅថ្ងៃ១៥ សីហា ១៩៧៥ នេះតែម្ដង ។ នៅពេលនុ៎ង លោកគ្រូ សុន សេន មេខ្ញុំហ្នឹង គាត់ថា យើងមិនប្រើពាក្យនរគបាលទៀតទេ វាដូចយួនពាក្យហ្នឹងយួនវាដាក់ឲ្យ ហើយក៏ពួកសម្ដេចសីហនុ ក៏ប្រើដែរ អាននរគបាល ។ យើងប្រើពាក្យសន្តិបាលនរគបាល ប្រែថាអ្នកថែរក្សាព្រះនរគ ។ ឯចំណែកសន្តិបាល ប្រែមកថា អ្នកថែរក្សាសន្តិភាព សន្តិសុខនៅក្នុងប្រទេស ។ ដូច្នេះ យើងប្រើពាក្យសន្តិបាល អក្សរកាត់គឺ "ស" ។ ឥឡូវលេខគិតដាក់លេខប៉ុន្មាន? ពេលដែលមេសួរប៉ុណ្ណឹង ណាត ឆ្លើយផ្ទួង ដាក់លេខ២១ ទៅ អ្វូនៃលេខតេអ្វូរបស់ខ្ញុំ ។ អ៊ីអ៊ីចឹង ស-២១ ដូច្នេះក៏កើតពាក្យ ស-២១ តាំងពីពេលនោះមក ។

ដូច្នេះ ខ្ញុំសូមបញ្ជាក់បន្ថែមជូនអង្គសវនាការថា មន្ទីរនេះស្គាល់ជាផ្លូវការគឺមានតែ ស-២១ គ្មានពាក្យ ស-២៤ ។ ស-២៤ ណាត ក្បាច់ក្បូរទៅបង្កើតខ្លួនឯងទេ ខ្ញុំវាក់តើ អាស-២៤ ស្អី ។ មើលចុះឯកសារដែលនៅសល់សំណុំរឿងដែលគេហៅមិត្តហ៊ុយ ទៅប្រជុំរឿងកសិកម្ម ។ មិត្តហ៊ុយ ទៅក្នុងនាម ស-២១ មិនមែនក្នុងនាមស-២៤ ទេ ដូច្នេះ ខ្ញុំបដិសេធពាក្យថា ស-២៤នេះ បដិសេធត្រឹមតែថា ណាតគាត់បង្កើតមកខ្លួនឯងមិនមែនបក្សកុម្មុយនីស្តកម្ពុជាដាក់ឲ្យទេ ។ ក៏ប៉ុន្តែ ព្រៃសនៅតែជារបស់ខ្ញុំ ឧក្រិដ្ឋកម្មប៉ុន្មាននៅព្រៃស គឺខ្ញុំទទួលដដែល គ្រាន់តែបញ្ជាក់ប៉ុណ្ណឹង ។ សូមបញ្ចប់ ។

[១៥:៣៣:៤២]

**ស៖** លោកអាចបញ្ជាក់បានទេ អំពីការរៀបចំមន្ទីរសន្តិបាល២១ ដែលយើងប្រើកាត់ថា មន្ទីរសន្តិសុខ មន្ទីរស-២១ នេះមានរៀបចំរចនាសម្ព័ន្ធយ៉ាងម៉េចទៅ? ពីដំបូងៗនៃការចាប់ផ្ដើមរៀបចំនោះ។

**ឆ៖** លោកប្រធានជាទីគោរពនៅពេលដែលចាត់តាំងហើយភ្លាមនោះ ដូចខ្ញុំបានរាយការណ៍ជម្រាបរួចទៅហើយ យើងខ្ញុំនៅក្នុងការរៀបចំឯកសារដែលប្រមូលបានពីសម័យ លន់ នល់ ទុកដាក់ហើយនិងចងក្រងខ្លះ រាយការណ៍ជូនមេ ហើយនិងផ្ញើឯកសារខ្លះទៅមេ។ ដូចជាយើងខ្ញុំទៅរឹបអូសបានយកផែនទីអំពីទីតាំងយោធាអី នៅយួន នៅសៀមផ្ញើទៅមេ ។ នេះមែន ។ នេះការងារដំបូង ហើយដល់ក្រោយពីនោះមក យើងខ្ញុំមកដល់នាយកដ្ឋាន អគ្គនាយកដ្ឋាននរគបាលជាតិ យើងខ្ញុំបង្រៀនគេសួរចម្លើយ ហើយនិងដើរមើលគេសួរ ។ ឯចំណែក ក្មេងៗដទៃទៀតនៅសួរ ដោយឡែក ណាត គាត់យក ម៉ម ណៃ ទៅទុកជាស្មៀនគាត់ ។ គាត់បង្កើតរបៀបចាត់តាំងមួយទៀតកាន់តែកំប៉ិកកំប៉ុកឡើង គាត់ចង់បង្កើតការិយាល័យរបស់មន្ទីរស-២១ ហ្នឹងដាក់ថា ម-២១ ខ្ញុំបាទក៏ស៊ីញ៉េពាក្យ ម-២១ ដែរ ពាក្យ ម-២១ នេះនៅសល់ជាភស្តុតាងនៅឡើយ ។ នេះការពិត ។

ដោយឡែក កិច្ចការប្រចាំថ្ងៃហើយនិងកិច្ចរដ្ឋបាលទាំងអស់រួមទាំងព្រៃសផងនៅលើដៃមិត្ត ហ៊ិរ ជាអ្នកគ្រប់គ្រង ។ យើងខ្ញុំនិយាយនេះ គឺនៅតែរក្សាដដែលថា យើងខ្ញុំអត់គេចពីឧក្រិដ្ឋកម្មទេ ក៏ប៉ុន្តែ គ្រាន់តែបង្ហាញការពិត គ្នាអ្នករត់ខ្វាត់ខ្វែងដៃជើងមែនទែនគឺ មិត្តហ៊ិរ ឯចំណែកខ្ញុំ គិតគូរអារឿង ឯកសារឯណេះ ហើយនិងសេចក្ដីសារភាព ។ ហើយម្យ៉ាងទៀតការងារបក្ស សូមជម្រាបអង្គសវនាការ ទាំងមូលតាមរយៈលោកប្រធានថា ម៉ាក ណាត គាត់ជាលេខាមែន ការងារបក្សត្រូវមើលលើគាត់ ។ ក៏ប៉ុន្តែ មិនដឹងយ៉ាងម៉េច អ្នកមិននិយាយមិនដឹងយ៉ាងម៉េចទេ សាច់ទ្រឹស្ដីគាត់មិនដល់ខ្ញុំទេ ។ សូមជម្រាប លោកប្រធានថា យើងខ្ញុំទាំងពីរនាក់ ណាត និងខ្ញុំនេះនៅក្នុងជួរបដិវត្តន៍ជាមួយគ្នាតាំងពីចុងឆ្នាំ១៩៦៥ ខាងទ្រឹស្ដីខ្ញុំស៊ី ណាត រហូត នេះខាងទ្រឹស្ដីកុម្មុយនីស្ត ដែលយើងឥឡូវគេហៅថា ទ្រឹស្ដីផ្ដាច់ការវណ្ណៈ អធននោះ ខ្ញុំស៊ី ណាត រហូត ។ ដូច្នេះ សន្និបាតកកើតមន្ទីរ ស-២១ យើងខ្ញុំដឹកនាំ ។ ខ្ញុំបាទផ្ទាល់ខ្លួន ដឹកនាំ ណាត នៅហ្នឹង ក៏ប៉ុន្តែ មិនដឹកនាំកិច្ចការប្រជុំទេ ។ ដូច្នេះ ការងារបក្សត្រូវគាត់កាន់ ទៅបែរជា ខ្ញុំកាន់ ។ ការងារកំណត់ហេតុខ្ញុំកាន់ កំណត់ហេតុអី មិនមែនជាកំណត់ហេតុ ការងារសួរចម្លើយហើយ និងបញ្ជូនឯកសារទៅលើ ខ្ញុំកាន់កាប់ ឯកសារមួយចំនួន ។ នៅពេលហ្នឹងគឺអ៊ីចឹង ។ ឯចំណែកការងារ ប្រចាំរត់ពាសណាពាសណី គឺ មិត្តហ៊ិរ នៅលើមិត្តហ៊ិរទេ ហើយនិងមិត្តហ៊ុយ ។ នេះរចនាសម្ព័ន្ធ ពីរនេះវានៅអ៊ីចឹង ។ ឯចំណែកកម្មាភិបាលយកមកពីអមលាំងទាំងប៉ុន្មានបញ្ចូលក្នុងក្រុមសួរចម្លើយ ។ នេះសូមគោរពជូន ។

[១៥:៣៧:២៣]

**ស៖** យើងបានមើលឯកសារឃើញថាមានការច្បាស់លាស់នៃការយន្តការនៃការបង្កើតអង្គភាព នានាចំណុះឲ្យស-២១ ដោយដូចជា ឧទាហរណ៍ ផ្នែកខាងឯកសារ នៅខាងភស្តុភា ផ្នែកខាងកងការពារ នៅខាងសួរចម្លើយអីអ៊ីចឹង ។ សួរថា ពេលដែលយើងរៀបចំដំបូងនោះ តើកិច្ចការនៃការដំណើរការ រៀបចំដំបូងហ្នឹង យើងបានពិភាក្សាគូរអំពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងបង្កើតឡើងនៅអង្គភាពផ្សេងៗ ដើម្បីដំណើរការប្រតិបត្តិការចាប់ពីពេលនោះ ឬក៏បណ្ដើរៗក្រោយមកបានយើងចាប់ផ្ដើមធ្វើការរៀបចំ ដូច្នេះ?

**ឆ៖** លោកប្រធានជាទីគោរព! រចនាសម្ព័ន្ធចាស់របស់គេយើងខ្ញុំមិនរើរុះ នេះនិយាយខ្លីមួយ ម៉ាត់ ។ នៅជាអនុប្រធានកាន់តែអត់ចង់រើរូស កុំឲ្យគេថាយើងវាខែងរែងពេក ។ ដល់អត់ពីគេហ្នឹង ក៏មិនរើរូស ទុកឲ្យមិត្តហ៊ិរ នៅកាន់កាប់កិច្ចការគ្រប់បែបយ៉ាងប្រចាំថ្ងៃ ។ កិច្ចការប្រចាំថ្ងៃដែលធ្វើ

ឯចំណែកខ្ញុំផ្ទាល់ គឺទៅជាមួយមេខាងលើ ឯចំណែកអង្គភាពផ្សេងៗ ថតរូប អង្គភាពសួរ អង្គភាពការពារ អង្គភាពកងពិសេស អង្គភាពបង្កបង្កើនផល និងអប់រំសាជាថ្មីអី អង្គភាពតូចៗ គឺវាតំណតាំងពីគេចាត់តាំងពីមុនមក ។ ដោយឡែក អ្នកដែលបញ្ចូលពីម-១៣ ទៅគឺមានតែខាងសួរចម្លើយទេ ហើយបង ម៉ម ណៃ ដែលពីដើម ណាត ចង់ទុកឲ្យទៅជាស្មៀនគាត់ ក្រោយមកយើងខ្ញុំ ខ្ញុំបាទទុកជាអ្នកជំនួយសម្រាប់កាលណាចង់បញ្ជាឲ្យគេធ្វើអីទាល់តែខ្ញុំសរសេរទៅបង ម៉ម ណៃ ហើយស៊ីញ៉េខ្ញុំ ។ ឯចំណែក មិត្តហ៊័រ អត់សរសេរព្រោះគេក្នុងគណៈកម្មាធិការជាមួយ ហៅមកពីគ្រោះគ្នាជាឯកភាព គេចេញមុខទៅធ្វើក្នុងឋានៈគេជាអនុប្រធាន មិនបាច់មានស៊ីញ៉េខ្ញុំទេ ។ ឯចំណែកស្អីដែលត្រូវឆ្លងកាត់បង ម៉ម ណៃ ខ្ញុំសុទ្ធតែស៊ីញ៉េ នេះខ្ញុំទុកជាជំនួយការរបស់ខ្ញុំ ។ ឯចំណែក មិត្តប៉ុន មិនមែនជាជំនួយការទេជាកម្មាភិបាលដាច់ដោយឡែកសួរចម្លើយតែមនុស្សសំខាន់ ក្រៅពីនោះយើងខ្ញុំរក្សាការចាត់តាំងចាស់ ។

[១៥:៤០:១៤]

**ស៖** លោកនៅចងចាំទេ អំពីឈ្មោះរបស់អ្នកគ្រប់គ្រងស-២១ នេះ គេហៅជាប្រធានស-២១ ជាអនុប្រធានស-២១ ឬក៏ជាលេខា ជាអនុលេខា ឬក៏ជាសមាជិកអ៊ីចឹង ។ វាមានការខុសគ្នាទេ ឬក៏ប្រើប្រាស់វិធីណា ជាប្រធាន ជាអនុប្រធាន ឬក៏ជាលេខា ជាអនុលេខា នៅស-២១នោះ?

**ឆ៖** លោកប្រធានជាទីគោរព! ផ្លូវការបក្ស ខ្ញុំបាទជាលេខាគណៈកម្មាធិការមន្ទីរស-២១ មិត្តហ៊័រ ជាអនុលេខាគណៈកម្មាធិការមន្ទីរ ស-២១ ។ ឯចំណែក មិត្តហ៊ុយ ជាសមាជិកគណៈកម្មាធិការមន្ទីរ ស-២១ នេះគណៈកម្មាធិការពេញសិទ្ធិរបស់មន្ទីរស-២១ អត់បានរើសអ្នកជំនួយការអីត្រឹមត្រូវទេ ។ ខាងផ្លូវរដ្ឋបាលគេហៅខ្ញុំបាទថា ប្រធានមន្ទីរស-២១ ហើយមិត្តហ៊័រ អនុប្រធាន មិត្តហ៊ុយ សមាជិក ក៏ប៉ុន្តែជាទូទៅ គឺប្រើពាក្យប្រធានមន្ទីរស-២១ ។

**ស៖** លោកអាចប្រាប់ដល់អង្គសវនាការបានទេថា កម្លាំងកាលពីច្របាច់បញ្ចូលគ្នាដំបូងរវាងកម្លាំងមកពីកងពល៧០៣ ថាតើមានចំនួនប៉ុន្មាននាក់? ហើយកម្លាំងដែលលោកនាំយកពីម-១៣ អមលាំងដែលមានឈ្មោះមាស ជាអ្នកទៅយកមកនោះ មានចំនួនប៉ុន្មាននាក់?

**ឆ៖** កម្លាំង៧០៣ រាប់រយ ។ លោកប្រធានកម្លាំងគេរាប់រយ ខ្ញុំអត់ក្តាប់បានទេ សូមនិយាយដោយត្រង់ ។ ក៏ប៉ុន្តែសូមជម្រាបប៉ុណ្ណោះ ឋានៈ ណាត គាត់លេខាកងពល។ មិត្តហ៊័រ កាលពីសម័យសង្គ្រាម គឺមុន១៧មេសា គាត់នៅជាលេខាគណៈកម្មាធិការវរសេនាតូចកងពិសេស ។ សូមជម្រាបអង្គសវនាការដោយត្រង់ថា នៅក្នុងជួរកងទ័ព បក្សជឿទុកចិត្ត ហើយនិងស្រឡាញ់រាប់អានកងពិសេស

នោះជាងគេ ។ កងពិសេសនោះ គឺគេលោតចាក់កាប់ត្រង់ៗម៉ង់ ។ ដូច្នេះ គេស៊ូប្តូរស្លាប់រស់ដើម្បីបក្ស នេះតាមទ្រឹស្តីដែលគេបង្វឹកបង្វឹនកងពិសេសទៅអ៊ីចឹង ។ ក៏ប៉ុន្តែ ដល់ចូលមកមន្ទីរស-២១ នេះរៀបចំចុះឡើងៗ ណាត គាត់ចេះតែខំចាត់តាំងហើយ លើកមិត្តហ៊ីរហ្នឹង ឲ្យទៅជាអនុសេនាធំ-- វរសេនាធំ មិត្តហ៊ីរ មិត្តហ៊ុយ ឲ្យទៅជាវរសេនាធំ ។ ឯចំណែកយើងខ្ញុំបាទ កាលដែលនៅអមលាំងនៅឡើយ នៅក្នុងឋានៈជាសមាជិកសាខាប៉ុណ្ណោះឯង ។

ដូច្នេះ និយាយសរុបមកកម្លាំងនេះបើនិយាយតម្លៃរបស់វាមានតម្លៃស្មើនឹងវរសេនាតូច ឬក៏យើងនិយាយឲ្យស្រួលស្តាប់ទៅទៀត ដោយសារសំខាន់របស់វាគ្មានអ្នកណានៅពីលើ គ្មានកងវរសេនាធំណានៅពីលើ យើងអាចហៅវាបានថាវរសេនាធំឯករាជ្យ ។ នេះយើងខ្ញុំក្តាប់បានជារួមប៉ុណ្ណោះ ។ ឯចំណែកមកនៅនេះ គឺវាមានបី មិនមែនមានតែពីរទេ មានបីអង្គភាព ។ អង្គភាពមួយទៀត គឺអង្គភាពអ្នកតស៊ូសម្ងាត់នៅក្រុងភ្នំពេញ មេយកមកមួយចំនួនជាង១០នាក់ អាចប្រហែល១០នាក់ដែរ ។ នៅចុងបញ្ចប់នៅសល់តែម្នាក់ទេ អន់ សុខន ហៅ ត្រូវ រត់លឿនទៅបែកគ្នា គេសុំខ្ញុំចេញទៅនៅអមលាំង-- (សុំទោស) នៅឃុំពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំងនេះ ។ ដូច្នេះ បីនោះច្របាច់បញ្ចូលគ្នា ខាងកងទ័ព៧០៣រាប់រយ ច្រើនរយឯកឧត្តម ខ្ញុំជម្រាបនេះ ព្រោះតាមការសម្រិតសម្រាំងប្រហែលជាជាប់២០០ សម្រិតសម្រាំងសមាសភាពមកពី៧០៣ មិនដឹងប៉ុន្មានទេ ។ ដូច្នេះ រាប់រយ យើងខ្ញុំទៅសុំបានពីកំពង់ឆ្នាំងមកពីរជើង មួយជើងមួយឡានអាកាត់ៗចិន ។ ដូច្នេះ ប្រហែលជា៥០ ទៅ៦០នាក់ទាំងពីរជើងនេះ នេះគឺសុំក្រោយមន្ទីរ១៣-- (សុំទោស) មន្ទីរស-២១ កកើត ។ ដូច្នេះ សមាសភាពរយ មិនដល់ពាន់ទេ រយ នេះជាកម្មាភិបាលនិងយុទ្ធជន ។ បើសិនជាយើងរាប់ទាំងមនុស្ស ដែលនៅខាងស្រែជាពាក់កណ្តាលយុទ្ធជន ជាពាក់កណ្តាលអ្នកមានបញ្ហា វាជាងមួយពាន់ហើយមើលទៅជាងមួយពាន់មិនដឹង ជាងពីរពាន់មិនដឹង ។ ខ្ញុំជម្រាបខាងស្ថិតិ ខ្ញុំអត់គិត អត់គូរសោះ ទុកឲ្យគេធ្វើ ។

[១៥:៤៥:៣៩]

**ស៖** លោកបានឆ្លើយថា អ្នកដែលចាត់ចែងរៀបចំបង្កើតមន្ទីរស-២១ នេះតាមគំនិតផ្តួចផ្តើមរបស់ សុន សេន ។ អ៊ីចឹងមែនទេ?

**ឆ៖** អ្នកដែលមកឧទ្ទេសនាមបង្កើតស-២១ហ្នឹង គឺមេខ្ញុំតែម្តង គឺលោកគ្រូ សុន សេន ឋានៈគាត់ជានាយអគ្គសេនាធិការ ។

**ស៖** អម្បាញ់មិញលោកបានឆ្លើយថា លោកបានទៅ ធ្វើដំណើរទៅដល់គុកតាខ្មៅ គុកតាខ្មៅហ្នឹងសំដៅគុកនៅមន្ទីរពេទ្យ អតីតមន្ទីរពេទ្យឆ្កួតហ្នឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន គឺពិតនៅហ្នឹងពេទ្យឆ្កួតហ្នឹងតែម្តង ។

**ស៖** ពេលដែលលោកទៅដល់ហ្នឹង លោកសង្កេតឃើញថា អ្នកទោសជាប់នៅមន្ទីរពេទ្យនៅគុកមន្ទីរពេទ្យឆ្កួតហ្នឹងប្រហែលប៉ុន្មាននាក់ដែរទៅ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំចូលបានតែមួយបន្ទប់ទេ ខ្ញុំអត់បានចូលទៅទៀតទេ ចូលទៅជួបពេទ្យ ធី ដែលខ្ញុំបាទធ្លាប់ស្គាល់កាលពីនៅ២៥ ដូចគ្នាហ្នឹង ។ ជួបគាត់ ខ្ញុំចេញមកវិញមក ។ ដូច្នេះ ខ្ញុំចង់ដឹងរឿងរ៉ាវអីក្នុងឋានៈជាអនុប្រធានទៅឆាឆៅរឿងគេ អង្គភាពគេចាស់ពីមុនមកទេ ។ អត់ដឹង ។ ក៏ប៉ុន្តែសូមជម្រាបលោកប្រធានបន្ថែមទៀតថា គុកនៅតាខ្មៅនេះ ថ្វីត្បិតតែ ណាត គាត់ចេញទៅហើយក៏ដោយ ក៏ ណាត បានអង្វរខ្ញុំ ។ សូមទោស! ខ្ញុំប្រើពាក្យអង្វរទៅចុះ ព្រោះគាត់និយាយពន្យល់ខ្ញុំ "ថាអេ៎ គុកតាខ្មៅ កុំឱ្យគេណ៎ា" ។ ខ្ញុំថា "ទុកធ្វើអី"? គាត់ថា "ទុកប្រើទៅ!" ។ ប៉ុន្តែ គាត់ចេញទៅ ខ្ញុំឃើញគាត់មកអើតនៅនឹងជាមួយ មិត្តហ៊ីរ ញឹកណាស់ ហើយមេដល់ឲ្យខ្ញុំរាយការណ៍ជូនគាត់ទៅ គាត់ថា "អើឱ្យវាបង្ហើយការងារចាស់របស់វាទៅ" ។

ដូច្នេះ គុកនៅពេទ្យឆ្កួតនេះ ប្រហែលជាដល់ខែ៦ គាត់ចេញទៅពីជាខែ៣ ប្រហែលជាដល់ខែ៥ ឬខែ៦ ឬខែ៧ បានចប់ ។ ចប់អាគុកនៅតាមខ្មៅនេះ ហើយនៅពេលហ្នឹងខ្ញុំបាទរៀបចំវិទ្យាល័យ ពញាយ៉ាត នេះសម្រាប់ដាក់អ្នកទោសរួចហើយ ។ ហើយសូមនិយាយហួសបន្តិចទៅទៀត នៅពេលដែល ណាត គាត់ចេញទៅ គាត់ផ្តាំឱ្យខ្ញុំទុកពេទ្យឆ្កួតនេះប្រើ ។ ខ្ញុំក៏ទុក ព្រោះវាមានប្រយោជន៍អី អ្នកណាទាមទារ?

[១៥:៤៨:០៤]

ដល់ថ្ងៃមួយហ្នឹងមេ លោកគ្រូ សុន សេន ទូរស័ព្ទមកខ្ញុំ "ឌុច" "បាទ" "ពេទ្យឆ្កួតហ្នឹងខាងសង្គមកិច្ចគេសុំណ៎ា" ខ្ញុំថា "បានបង ខ្ញុំជូន ក៏ប៉ុន្តែអត់ទោស ខ្ញុំអត់ទាន់ជូនភ្លាមទេ ខ្ញុំឱ្យគេគាស់កកាយឆ្អឹងយកមកដុតឲ្យអស់សិន បានខ្ញុំជូនបាន" ខ្ញុំហើយដាក់តែទូរស័ព្ទហៅ មិត្តហ៊ីរ ។ ទូរស័ព្ទខ្ញុំតែហៅមិត្ត ហ៊ីរ មកជួប ។ ខ្ញុំថា "មិត្តហ៊ីរ បងគាត់ទាមទារប្រគល់ពេទ្យឆ្កួតទៅឲ្យខាងសង្គមកិច្ចវិញ ។ ឥឡូវខ្ញុំធានាជាមួយបងហើយ ថាឲ្យ។ ក៏ប៉ុន្តែ មិនដោះស្រាយឆ្អឹងទាំងប៉ុន្មានដែលយើងកប់នៅនុ៎ង អដ្ឋិធាតុទាំងប៉ុន្មានដែលយើងកប់នៅហ្នឹងឯង គាស់មក ហើយដុត" ។ ប្រហែលជាកន្លះខែក្រោយមក មិត្តហ៊ីរ គេមក

រាយការណ៍ "បង ខ្ញុំគាស់ដុតអស់ហើយ នៅសល់តែពីរទេ ក្រោមទំនប់ដែលទើបតែលើកថ្មី ទំនប់នោះធំណាស់ យើងធ្វើអីមិនកើត ហើយគ្មានអ្នកណាទៅរើអាទំនប់នោះផង" ។ ដល់បានទទួលដំណឹងអ៊ីចឹងខ្ញុំល្ងាចឡើងបានជួបមេ ទូរស័ព្ទទៅមេវិញថា "បង សូមជូន ខ្ញុំគាស់កកាយឆ្អឹងយកមកដុតអស់ហើយនៅសល់តែពីរទេក្រោមទំនប់" ។ ខ្ញុំរាយការណ៍អ៊ីចឹងទៅ ពីនុ៎ងមកពេទ្យឆ្កួតក៏បាត់ពីដៃខ្ញុំទៅ ។ ម្លោះហើយបានការស្រាវជ្រាវជំនាន់ក្រោយនេះ អត់ឃើញមានឆ្អឹងនៅហ្នឹង គុកមន្ទីរឆ្កួតតាខ្មៅ ។ ការស្រាវជ្រាវជំនាន់ក្រោយនេះ គេទៅរកដែរ ប៉ុន្តែអត់ឃើញមាន ។ នេះខ្ញុំចាត់ចែងអ៊ីចឹង បានវាអត់ឃើញ ។

**ស៖** លោកបានឆ្លើយរៀបរាប់កាលពីដំបូងហ្នឹងថា លោកក្រោយមកគឺមានកន្លែងសួរចម្លើយនៅក្រុងភ្នំពេញចំនួនពីរកន្លែង នៅក្នុងនោះមានទាំង ប៉េហ្ស៊ី ផង ដែលមានភារៈក្នុងការសួរចម្លើយអ្នកទោស ដែលនាំមកពីតាខ្មៅ ។ ច្បាស់ទេចម្លើយនេះ?

**ឆ៖** បាទ ច្បាស់ ។ ខ្ញុំនៅ ប៉េហ្ស៊ី ខ្ញុំបង្រៀនផង ខ្ញុំគេបង្រៀនគេសួរចម្លើយផង ខ្ញុំដើរមើលគេសួរចម្លើយផង ហើយនិងរៀបចំសេចក្តីរាយការណ៍ទៅមេផង ពីរឿងខ្សែខ្មាំង ខ្សែក្បត់ ។

**ស៖** សំណួរចង់ដឹងថា អ្នកទោសទាំងអស់ដែលលោកបាននិយាយថា បាននាំមកពីតាខ្មៅ ពីពេទ្យឆ្កួតនៅតាខ្មៅ មកសួរចម្លើយនៅពីរកន្លែង ។ កន្លែងរួមទាំងនៅ ប៉េហ្ស៊ី អតីត ប៉េហ្ស៊ី ផងនោះ ។ សួរថាក្រោយពេលសួរចម្លើយរួចហ្នឹង អ្នកទោសហ្នឹងបញ្ជូនត្រឡប់ទៅតាខ្មៅវិញ ឬក៏ទុកនៅទីក្រុងភ្នំពេញនេះតែម្តង?

[១៥:៥០:៤៤]

**ឆ៖** ប្រសាសន៍លោកប្រធាន ជាគោលការណ៍អ្នកណាក៏ដោយឲ្យតែសួរចប់ គេកម្ទេចហើយ ។ ដូច្នេះកន្លែងកម្ទេចៗជំនាន់នុ៎ង គឺតាមសន្និដ្ឋានបច្ចុប្បន្នគឺនៅឯពេទ្យឆ្កួតឯណោះឯង ។ អត់មានទៅគាស់ដីនៅត្រង់ ប៉េហ្ស៊ី ហ្នឹងឥដ្ឋថ្មច្រើន ។ ដូច្នេះខ្ញុំអត់បានទៅឃើញនឹងភ្នែក ហើយនិងអត់បានទៅដេញដោយគេទេ ។ ក៏ប៉ុន្តែសន្និដ្ឋានឥឡូវ គឺបញ្ជូនទៅនុ៎ង ព្រោះខ្ញុំឃើញតិចណាស់ ។

សូមជម្រាបប្រសាសន៍លោកប្រធានដោយស្មោះ ដោយច្បាស់ថា ប៉េហ្ស៊ី ហ្នឹង ក៏ខ្ញុំមិនដែលចូលទៅកន្លែងឃុំឃាំង ខ្ញុំចូលទៅហ្នឹងម្តងគត់ ។ ណាត នាំខ្ញុំទៅអង្គុយលេងជាមួយនឹងឪពុកមាគាត់ ។ មិនដឹងជាឪពុកមាចម្ងាយណាទេ ឈ្មោះ បានអ៊ូច និលពេជ ។ បានអ៊ូច និលពេជ ជាខ្មែរឥស្សរៈចាស់ដែលសម្តេចព្រះ នរោត្តម សីហនុ ប្រទានងារជា បានអ៊ូច និលពេជ ពាក់ស័ក្តិ៤ ។ គាត់ទៅអង្គុយ

និយាយលេងហ្នឹង ។ គោលបំណង ណាត បើតាមខ្ញុំមើល ប្រហែលជាចង់ឲ្យខ្ញុំជួយគិតគូទុកដាក់ផ្ទៃរក្សាផងដឹង អីមិនដឹងទេ ។ ប៉ុន្តែ ខ្ញុំធ្វើហី គ្រាន់តែស្តាប់ព្រោះគេប្រធានស្រាប់ ខ្ញុំអត់លូកដៃចូលទេ ។

សរុបមកគឺ--

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

លោកប្រធានខ្ញុំសូមអភ័យទោសដែលខ្ញុំកាត់ ខ្ញុំសូមឲ្យលោកប្រធានធ្វើការណែនាំទៅដល់ជនជាប់ចោទ ឲ្យគាត់និយាយឲ្យបានយឺតបន្តិចដើម្បីឲ្យការបកប្រែធ្វើការបកតាមទាន់ទៅលើអ្វីដែលបានលើកឡើង ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមរំឭកម្តងទៀតដោយសារបញ្ហាដែរ វាការបកប្រែ ហើយខ្លួនខ្ញុំផ្ទាល់ជាការលំបាកដែរ ព្រោះខ្ញុំនិយាយខ្មែរហ្នឹងវាញាប់ជាងគេ អ៊ីចឹងខំប្រឹងអានហ្នឹងដើម្បីពន្យឺតនៃការនិយាយ ហើយសំណូមពរនេះជាការត្រឹមត្រូវ ហើយខ្ញុំក៏ភ្លេចខ្លួនដែរ ។ អ៊ីចឹង សូមនិយាយឲ្យបានយឺតបន្តិចដើម្បីឲ្យ ទុកឱកាសឲ្យអ្នកបកប្រែអាចបកប្រែបាន ដើម្បីឲ្យយល់ខ្លឹមសារ ន័យ ទាំងសំណួរទាំងចម្លើយ ។

[១៥:៥៣:០៤]

ជាបន្តនេះប្រគល់វេទិកានេះទៅចៅក្រម លោក លោកស្រីចៅក្រម តើលោកស្រីមានសំណួរអ្វីត្រូវសួរទៅដល់ជនជាប់ចោទរូបនេះទេ ពាក់ព័ន្ធនឹងអង្គហេតុនៃការបង្កើតមន្ទីរស-២១ ហើយនិងគុកពេទ្យឆ្កួតតាខ្មៅ? ឈប់ៗ សូមទោស! សូមសម្រាកបី-បួននាទីសិន ព្រោះបញ្ហាអស់កាសែត ឥឡូវមានការរៀបចំផ្លាស់ប្តូរកាសែតថត ។

មន្ត្រីតុលាការរៀបចំចាត់ចែងភ្លាម!

ជាកិច្ចបន្តនេះ តើលោក លោកស្រីចៅក្រមមានសំណួរអ្វីត្រូវសួរដល់ជនជាប់ចោទរូបនេះទេ? ទាក់ទិនជាមួយនឹងអង្គហេតុនៃការបង្កើតមន្ទីរស-២១ និងគុកតាខ្មៅ ។ បើមានសូមអញ្ជើញ ។

សូមអញ្ជើញ លោក យ៉ា សុខន ។

**សួរដោយចៅក្រម យ៉ា សុខន៖**

ខ្ញុំសូមអរគុណលោកប្រធាន ។ សូមជនជាប់ចោទបញ្ជាក់មកមើលថា នៅពេលដែលជនជាប់ចោទបានឆ្លើយបញ្ជាក់ ចំពោះលោកប្រធានអម្បាញ់មិញនេះ គឺថាអ្នកផ្តួចផ្តើមគំនិតក្នុងការបង្កើតមន្ទីរស-២១នេះ គឺលោក សុន សេន ។

**ស៖** តើលោក សុន សេន នេះគាត់មានសមាសភាពជាអ្វី ហើយជាមនុស្សទីប៉ុន្មាននៅក្នុងគណៈអចិន្ត្រៃយ៍គណៈកម្មាធិការបក្ស ហើយការផ្ដួចផ្ដើមនេះ តើលោកសន្និដ្ឋានបានទេ តើមានការយល់ព្រមពី ប៉ុល ពត និង នួន ជា ទេ?

**ឆ៖** លោកចៅក្រមជាទីគោរព! ខ្ញុំសូមអរគុណ និងសូមឆ្លើយជូនដូចតទៅ៖

លោកគ្រូ សុន សេន ខ្ញុំនេះស្គាល់ជាចំហជារដ្ឋមន្ត្រីក្រសួងការពារប្រទេស និងជានាយអគ្គសេនាធិការនៃកងទ័ពបដិវត្តន៍កម្ពុជា ។ ក៏ប៉ុន្តែ នៅក្នុងជួរបក្ស គាត់ជាបុគ្គលទី៧របស់បក្សកុម្មុយនីស្តកម្ពុជា។ បុគ្គលទី១ គឺ ប៉ុល ពត ។ បុគ្គលទី២ គឺ នួន ជា អនុលេខាទី១ ។ បុគ្គលទី៣ គឺ សោ ភឹម ហៅ យ៉ាន់ អនុលេខាទី២ ទទួលបន្ទុកភូមិភាគបូព៌ា ។ បុគ្គលទី៤ គឺ អ៊ុង ជឿន ហៅ ម៉ុក ជាអនុលេខាទី៣ ទទួលបន្ទុកលេខាភូមិភាគនិរតីថ្មី ។ សូមបញ្ជាក់ថា និរតីចាស់ មាននៅទាំងខាងជើងផ្លូវលេខ៤ទាំងខាងត្បូងផ្លូវលេខ៤ ។ ឯចំណែកនិរតីថ្មី គឺវាមានតែផ្នែកខាងផ្លូវជាតិលេខ៤ ថែមតំបន់២៥ ។ ពីដើមតំបន់២៥ វាជារបស់ភូមិភាគពិសេស ។ ក្រោយ១៧ មេសា លែងមានភូមិភាគពិសេសទៀតហើយ ។

[១៥:៥៨:១២]

ខ្ញុំសូមតទៅទៀត។ បុគ្គលទី៥របស់បក្សកុម្មុយនីស្តកម្ពុជា គឺលោកគ្រូ អៀង សារី ហៅ វ៉ាន់ ជាសមាជិកពេញសិទ្ធិនៃអចិន្ត្រៃយ៍មជ្ឈិមបក្ស ទទួលភារៈការងារបរទេស ទាំងជាមួយបក្សម៉ាក្សលេនីនជាបងប្អូន ទាំងជាមួយរដ្ឋាភិបាលនៃប្រទេសនានា ។ បុគ្គលទី៦ គឺ វន វេត ហៅ បង វន អ៊ុំឈ្មោះរបស់គាត់ច្រើនណាស់ ពេញ ធួក, សុខ ធួក ទទួលភារកិច្ចជាឧបនាយកទី២ ។ ឧបនាយកទី១ ខ្ញុំភ្លេចបញ្ជាក់ ឧបនាយកទី១ គឺលោកគ្រូ អៀង សារី ។ ឧបនាយកទី២ គឺ បង វន ហ្នឹងឯង ជាបុគ្គលទី៦ ជាសមាជិកអចិន្ត្រៃយ៍ត្រៀម ។ បុគ្គលទី៧ ចុងបញ្ចប់គេនៅក្នុងគណៈអចិន្ត្រៃយ៍គឺលោកគ្រូ សុន សេន ជាឧប-នាយកទី៣ ។ ប៉ុន្តែ អំណាចសម្បើមណាស់ ព្រោះជាអ្នកទទួលខុសត្រូវខាងនគរបាល ខាងសន្តិសុខ ។ នេះយើងខ្ញុំរាយការណ៍តាមឯកសារថ្ងៃ៩ តុលា ឆ្នាំ១៩៧៥ ។

[១៥:៥៩:៥៦]

ដូច្នេះ កិច្ចការអី គេនៅជុំគ្នានៅមន្ទីរ៨៧០ គេរាយការណ៍ភ្លាមៗ ។ ឯចំណែក ការកកើតមន្ទីរ ស-២១នេះ មិនដឹងជាសម្រេចពីអង្គាល់ទេ ព្រោះអត់មានឃើញឯកសារ ។ ក៏ប៉ុន្តែ គ្មានហេតុផលអីដែលអាចបដិសេធថា ប៉ុល ពត មិនបានផ្ដើមគំនិតទេ គឺពិតជាគំនិតផ្ដើមរបស់ ប៉ុល ពត ។

ឯចំណែកស្អីក៏ដោយ ឲ្យតែ ប៉ុល ពត សម្រេច នួន ជា គាត់អត់មានសិទ្ធិសម្រេចទេ ក៏ប៉ុន្តែភារកិច្ចរបស់គាត់ខាងគ្រប់បែបយ៉ាងដែលបក្សកុម្មុយនីស្តធ្វើទៅលើផ្លូវឧក្រិដ្ឋកម្មគ្រប់បែបយ៉ាង គឺ នួន ជា គាត់អ្នកតាមដានការអនុវត្ត ។

ដូច្នេះ សរុបមក ប៉ុល ពត ជាអ្នកផ្ដើមគំនិត, សុន សេន ជាអ្នកអនុវត្ត តែ នួន ជា ជាអ្នកតាមដាន ។ នេះយើងខ្ញុំសរុបតាមការដែលឃើញផង ហើយនិងតាមឯកសារថ្ងៃ៩ តុលា ១៩៧៥ ផង ។ នេះសូមបញ្ចប់ ។ សូមលោកចៅក្រមជ្រាប ។

**ស៖** តើការបង្កើតមន្ទីរស-២១ នេះមានភារកិច្ចធ្វើអ្វី? ក្នុងការបង្កើតនេះមានលិខិតសម្រេចជាផ្លូវការពីថ្នាក់ណាមកទេ? ហើយមន្ទីរស-២១ នេះចាត់ថ្នាក់ក្នុងកម្រិតណាទៅនឹងមន្ទីរសន្តិសុខដទៃទៀត?

**ឆ៖** សូមអរគុណលោកចៅក្រម។ សូមបញ្ជាក់ថា ការចាត់តាំងរបស់ខ្មែរក្រហមក្នុងបក្សកុម្មុយនីស្តកម្ពុជា ខ្ញុំសូមបញ្ជាក់អ៊ីចឹង មិនងាយឃើញឯកសារចាត់តាំងទេ ។ ឯកសារចាត់តាំងដែលនៅសល់ហើយដែលធ្លាក់មកដល់ដៃខ្ញុំបាទក្នុងរយៈកាលនៃការស៊ើបអង្កេតនេះ ខ្ញុំឃើញមានពីរ ឯកសារថ្ងៃទី៣០ មីនា ១៩៧៦ នេះមួយ ហើយនិងឯកសារថ្ងៃទី៩ តុលា ១៩៧៥ នេះពីរ ។ តែឯកសារនេះ ជាឯកសារសម្ងាត់មិនធ្លាក់ដល់ដៃខ្ញុំបាទជាអ្នកអនុវត្តនៅខាងក្រោមទេ ជាឯកសារនៅខាងលើរបស់គេឯណោះ ។

ដូច្នេះសរុបមកវិញ ខ្ញុំចង់និយាយថា ការចាត់តាំងមន្ទីរស-២១ នេះ គ្មានលិខិតចាត់តាំងជាផ្លូវការមានត្រា មានអីទេ អត់ប្រើត្រាទេ ។ សូម្បីតែឯកសារថ្ងៃ៣០ មីនា ១៩៧៦ និងឯកសារថ្ងៃ៩ តុលា ១៩៧៥ ក៏អត់មានត្រា អត់មានហត្ថលេខាដែរ កំបុតក្បាលកន្ទុយ ។ ប៉ុន្តែ អ្នកណាក៏គោរពអាឯកសារហ្នឹងដែរ ។ ឃ្លាអាថ្ងៃ៣០ មីនា ១៩៧០ គឺទាំងអាចម៍ ទាំងឫស ទាំងគល់ ទាំងអស់ជាឃ្លារបស់ ប៉ុល ពត ខ្លីៗទៅអ៊ីចឹង នរណាក៏ស្គាល់ដែរ ។ ដូច្នេះ តែ ប៉ុល ពត សម្រេចហើយ វាទៅជាច្បាប់ វាទៅជាមាគ៌ា ។

[១៦:០៣:៣៤]

សរុបមកវិញ ខ្ញុំចង់បញ្ជាក់ជូនលោកចៅក្រមដែលបានមានប្រសាសន៍សួរខ្ញុំបាទអម្បាញ់មិញថាមានការចាត់តាំងទេ ជាផ្លូវការជាលាយលក្ខណ៍អក្សរទេ? បាទ, អត់ទេ ។ ហើយសូមអរគុណ ដែលលោកចៅក្រមបានសួរខ្ញុំបន្តទៅទៀត ។ មានឯកសារមួយសម្រាប់បញ្ជាក់ថា ស-២១ វាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ សុន សេន គឺដោយយោងទៅតាមសកម្មភាពផ្ទាល់របស់ខ្ញុំ រាល់ថ្ងៃរបស់ខ្ញុំបាទទៅជាមួយនឹងមេ ហើយនិងយោងតាមឯកសារថ្ងៃ៩ តុលា ១៩៧៥ ។ ឯចំណែកការទាក់ទងរវាង ស-២១ និងមន្ទីរនគរបាលទូទាំងប្រទេស គ្មានខ្សែទាក់ទងទទឹង មានតែការទាក់ទងតាមខ្សែបណ្ដោយ គឺមន្ទីរ

នគរបាលភូមិភាគណា លេខាភូមិភាគនោះជាអ្នកទទួលខុសត្រូវ ។ ឯកសារដែលនៅសល់ជាគោល--

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន! អ៊ីចឹងគឺថាការបកប្រែហ្នឹងមិនអាចបានទាន់ទេ សុំឲ្យលោក ឌុច និយាយឲ្យបានច្បាស់ម្តងទៀតអំពីខ្សែបណ្តោយ និងខ្សែទទឹង ពីព្រោះអីអាចមានបញ្ហាក្នុងការបកប្រែ ។ អ៊ីចឹងសូមលោកនិយាយម្តងទៀត ។

**ប្រធានអង្គជំនុំ៖**

លោកកាំង ហ្គេចអ៊ាវ សុំនិយាយម្តងទៀត ដោយសារមានបញ្ហាបកប្រែភាសា ។ ឥឡូវហ្នឹងយើងកំពុងតែមានបញ្ហាស្មុគស្មាញអំពីបញ្ហាបកប្រែភាសានេះ ហើយមានសំណើហើយយើងនឹងពិចារណាសម្រេចនៅក្នុងអំឡុងពេលឆាប់ៗខាងមុខ ។ ប៉ុន្តែ ឥឡូវនេះយើងមិនរង់ចាំទេ ដំណើរការនៅតែប្រព្រឹត្តទៅតាមអ្វីដែលយើងគ្រោងទុក ប្រឹងប្រែងឲ្យអស់លទ្ធភាព ដើម្បីប្រព្រឹត្តទៅឲ្យខាងតែបានដើម្បីជំរុញដំណើរការ ។

អ៊ីចឹងសូមឆ្លើយឡើងវិញអំពី បញ្ជាក់ឡើងវិញអំពីខ្សែបណ្តោយ ខ្សែទទឹងអំមិញនៃមន្ទីរសន្តិសុខដែលលោកឆ្លើយនឹងសំណួររបស់ចៅក្រម ។

[១៦:០៦:០៦]

**ជនជាប់ចោទ៖**

ខ្ញុំសូមបញ្ជាក់ថា អ្វីដែលហៅថាការទាក់ទងតាមខ្សែទទឹង ការទាក់ទងតាមខ្សែទទឹងគឺទាក់ទងតែសន្តិសុខ នឹងសន្តិសុខគ្នាឯង ។ ឧទាហរណ៍ សន្តិសុខស-២១ ទៅទាក់ទងជាមួយនឹងសន្តិសុខភូមិភាគបស្ចិម ។ ហ្នឹងហៅថា ការទាក់ទងតាមខ្សែទទឹង ។ បារាំងហៅការទាក់ទងបែបនេះថាស្ទី *រី ឡាស្យុង អូរីហ្សុងតាល់* ប្រហែលជាគេហៅអ៊ីចឹង ។ នេះខ្សែទាក់ទងពី ស-២១ ទៅមន្ទីរនគរបាលភូមិភាគបស្ចិមឬក៏អត់ ខ្សែទាក់ទងរបស់មន្ទីរស-២១ ទៅនគរបាលភូមិភាគពាយព្យក៏អត់ ខ្សែទាក់ទងរបស់ ស-២១ ទៅភូមិភាគកណ្តាលក៏អត់ គឺគ្មានទេ ការទាក់ទងនគរបាលនឹងនគរបាលបែបនេះ ។

ដូច្នេះ បានន័យថាគ្មានការទាក់ទងបែប *អូរីហ្សុងតាល់* ហ្នឹងទេ មានតែការទាក់ទងដែលខ្សែបណ្តោយ គឺពីខ្ញុំ ពីស-២១ ទៅមេខ្ញុំ លោកគ្រូ សុន សេន ។ គឺពីក្រោមឡើងលើ ពីលើចុះក្រោម អាចបារាំងគេហៅថា *អូរីហ្សុងតាល់ អំ វ៉េទីកាល់* ។ ការទាក់ទងបែបនេះ វាមានបញ្ជាក់ដោយឯកសារមួយគឺឯកសារថ្ងៃ៣០ ខែមីនា ១៩៧៦ ។ អ្នកដែលមានសិទ្ធិសម្រេចកម្មេចនៅតាមមូលដ្ឋានជនបទ គឺអចិ-

ន្ត្រៃយ៍ភាគ ។ ពាក្យអចិន្ត្រៃយ៍ភាគមួយម៉ាត់នេះ មិនមែនសំដៅសមាជិកអចិន្ត្រៃយ៍ទាំងមូលទេ គឺសំដៅលេខាជាពិសេសៗ ។

ខ្ញុំសូមលើកឧទាហរណ៍មួយពីរ ។ ឯកសារដែល ចាន់ សំ ហៅ សែ លេខាភូមិភាគ៨០១ គឺឧត្តរថ្មី រាយការណ៍មក ប៉ុល ពត វាបង្ហាញគឺពីលេខាភូមិឈ្មោះ ចាន់ សំ ហៅ សែ ហៅ កង ចាប នេះ មក ប៉ុល ពត ។ នេះជាភស្តុតាងមួយបញ្ជាក់ ថាគឺវាទៅតាមខ្សែបណ្ដោយអ៊ីចឹង ។ ហើយនៅពេលដែល ចាន់ សំ ហៅ កង ចាប ហៅ សែ ទៅចាប់មនុស្ស គឺប៉ះលើបងប្អូនប្រពន្ធ ខៀវ សំផន ទទួល កង ចាប ហៅ សែ ហៅ ចាន់ សំ វាមានសំណុំរឿង *(ស្ដាប់មិនបាន)* ប៉ុល ពត ឲ្យគេចាប់ ចាន់ សំ ហៅ សែ មក ឲ្យមកចូលមក ស-២១ បណ្ដោយ ។ ភស្តុតាងគឺនៅក្នុងសេចក្ដីសារភាពចុងក្រោយ-- កំណត់ហេតុសួរចម្លើយចុងក្រោយរបស់ ខៀវ សំផន ។

ដូច្នេះវាបញ្ជាក់ៗថា គ្មានខ្សែទទឹងពី ស-២១ ទៅ--

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអភ័យទោសលោកប្រធាន! សូមឲ្យជនជាប់ចោទនិយាយឲ្យយឺតៗបន្តិចជាងហ្នឹង ដោយ-សារតែខ្ញុំ ខាងសហព្រះរាជអាជ្ញា និងខាងមេធាវីការពារក្ដីមើលមុខគ្នាទៅវិញទៅមក ទាក់ទងទៅនឹងបញ្ហានេះ ។

[១៦:១០:០៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្សង់ម៉ាក ចង់កត់សម្គាល់អ្វី សូមអញ្ជើញលោកហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

វាជាបញ្ហាសំខាន់ណាស់ ដើម្បីឲ្យយើងមានឯកសារណាមួយដែលលោកនិយាយយោងទៅនោះ ប្រសិនបើមិនដូច្នោះទេ គឺវាពិបាក ។ ដូច្នេះហើយសូមឲ្យជនជាប់ចោទបង្ហាញចំពោះឯកសារទាំងឡាយដែលគាត់បានយោងបញ្ជាក់ឲ្យច្បាស់ទៅលើលេខយោងផ្សេងៗទៅលើឯកសារទាំងអស់នោះ ដើម្បីឲ្យយើងបានយល់ទាំងអស់គ្នា ។

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទអាចធ្វើតាមដូច្នេះបានដែរទេ?

ទីមួយសុំរំឭកម្ដងទៀត សូមនិយាយយឺតៗ ដើម្បីឲ្យមានការបកប្រែទាន់ ។

ទីពីរគឺមានការ សុំឲ្យមានការបង្ហាញនូវឯកសារ ដែលលោកឆ្លើយ ហើយយោងទៅលើឯកសារផ្សេងៗនោះ សូមឲ្យមានការបង្ហាញនូវឯកសារដែលយោងផង បានទេ?

**ជនជាប់ចោទ៖**

អរគុណលោកព្រះរាជអាជ្ញា និងអរគុណលោកចៅក្រម ឡាវែន៍ ។

ឯកសារដែល ខៀវ សំផន គាត់រាយការណ៍ថា ចាប់បងប្អូនប្រពន្ធគាត់មក ហើយ ប៉ុល ពត សម្រេចចាប់ ចាន់ សំ ហៅ សែ នេះ ។ នេះឯកសារៗលេខ D៤៩ ទំព័រ៥ ជាខ្មែរនៅខាងបន្ទាត់ដើមតែម្តង ។ ឯកសារលេខ D៤៩ ទំព័រទី៥ គឺបានន័យថាទំព័រ ERN00156192 ។ បន្ទាត់ខាងដើមតែម្តងនេះជាឯកសារ ជាអត្ថបទជាខ្មែរ ។ ខ្ញុំសូមអានអត្ថបទជាខ្មែរ៖

សំណួររបស់ជំនួយការសហព្រះរាជអាជ្ញា *ស្តាគហ្វត* “តើធ្វើដូចម្តេចទើបលោកអាចដឹងថាអ្នកទោសនៅព្រះវិហារត្រូវបានដោះលែង?” ។ ឆ្លើយ “ក្នុងចំណោមអ្នកដែលត្រូវចាប់ខ្លួន មានបងប្អូនរបស់ប្រពន្ធខ្ញុំ ហើយត្រូវបានដោះលែងនិងបញ្ជូនមកតាខ្មៅ ។ អង្គភាពនៅតាខ្មៅ ទទួលបន្ទុកផ្គត់ផ្គង់បុគ្គលិក ក១ និង ក៣ ហើយប្រពន្ធខ្ញុំបានទៅជួបគាត់នៅតាខ្មៅ ។ កម្មាភិបាលដែលជាអ្នកចាប់ គឺកង ចាប ដែលបន្ទាប់មកខ្លួនគាត់ក៏ត្រូវគេចាប់ខ្លួនផងដែរ” ។

[១៦:១៣:០៥]

ដូច្នេះ ឯកសារមួយនេះវាបញ្ជាក់តួនាទីរបស់ កង ចាប ទៅលើមន្ទីរសន្តិសុខនៅភូមិភាគ៨០១ ។ ឯចំណែកឯកសារមួយទៀត ខ្ញុំអត់បានយកមកទេ នៅលើលិខិតបញ្ជូនរបស់ កង ចាប បញ្ជូនសេចក្តីសារភាពរបស់ សាន់ អ៊ាប មក ប៉ុល ពត ។ សាន់ អ៊ាប ហ្នឹងប្រធានពាណិជ្ជកម្មនៅភ្នំពេញមក ប៉ុល ពត ។ ខ្ញុំអត់បានយកមកទេ ។ ឯកសារនេះសហចៅក្រមស៊ើបអង្កេតឲ្យខ្ញុំបញ្ជាក់សាថ្មីម្តងទៀតហើយ។

ដូច្នេះ យោងតាមឯកសារដែលមានក្នុង--

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

អរគុណលោកប្រធាន ។ ឯកសារដែលជនជាប់ចោទយោងនោះគឺៗកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ខៀវ សំផន ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៨ ។ យើងមានបញ្ហាបន្តិចបន្តួច គឺមេធាវីគាត់ចង់បញ្ជាក់ទៅលើបញ្ហានេះយ៉ាងម៉េច ដែលថាឯកសារនេះគឺអត់មាននៅក្នុងសំណុំរឿងនាពេលនេះ?

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ស្ថានការណ៍ដូចជាតឹងតែងដែរហើយ ហើយពេលវេលាក៏ដល់ពេលកំណត់ត្រូវសម្រាក

ហើយ ។ ដូច្នេះ អង្គជំនុំជម្រះប្រកាសសម្រាក ។ សវនាការថ្ងៃនេះគឺផ្អាកត្រឹមប៉ុណ្ណេះ ហើយលើកទៅបន្តសវនាការនៅព្រឹកថ្ងៃស្អែក ។

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់ទីនេះនៅថ្ងៃ ព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន ។

ហើយសូមជម្រាបជូនដល់អស់លោក លោកស្រីនៅក្នុង--

*(ចៅក្រមពិភាក្សាគ្នា)*

អ៊ឺចឹងសូមជម្រាបផងដែរថា នៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះហ្នឹងធ្វើសវនាការតែមួយព្រឹកទេ រហូតដល់ម៉ោងដប់ពីរ ។ ដោយឡែករសៀលអង្គជំនុំជម្រះនឹងសម្រាក ដោយសារមូលហេតុបញ្ហាច្រើនដែលត្រូវពិគ្រោះពិភាក្សា និងចេញសេចក្តីសម្រេចនៅក្នុងសប្តាហ៍បន្ទាប់ ដោយហេតុថា ឯកសារទាំងអស់សុទ្ធតែត្រូវចាំបាច់ក្នុងការឆ្លើយតបទៅនឹងសំណូមពរ និងតម្រូវការនៃនីតិវិធី ។

អ៊ឺចឹងសូមអ៊ឺចឹង ហើយសូមអញ្ជើញអ្នកដែលត្រូវចូលរួមក្នុងសវនាការ អញ្ជើញមកចូលរួមឲ្យបានមុនម៉ោងប្រាំបួននៅថ្ងៃស្អែក ៕

*[សវនាការផ្អាកនៅម៉ោង ១៦:១៧ នាទី]*